# បឋមសង្គាយនា
# ទេសនាត្រៃបី

ចោទ – ឆ្លើយ

ក្នុងព្រះត្រៃបិដក



ព.ស. ២៥១៦ គ.ស. ១៩៧៣

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

AnAnA
Computer
Trusted Service & Quality

# បឋមសព្ទាយនា

# ទេសនាត្រៃបី

---

ចម្លងចេញពីសាស្ត្រាស្លឹករឹត

ដោយ សែម-សូរ


សញ្ញាប័ត្រពុទ្ធិកឧត្តមសិក្សា បឋមភូមិ ១៩៦៣

និសិត្សមហាវិទ្យាល័យអក្សរសាស្ត្រ

និងមនុស្សសាស្ត្រ ភ្នំពេញ


---


ផ្សាយចេញពី

(បោះពុម្ពលើកទី ២)

ព.ស. ២៥១៧ គ.ស. ១៩៧៣



ទុកសិទ្ធិ

# អារម្ភកថា

ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ចូលបរិនិព្វានហើយបាន ៣ ខែ (ពីថ្ងៃពេញបូរមីខែពិសាខ ដល់ថ្ងៃពេញបូរមីខែស្រាពណ៍) ព្រះអរហន្តទាំងឡាយចំនួន ៥០០ ព្រះអង្គ មានព្រះមហាកស្សបជាដើម បានផ្តើមធ្វើបឋមសង្គាយនាឡើង (ផ្តើមធ្វើតាំងពីពេលបូជាព្រះបរមសព និង ចែកព្រះសារីរិកធាតុរួចហើយម្ល៉េះ) ចាប់ធ្វើនៅថ្ងៃ ១ រោជខែ ស្រាពណ៍ ឆ្នាំម្សាញ់ បញ្ចស័ក នៅក្នុងសត្តបណ្ណគុហា ក្បែរភ្នំវេភារៈ នៃនគរមគធៈ ដោយមានព្រះមហាកស្សបជាប្រធានសង្ឃ បានចោទសួរព្រះវិន័យ ចំពោះ ព្រះឧបាលិៗ ឆ្លើយ , ចោទសួរព្រះសូត្រនិងព្រះអភិធម្ម ចំពោះព្រះមហាអានន្ទត្ថេរ ៗ ឆ្លើយ (ព្រះអានន្ទឆ្លើយ ២ បិដកតែ ១ ព្រះអង្គឯង ព្រោះលោកជាឃ្លាំងធម៌ពូកែចាំ) ។

ការធ្វើបឋមសង្គាយនា (សង្គាយនាលើកទី ១ ឬការផ្ទៀងផ្ទាត់ធម៌វិន័យនៅវគ្គវគ្គ) នេះដោយព្រះមហាកស្សបប្រារព្ធ នូវពាក្យចម្រូងចម្រះ របស់សុភទ្ទភិក្ខុ ដែលមានយោបល់ជំទាស់នឹងព្រះធម្មវិន័យ កាលពេលព្រះពុទ្ធបរិនិព្វានហើយថ្មី ៗ ឯណោះ ។ លុះធ្វើចប់បិដកតាមវគ្គមួយ ៗ ហើយ ព្រះអរហន្តទាំងអស់ដែលគង់ចាំស្តាប់ ក៏សូត្រព្រមគ្នាឡើង ទាំងអស់យ៉ាងត្រឹមត្រូវមានរបៀបរៀបរយត្រឹមគ្នាជាផ្លូន ១ ។ ការសូត្រនោះ គឺសូត្រ៣ដង ក្នុងបិដកនីមួយៗ ដែលយើងហៅថា អានត្រ័យ- អានឬសូត្រ៣ដង ។

ព្រះបាទអជាតសត្រូវ មហាចមចក្រព្រះចៅមគធរដ្ឋ ដែល បានសម្លាប់ព្រះបាទពិម្ពិសារវៀរជាបិតា យករាជ្យសោយនៅឆ្នាំ ទី ៣៧ នៃពុទ្ធកាលនោះ , ពេលរៀបធ្វើសង្គាយនា ទ្រង់បានសោយរាជ្យបាន ៨ ឆ្នាំ

ហើយ ។ ក្រោយពេលពិឃាតព្រះបិតារួច ព្រះបាទអជាតសត្រូវទ្រង់បានជួបប្រាស្រ័យទាក់ទងនឹងព្រះសម្ពុទ្ធ ទ្រង់ទឹកភ្លុចព្រះទ័យ ណាស់ចំពោះកំហុស របស់ព្រះអង្គ ហើយអ្នកធ្វើបិតុឃាត ដូចព្រះបាទ អជាតសត្រូវនេះ ត្រូវទទួលទោសអនន្តរិយកម្ម ធ្លាក់ទៅសោយទុក្ខ ក្នុងអវិចីមហានរក ប៉ុន្តែកាលព្រះពុទ្ធបរិនិព្វានទៅ - ព្រះបាទអជាត សត្រូវទ្រង់ពគ្រោះ ដោយតូចព្រះទ័យ និង ភ័យខ្លាចចំពោះបាបកម្មនោះ ជាមួយព្រះអរហន្តទាំងឡា ទ្រង់ក៏ព្រមស្ម័គ្រព្រះទ័យជួយឧបត្ថម្ភ ធ្វើបឋមសង្គាយនា នោះដោយពេញទំហឹងអស់រយៈវេលា ៧ ខែគត់ទើបចប់ ( ចប់នៅថ្ងៃពេញបូរមីខែផល្គុណ ) ។ ព្រះបាទអជាតសត្រូវ កាលសោយ ទីវង្គតដោយត្រូវព្រះរាជបុត្រនាម **ឧទយភទ្ទ** ធ្វើឃាតយករាជ្យសោយ ទ្រង់ក៏ទៅសោយទុក្ខតែត្រឹមលោហកុម្ភីនរកប៉ុណ្ណោះ ។

អ្នកប្រាជ្ញខ្មែរយើងជំនាន់ចាស់ មានគំនិតប្រាជ្ញាវាងវៃណាស់ បាននឹកគិតយករឿងនេះមកចងក្រងជាគម្ពីរមួយ សម្រាប់ទេសនាចោទឆ្លើយនៅពេលបុណ្យទានម្តង ៗ - ដើម្បីផ្សាំផ្គួបផលធម្មកថិកដែលពុំសូវចេះធម៌អាថ៌ច្បាស់លាស់ , ចេះទេសន៍បានជំនាញ ឲ្យទេសនាកើតដោយអានតាមសាស្ត្រាសឹករឹក ដែលមានគោលធម៌យ៉ាងត្រឹមត្រូវលើនោះហើយស្រេច ។

បឋមសង្គាយនាត្រៃបិនេះ ជាក្បួនខ្នាត ១ ដ៏សំខាន់របស់ពុទ្ធសាសនិកជនយើងក្នុងបុរាណកាល ដែលបានរៀបចំឡើងយ៉ាងប្រណីត មាន

របៀបបែបផែនយ៉ាងត្រឹមត្រូវ សមទៅតាមរបៀបទេសនាចោទ ឆ្លើយ ប៉ុន្តែដោយការចម្លងត ៗ គ្នាពីមួយទៅមួយ ដាក់ក្នុងសាស្ត្រាស្លឹករឹតនៅតាមវត្តនីមួយ ៗ ច្រើនលើកច្រើនតំណរពេក ច្បាប់នេះក៏ចេះតែក្លាយប្លែក ៗ គ្នាពីមួយទៅមួយជាច្រើនអន្លើ ។

ខ្ញុំព្រះករុណា ខ្ញុំបាទបានឃើញគម្ពីរនេះ តំកល់នៅវត្តកោះអណ្តែត ភូមិកោះក្នោត សង្កាត់ព្រែកក្រើស ស្រុកកំពង់ត្រាច ( កំពត ) ក៏បានសូមអនុញ្ញាតពីព្រះតេជគុណចៅអធិការវត្តនោះ យកមកចម្លង ហើយកែសម្រួលត្រង់កន្លែងខ្លះដែលស្តាប់មិនបាន ឲ្យមានឃ្លាប្រយោគ ងាយស្តាប់ឡើង និងកែអក្ខរាវិរុទ្ធឲ្យបានត្រឹមត្រូវតែប៉ុណ្ណោះ ឯទៃពីនេះ ខ្ញុំព្រះករុណា ខ្ញុំបាទបានទុកឲ្យនៅតាមលក្ខណៈដើមទាំងអស់ ដូចពាក្យថា ‹‹ អ្នក, បង, ចុន, អើយ ជាដើម ដែលមានសំនៀងស្នូរស្ទួនរណ្តំគ្នាតាមរបៀបកម្រងកែវតាមបែបបុរាណ · ហើយដែលមានលក្ខណៈពីរោះពីសាតាមសម្ផស្ស និងសម្រស់ជាខ្មែរនេះឯង ។

នៅទីបញ្ចប់នេះ ខ្ញុំព្រះករុណា ខ្ញុំបាទសូមទោសពីសំណាក់លោកអ្នកចេះដឹងទាំងឡាយ ព្រោះការចម្លងនេះពុំបានត្រឹមត្រូវតាមច្បាប់ទម្លាប់ ក៏សូមអភ័យទោសឲ្យទាន ។

សូមព្រះពុទ្ធសាសនាបានចំរើនរុងរឿងជានិច្ចនិរន្តរ៍តទៅ ។

ថ្ងៃ ២០ មិនា ១៩៦៩

ចែសេង - ស្នូរ

# កិច្ចការទេសនាត្រៃបិ

តាមធម្មតា តាំងពីបុរាណកាលមក, ដើម្បីនឹងទេសនាសង្គាយនាត្រៃបិដកនេះ តេតែងរៀបគ្រែ ៣ ឬ ធ្វើអាសនៈឲ្យខ្ពស់តែ ១ តែមានកន្លែង ៣ ហើយនិមន្តព្រះធម្មកថិក ៣ អង្គ ឲ្យឡើងគង់លើគ្រែធម្មាសនៈនោះ ។ ព្រះថេរៈអង្គណាដែលមានវស្សាចាស់ជាង គង់នៅកណ្តាល ហើយដែលត្រូវតែងតាំងជាព្រះមហាកស្សប, ព្រះថេរៈ ២ អង្គទៀត គង់នៅខាងឆ្វេង - ស្តាំ នៃព្រះថេរអង្គចាស់ ដែលគេទុកព្រះថេរៈខាងឆ្វេងជាឧបាលិ អ្នកឆ្លើយព្រះវិន័យ ព្រះថេរៈដែលគង់ខាងស្តាំជាព្រះមហាអានន្ទអ្នកឆ្លើយព្រះសូត្រនិងព្រះអភិធម្ម ។

នៅពេលទេសនា ព្រះថេរៈអង្គកណ្តាលជាមហាថេរ តែងចំរើនពរញាតិញោម ប្រកាសតាំងខ្លួនជា ពះមហាកស្សប ព្រះឧបាលិ និងព្រះមហាអានន្ទ ។ តមកកាលធ្វើយ៉ាងនេះរួចហើយ ព្រះថេរ ទាំងពីរអង្គដែលគង់នៅសងខាង អង្គណា ១ ក៏បាន តែងធ្វើពិធីបកសករាជ ។ បន្ទាប់មកព្រះមហាថេជាមហាកស្សប តែងនមស្ការព្រះរតនត្រ័យ ( អានតាមសាស្ត្រា ) រចលើកសេចក្តីនិទានក្នុងមហាបរិនិព្វានសូត្រមកសំដែង ព្រមទាំងប្រកាសជំនុំសង្ឃ រួចសឹមទេសនាចោទ — ឆ្លើយតទៅតាមលំដាប់លំដោយ គឺព្រះមហាកស្សបត្រូវចោទសួរព្រះវិន័យនឹងមហាឧបាលិ រួចទើបចោទសួរព្រះសូត្រ និង ព្រះអភិធម្មជាមួយព្រះមហាអានន្ទ ។

នៅពេលចប់បិដកនីមួយ ៗ ព្រះសង្ឃដែលហៅថានាគសេនទាំង ៤ ឬ លើស

ពីនេះ ត្រូវសូត្រស្វាធ្យាយព្រះវិន័យ ឬ ព្រះសូត្រ ឬ ក៏ព្រះអភិធម្ម តាមការគួរតទៅ ។

ប៉ុន្តែ តាមរបៀបខាងលើនេះ ឃើញថាព្រះថេរៈដែលឋានៈជាព្រះមហាអានន្ទនោះ ឃើញថាគង់នៅធំនៅវយុណាស់ ។ ដូច្នេះគួរចែកការបកស្រាយទៅព្រះថេរ ដែលមានឋានៈជាព្រះមហាអានន្ទនោះវិញក៏ជាការគួរម្យ៉ាងដែរ ។

# បទចំរើនពរ

ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ

ធម៌គឺពរទាំងឡាយ ៤ ប្រការ គឺអាយុ ១ ពណ៌សម្បុរកាយ ១ សេចក្ដីសុខ កម្លាំង ១ សូមចំរើនកើតមានដល់លោក-អ្នក នាង ជាពុទ្ធបរិស័ទទាំងឡាយ ដែលមានចិត្តជ្រះថ្លាអញ្ជើញមកស្ដាប់ព្រះសទ្ធម្មវិសេស ទេសនានាវេលានេះឯង ។

ឱកាសនេះ អាត្មាភាពទាំង ៣ រូប ដែលគង់នៅលើគ្រែធម្មាសនៈនេះ បានទទួលភារៈជាអ្នកសំដែងធម៌ទេសនា បុច្ឆា វិសជ្ជនា ចោទឆ្លើយ តាមបែបបទ ដែលមានមកតាំងពីបុរាណកាលមក ជារបៀបសង្គាយនាត្រៃបី ក្នុងព្រះត្រៃបិដក ដើម្បីចែកជូនដល់ពុទ្ធបរិស័ទទាំងឡាយ ស្ដាប់យកផលានិសង្សរៀងៗខ្លួន ។

ដូច្នេះ បើអាត្មាភាពទាំងអស់រូបនេះ បានសំដែងទៅហើយដោយមានការភ្លាំងភ្លាត់ខុសខ្ចូចបទបាថបាលី ឬសេចក្ដីអធិប្បាយត្រង់កន្លែងណា ១ ក៏សូមឲ្យលោក-អ្នក នាង ជាពុទ្ធបរិស័ទទាំងឡាយមេត្តាអភ័យទោសដល់អាត្មាភាពទាំង ៣ រូប ហើយអាត្មាភាពទាំង ៣ រូបនឹងសូមសំដែងទៅតាមសមត្ថភាពរៀងខ្លួន សូមចំរើន ។

## របៀបបកសករាជ

## ( គំរូ )

តស្ស ភគវតោ សម្មាសម្ពុទ្ធស្ស បរិនិព្វុតមិវសតោ បដ្ឋាយ យាវជ្ជតនា ពុទ្ធសាសនាយុកាលស្ស គណនា សល្លក្ខេតព្វា = សូមពុទ្ធសាសនិកជនទាំងឡាយទាំងពួង កំណត់នូវពុទ្ធ-សាសនាយុកាល រាប់ចាប់ដើមតាំងថ្ងៃដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់យាងចូលបរិនិព្វានទៅថ្ងៃអង្គារ យាមអង្គារ ១៥ កើតខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក រហូតមកទល់នឹងថ្ងៃ ខែ ឆ្នាំនេះ ព្រះពុទ្ធសករាជព្រះសាសនាកន្លងទៅហើយបាន ២៥១១ ឆ្នាំ ខែ បាន (១ ") ថ្ងៃបាន(៧) ក្នុងបច្ចុប្បន្នកាលឥឡូវនេះ ស្ថិតនៅក្នុងឆ្នាំមមែ ឯកស័ក ក្នុងហោរាស្ត្រ ( ពុធ ៨ កើតខែចេត្រ ). ថ្ងៃ ខែ ឆ្នាំនេះ ទុកជាបច្ចុប្បន្នកាល នៅសល់ទៅអនាគតខាងមុខទៀត ( ២៤៨៨ ) ឆ្នាំ, ខែ ( គ្មាន ). ថ្ងៃសល់ ( ២២ ) ថ្ងៃទៀត ប្រមូលថ្ងៃ ខែ ឆ្នាំ ទាំង ៣ កាល គឺអតីតកាល បច្ចុប្បន្នកាល និង អនាគតកាល ត្រូវជាព្រះពុទ្ធសាសនាយុកាលគ្រប់ ៥០០០ ព្រះវស្សា ដោយបរិបូណ៌ ។

## បឋមសជ្ឈាយនា

## ទេសនាវគ្គ ៣

---

### បឋមនមស្សការ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

យោ កប្បកោដី- ហិបិ អប្បមេយ្យំ<br>
កាលំ ករោន្តោ អតិទុក្ករានិ<br>
ខេទំ គតោ លោ- កហិតាយ នាថោ<br>
នមោ មហាកា- រុណិកស្ស តស្ស

អសម្ពុធំ ពុទ្ធនិសេវិតំ<br>
យំ ភវាភវំ គច្ឆ- តិ ជីវលោកោ<br>
នមោ អវិជ្ជា- ទិក្កិលេសជាលំ<br>
វិទ្ធំសិនោ ធម្ម- វរស្ស តស្ស

គុណេហិ យោ សី- លសមាធិញ្ញា<br>
វិមុត្តិញ្ញាណប្ប- ភូតីហិ យុត្តោ<br>
ខេតញ្ជនានំ កុសលត្ថកានំ

តមរិយសង្ឃំ សិរិសា នមាមិ

តច្ចេវមច្ចន្ត– នមស្ស នេយ្យំ

នមស្សមានោ រតនត្តយំ យំ

បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ

តស្សានុភាវេន ហតន្តរាយោ

យោ នាថោ រីអង្គសម្តេចព្រះបរមលោកនាថសាស្តាចារ្យ ព្រះអង្គដ៏ជាទីពឹងពំនាក់នៃទេវតាមនុស្សសត្វផងទាំងឡាយឯណា , ករោន្តោ កាលព្រះអង្គសន្សំបន្ទំព្រះបារមី អតិទុក្ករានិ ព្រះអង្គទ្រង់ធ្វើនូវអំពើទាំងឡាយនោះ ក្រមក្រៃពេក គឺបុគ្គលដទៃឯណាមួយក្រមមិនធ្វើគ្រាបពំបានឡើយ បត្តោ ទ្រង់ដល់ហើយ ខេមំ នូវសេចក្តីទុក្ខព្រួយ នឿយលំបាកក្នុងកាយពល កាលំ អស់កាល អប្បមេយ្យំ នឹងរាប់ក៏ពុំបាន នឹងប្រមាណក៏ពុំត្រូវឡើយ កប្បកោដិហិ ស្វម្បី ដោយនូវច្រើនក្រៃលែងសែនកោដិកប្បទាំងឡាយ លោកហិតាយ ដើម្បីនឹងធ្វើឲ្យជាប្រយោជន៍ដល់សត្វលោក នមោ រីកិរិយានមស្សការ មេ នៃខ្ញុំព្រះអង្គ អត្ថុ ចូរមាន តស្ស លោកនាថស្ស

ដល់អង្គសម្ដេចព្រះបរមគ្រូលោកនាថសាស្ដាចារ្យ ព្រះអង្គជាទីពឹងនោះ ,
មហាការុណិកស្ស ដ៏មានព្រះរាជហឫទ័យនោះត្រជាក់សព្វសាយអាសូរ
ករុណា ដល់ទេវតា មនុស្សសត្វផងទាំងពួង ។

ជីវលោកោ រីលោកផងដ៏ប្រកបទៅដោយជីវិត, គច្ឆតិ តែង
អន្ទោលទៅ ភវាភវំ កាន់ភពតូចភពធំ, អសម្ពុធំ ហេតុមិនបាន
ត្រាស់ដឹង យំ ធម្មវរំ នូវព្រះនពលោកុត្តរធម៌ដ៏ប្រសើរវិសេសឯណា, ពុទ្ធ
និសេវិតំ ដែលព្រះសម្មាសម្ពុទ្ធអង្គជាម្ចាស់ នៃត្រៃភពទាំង ៣ ជាអម្ចាស់ព្រះអង្គ
តែងនឹងសេពគប់, នមោ រីកិរិយានមស្ការ មេនៃខ្ញុំព្រះអង្គ អត្ថុ ចូរ
មាន តស្ស ធម្មវរស្ស ដល់ព្រះនពលោកុត្តរធម៌ ដ៏ប្រសើរវិសេសនោះ
អវិជ្ជាទិកិលេសជាលំ វិទ្ធំសិនោ ជាព្រះធម៌មានកិរិយាកំចាត់បង់នូវ
បណ្ដាញកិលេស និងអវិជ្ជាដ៏ងងឹតសូន្យសុងជាដើមនោះហោង ។

យោ សង្ឃោ រីព្រះអរិយសង្ឃឯណានីមួយ យុត្តោ ដ៏ប្រ-
កបហើយ គុណេហិ ដោយនូវគុណផងទាំងឡាយទាំងពួង សីលសមា
ធិបញ្ញា វិមុត្តិញាណប្បភូតីហិ មានសីលសមាធិបញ្ញាផង មានបច្ច
វេក្ខណញ្ញាណផង ខេត្តំ ជាស្រែបុណ្យដ៏ប្រសើរ ជនានំ នៃសត្វជនផង
ទាំងឡាយទាំងពួង កុសលត្ថិកានំ អ្នកមានសេចក្ដីត្រូវការដោយបុណ្យកង
ការកុសល អហំ ខ្ញុំព្រះករុណា នមាមិ ក៏សូមនមស្ការទោនក្រាបថ្វាយ

ចង្គំប្រណម្យនមស្ការ តំ អរិយសង្ឃំ នូវជំនុំព្រះអរិយសង្ឃអង្គអរហន្តា
ទីណាស្រេចផងទាំងនោះ សិរិសា ដោយនូវត្បូង, អហំ ខ្ញុំព្រះករុ-
ណា នមស្សមានោ កាលធ្វើនូវកិរិយានមស្សការគោរព រតនត្តយំ
នូវគុណសម្បត្តិនៃព្រះត្រៃរតន៍កែវទាំង ៣ ឥច្ចេវមច្ចន្តនមស្សនេយ្យំ គឺគួរ
នឹងនមស្ការដោយពិត ឥច្ចេវំ មោះ យថា រតនត្តយេន ដោយ
នូវប្រជុំ ៣ នៃព្រះត្រៃរតន៍ អលត្ថំ បានហើយ យំ បុញ្ញាភិសន្ទំ
នូវកងការកុសលបុណ្យឯណា វិបុលំ ដ៏ធំទូលាយទូលំ ហតន្តរាយោ
មានប្រក្រតីអាចកំចាត់បង់នូវសេចក្តីអន្តរាយទាំងឡាយ អានុភាវេន ដោយ
កម្លាំងអានុភាព តស្ស បុញ្ញាភិសន្ទស្ស នៃកងអារកុសលផលបុណ្យ
នោះ ហោន្តុ ចូរមាន មេ ដល់ខ្ញុំម្ចាស់នាពេលឥឡូវនេះហោង ។

# សេចក្តីនិទាន

ភោ សាធវោ បពិត្រសាធុសប្បុរសផងទាំងឡាយអើយ ពេលនេះអាត្មាភាពនឹងសំដែងនូវព្រះធម៌វិសេសទេសនាតែខ្លៃ សេចក្តីក្នុងបឋមសង្គាយនា ជាទីសណ្តាប់ប្រាប់ដល់អស់បពិត្រសប្បុរសទាំងពួងរាល់គ្នាឥឡូវនេះ ក៏សូមឲ្យផ្ចិតផ្ចង់តម្រង់ស្មារតីប្រុងសោតប្រសាទទាំងសងត្រងត្រាប់ព្រះធម៌វិសេសទេសនា ក្នុងសេចក្តីនៃព្រះបរិនិព្វានសូត្រនេះ ហើយក៏បានបង្កើតធម្មសង្វេគក្នុងចិត្តសន្តានគ្រប់គ្នា ត្រូវតែគិតពិចារណាយកត្រៃលក្ខណញ្ញាណទាំង ៣ ប្រការនោះមកតាំងទុកខ្ជាប់ហើយក៏អ្នកនោះឯង មិនដែលនឹងវង្វេងអំពីសម្បត្តិ៣ប្រការ គឺសម្បត្តិមនុស្សលោកនេះ ១ សម្បត្តិសួគ៌ ១ សម្បត្តិព្រះនិព្វាន ១ ដ៏ជាស្ថានបរមសុខ ក្សេមក្សាន្តប្រសើរនោះឡើយ ។

បរិនិព្វានកាលតោ អច្ឆរិយានិ បាតុរហេសុំ បពិត្រ អើយ នាកាលថ្ងៃដែលសម្តេចព្រះជិនវង្សទ្រង់យាងចូលកាន់ព្រះបរមនិព្វាននោះ សឹងនឹងបង្កើតជាហេតុអស្ចារ្យ ករកើតអស់គ្រឿងមហាប្រឹថពីញាប់ញ័ររៀងដល់ស្ថានសួគ៌ា ផ្កាមន្ទារពស្សឹងនឹងធ្លាក់ជ្រុះចុះមកអំពីតាវត្តិង្សាសួគ៌មកលើផែនដីមហាប្រឹថពី ក្នុងខណៈខេត្តដែលព្រះអង្គទ្រង់ចូលបរមនិព្វាន ហើយមិនមែនតែប៉ុណ្ណោះឡើយ មានអស់ទាំងទេវបុត្តទេវតាទាំងឡាយក្នុងសែនលោកធាតុ មានព្រះឥន្ទ្រាធិរាជជាដើមជាប្រធាន សឹងនឹងអាន់ដៃកាន់នីវទៅនូវទៀន ធូប ភ្ញី ផ្កា ប្រទីបផ្កាលា សារពើនូវចាម៉រស្វែនត្ញាន់ សឹងនឹងមានសត្តគ្រប់មុកបូជា ព្រះបរម

សពសម្តេចព្រះបរមគ្រូនោះប្រិចភានតាបអាប់អស់និស្សា ។

មល្លរាជានោ បពិត្រអើយ រីអស់ស្តេចមល្លរាជដងទាំងឡាយមួយ អន្លើដោយអគ្គមហេសីបុត្រីបុត្រាប្រជាជន ដែលមាននៅក្នុងនគរកុសិនារារាជធានី ស៊ីងដំលើកដៃឡើងដាក់លើត្បូង ហើយគក់ទ្រូងទួញយំដំខរាងទៃ ។ គ្រប់គ្នាហាក់ហៀបនឹងក្ស័យជន្មាជីវិត ក្នុងគ្រានោះ ។

វិនោទេតា លុះបន្ទោរបង់នូវសេចក្តីទុក្ខសោកបរិទេវាតស្រាកស្រាន្ត ក្សាន្តក្នុងចិត្តហើយ ក៏រៀបនូវគ្រឿងសក្ការបូជាស្រេចហើយ ទើបលើកព្រះបរមសពអង្គសម្តេចព្រះសាស្តាចារ្យ បំពាក់នូវគ្រឿងលតាប្រសាទន៍ស្រេចហើយ ក៏កងព្រះមល្លសមាស ទាំប្រទក្សិណព្រះនគរកុសិនារានោះបាន ៣ ជុំហើយក៏នាំចេញទៅតាមទ្វារខាងកើតដាក់លើមកុដពន្ធន៍ចេតិយស្រេចហើយ ទើបយកសំពត់កោសេយ្យពស្ត្រ ៥០០ ត្បូងជ្រលក់គ្រឿងប្រេងគ្រប់ហើយក៏យកទៅពិទ្ធ អំពីក្រៅព្រះមល្លសមាសនោះហោង ។

មល្លរាជានោ ឱលោកេតា បពិត្រអើយ កាលគ្រានោះរីស្តេចមល្លរាជដ៏ជាធំក្រៃលែងនឹងអស់ស្តេចដងទាំងពួង បានពិចារណាស្វែងរកអាចារ្យធំទាំងតូចក្នុងព្រះនគរនោះ រកអាចារ្យឯណានឹងឲ្យចេះជាងអាចារ្យឈ្មោះ ទោណព្រាហ្មណ៍ នោះគ្មានឡើយ ។ ក្សិណណោះស្តេចមល្លរាជក៏យកអាចារ្យទោណព្រាហ្មណ៍នោះឯងជាធំ ជាអធិបតីហើយឲ្យទោណអាចារ្យ នាំព្រះបរមសពនៃសម្តេចព្រះសាស្តាចារ្យបាន៣ ជុំហើយ ដាក់តំកល់លើមកុដពន្ធនចេតិយ ដ៏

សោភា រួចនមស្ការថ្វាយបង្គំព្រះបរមសព ហើយថ្វាយព្រះភ្លើងតាមខ្លួន ហោរាសាស្ត្រនាគ្រានោះឯង ។

តថា កាលេ បពិត្រអើយ ក្នុងកាលនោះព្រះអគ្គីក៏មិនអាចនឹងឆាបឆេះព្រះមឈូសនៃព្រះបរមសពបានឡើយ ដោយហេតុនោះហើយ បានជាពួកមល្លរាជផងទាំងឡាយ អស់ទាំងអាណាប្រជានុរាស្ត្រនិងទោណអាចារ្យ បបួលគ្នាចូលទៅថ្វាយបង្គំសួរព្រះអរហន្តទាំង ៧ សែនអង្គ មានព្រះអនុរុទ្ធត្ថេរជាប្រធាន ដើម្បីឲ្យដឹងពតិមានដ៏ច្បាស់លាស់ដោយព្រះបន្ទូលថា ភន្តេ បពិត្រព្រះមហាថេរដ៏ប្រសើរអើយ ចុះហេតុអ្វីទៅអេះ បានជាភ្លើងមិនព្រមឆេះដូច្នេះ សូមអម្ចាស់ទ្រង់ពិចារណាមើល ?

អនុរុទ្ធត្ថេរោ តំ សុត្វា ព្រះមហាអនុរុទ្ធត្ថេរ កាលណាបើបានស្ដាប់ព្រះបន្ទូលអស់ស្ដេចមល្លរាជផងទាំងពួង នូវទោណអាចារ្យយកសេចក្ដីមកពិតទូលថេរដីកាដូច្នោះ វិចារេត្វា ទើបព្រះមហាថេរ ពិចារណារមិលមើលដោយនូវព្រះនេត្រទិព្វក៏ឃើញច្បាស់ជាក់ប្រាកដហើយទ្រង់មានថេរដីកាថា ៖បពិត្រមហារាជផងទាំងពួងអើយ បានជាអស់មហារាជទ្រង់បូជាព្រះបរមសពមិនឆេះដូច្នេះ ព្រោះអីមហាកស្សបត្ថេរជាសិស្សធំបង ព្រះអង្គមិនទាន់និមន្តមកដល់ ដើម្បីបានថ្វាយបង្គំដោយផ្ទាល់ចំពោះព្រះបរមសព បើដូច្នេះសូមមហារាជទ្រង់រង់ចាំសិន ដ្បិតព្រះមហាកស្សប នឹងនិមន្តមកដល់ក្នុងថ្ងៃស្អែកនេះឯង ។

តេន ខោ បនសមយេ អាយស្មា មហាកស្សបោ

**បាវានគរ ឧបនិស្សាយ** បពិត្រអើយ នាសម័យនោះឯង ព្រះមហាកស្សបត្ថេរ ទ្រង់គង់នៅឯបាវានគរ (១) ឯណោះ ពាវេតារ នា កាលព្រឹកព្រាងស្វាងព្រះសុរិយា ព្រះមហាថេរក៏ទ្រង់លីលាយាត្រាត្រាច់ទៅបិណ្ឌបាត្រ ធ្វើភត្តកិច្ចស្រេចកាលឯណោះហើយ ក៏នាំអស់ពួកភិក្ខុជាបរិវារទាំង៥០០ អង្គ និមន្តតាមដោយមាគ៌ា ភក្តាឆ្ពោះទៅកាន់ក្រុងកុសិនារា (២) ។ នាវេលាថ្ងៃត្រង់នោះ ក៏មានហេតុក្តៅប្លែកចំឡែកអស្ចារ្យ , មហាមេឃ ព្រមទាំងផែនពសុធា ឧបមាបីដូចជារងើករងើង អ្នកនឹងយាងយាត្រាដោយព្រះបាទាទៅក៏ពុំបាន បង្កើតឲ្យពុំក្សាន្តក្នុងព្រះកាយពល អ្នកក៏យល់ហេតុប្លែកចំឡែកមហិមា ទើបទ្រង់នាំអស់បរិវារចូលទៅឈប់សម្រាកនៅក្រោមម្លប់រុក្ខានាក្បែរផ្លូវ មួយអន្លើដោយភិក្ខុសង្ឃអង្គអរហន្ត ជាបរិវារ ។

---

១- បាវានគរនេះ នៅក្នុងដែនមល្លៈ ដូចនគរកុសិនារាដែរ ។ ដែនមល្លៈ កាលពីដើមមានទីក្រុងឈ្មោះ **កុសាវតី** ។ ក្រោយមកក្នុងសម័យពុទ្ធកាល ក៏បែកជាក្រុងធំ២ ជារាជធានីដូចគ្នា គឺក្រុងបាវា ១ ក្រុងកុសិនារា ១ ។ ព្រះពុទ្ធទ្រង់បរិនិព្វានក្នុងដែនមល្លៈខាងក្រុងកុសិនារា ។ ក្រុងទាំងពីរបានទទួលចំណែកព្រះធាតុស្មើគ្នា ។ ដែនបាវាសព្វថ្ងៃឈ្មោះថា **បទ្រូនៈ**

(២) ក្រុងកុសិនារានេះ នៅក្នុងដែនមល្លដូចក្រុងបាវាដែរ តែស្ថិតនៅខាងត្បូងក្រុងបាវា ។ កុសិនារា សព្វថ្ងៃហៅថា **កាសៀ**, ឯក្រុងបាវា សព្វថ្ងៃហៅថា **បទ្រូន** ។ ដែនមល្លនេះ សព្វថ្ងៃស្ថិតនៅក្នុងប្រទេស **នេប៉ាល** ។

តស្មឹ សមយេ អញ្ញតរោ អាជីវកោ នាកាលសម័យ ថ្ងៃនោះ អាជីវកម្នាក់មានឈ្មោះមិនប្រាកដ បានយកផ្កាមន្ទាបុស្សមកចងនឹងឈើច្រត់ធ្វើជាឆ័ត្រ ហើយគាត់កាំងដើរមក , ថេរោ តំ ទិស្វា ព្រះមហាកស្សបត្ថេរ កាលណាបើបានឃើញផ្កាមន្ទាបុស្សលើចុងឈើច្រត់អាជីវកដូច្នោះហើយ ក៏អ្នកវែងពិភាល់ក្នុងព្រះរាជហឫទ័យមហិមា នឹកដល់ទៅអង្គសម្តេចព្រះបរមជិនវង្ស ទ្រង់ចូលព្រះបរមនិព្វានហើយ ឬដូចម្តេចអេះ ទើបអ្នកមានថេរវាចាសួរដំណើរដំណឹង អំពីអង្គសម្តេចព្រះទ្រង់ញាណដោយសព្វគ្រប់ តំ សុត្វា អាជីវកោ រីឯអាជីវកកាលណាបើបានស្តាប់ ព្រះមហាកស្សបត្ថេរ ដំណឹងសួរដូច្នោះហើយក៏ឆ្លើយថា ឃើ ! ព្រះមហាកស្សបអើយ អ្នកទើបនឹងមកអំពីស្ថានឯណាក៏ពញាក់ពញើលលីលលើផ្ញើជាមិនដឹងមិនឮដូច្នេះហេះ អ្នកប្រាបទេ ? ឥឡូវនេះព្រះសមណគោតមបរមគ្រូរបស់អ្នក គាត់ក៏ចូលនិព្វានទៅ៧ថ្ងៃហើយ ។

តំ សុត្វា ថេរោ រីឯព្រះមហាកស្សបត្ថេរ មួយអន្លើនឹងអស់ព្រះខីណាស្រពផងទាំងឡាយ ទិមិត្តតែបានស្តាប់ៗ ពាក្យអាជីវកប្រាប់សព្វគ្រប់ដូច្នេះហើយ ក៏សឹងបង្កើតនូវសេចក្តីរំពេក ទុក្ខំ អនិច្ចំអនត្តា បណ្តាអស់ភិក្ខុបរិស័ទដ៏ជាបុថុជ្ជនផងទាំងឡាយនោះ សឹងដ៏មានចិត្តញាប់ញ័ររន្ធត់ស្លុតបាត់ស្មារតី ហាក់ហៀបទៀបនឹងបែកសព៌្ទកក្នុងព្រះឱរាទ្ទញថា ឱព្រះគុណអើយព្រះគុណ ខ្ញុំអត់តែពីថ្ងៃនេះទៅហើយ ក៏នឹងរកទីពឹងពុំនាក់ផងពុំនាក់នោះគ្មានឡើយ ។

តទា សុភទ្ទោ វ មហល្លបព្វជិតោ បពិត្រអើយ គ្រា
នោះ មានភិក្ខុចាស់១អង្គឈ្មោះសុភទ្ទភិក្ខុ បួសចាស់ហើយជាអ្នកអៀវស្រ ពុំ
យកជំហូន្មានឡើយ កាលបើគាត់យល់អស់ភិក្ខុផងទាំងឡាយ ទាំងពួងទួញយំស្រ
ណោះអាណោះអាល័យ ចំពោះព្រះចរមគ្រូដែលទ្រង់ចូលបរិនិព្វានដូច្នោះហើយ
ក៏ស្រដីថា អាវុសោ ម្នាលអ្នកទាំងឡាយអើយ កុំបីអ្នកសោក កុំបីអ្នក
យំពេកឡើយ អាវុសោអើយ វីយើងរាល់គ្នា តាំងតែអំពីថ្ងៃនេះទៅ
ហើយ ក៏វានឹងសប្បាយ នឹងលេងសើចតែរាល់គ្នា គ្មានអ្នកឯណា១ ក៏
នឹងខុសវិន័យត្រៃសិក្ខាអ្វីៗនោះគ្មានឡើយ ។ នាកាលព្រះសមណគោតម
គាត់គង់ធរមាននៅឡើយ គាត់តែងតែនឹងស្រដីហាមប្រាប់ថែ ៗ បន្តិចថាខុសនឹង
ក្រិត្យបន្ទាត់ បន្តិចថាខុសនឹងវិន័យត្រៃសិក្ខា លុះតែឱន ៗ លុត ៗ ក្រាប ៗ
នោះទើបត្រូវនឹងចិត្តគាត់ ។

ថេរោ តំ សុត្វា វីព្រះកស្សបត្ថេរ កាលណាបើអ្នកបាន
ស្តាប់ឮពាក្យ សុភទ្ទភិក្ខុស្រដីនូវពាក្យដាចម្រូងចម្រេះ នូវច្នោះហើយ អ្នក
ក៏គិតពិចារណាដល់ព្រះសាសនាអង្គសម្តេចព្រះត្រៃលោកនាថសាស្តាចារ្យថា ឱ!
ព្រះគុណអើយព្រះគុណ ព្រះអង្គទ្រង់ចាកចូលនិព្វានមិនបានប៉ុន្មានថ្ងៃប៉ុន្មានខែ
ផង គួរអីក៏មកមានផ្តើតមានពាក្យចម្រូងចម្រេះក្នុងព្រះសាសនាដូច្នេះ ? អ្នកក៏
នឹកអួលអន់ក្នុងព្រះទ័យហើយមា អ្នកខំលៃលោយ៉ាត្រានាំអស់ភិក្ខុបរិវារទាំងពួងនិមន្ត
ត្រឡប់ស្នាក់ចំពោះព្រះភគ្គទៅមកុដពន្ធនចេតិយ ជាទីដែលគេដុតល់ព្រះបរម

តបតនោះឯងហោង ។

បទក្ខិណំ កត្វា លុះដល់ហើយក៏អ្នកនាំអស់ភិក្ខុផងទាំងពួងប្រទក្សិណព្រះបរមសពដ៏ផាត្រូបាន ៣ ជុំស្រេចកាលណា ឱនមិត្វា ក៏ឱនសិរសាអញ្ជលីចូលទៅក្រាបថ្វាយបង្គំ ទមស្សការព្រះបរមសពអង្គសម្តេចព្រះបរមលោកនាថសាស្តាចារ្យ ទ្វេ បាទា បពិត្រអើយ រីព្រះបាទព្រះមហាករុណាទាំងគូនោះមិញ លេចចេញមកអំពីក្នុងព្រះមឈូសមាសដ៏ប្រសើរនោះមកដំកល់លើសិរសាព្រះមហាកស្សបត្ថេរនោះ ហាក់ដូចជាទ្រង់មានព្រះបន្ទូលផង នឹងព្រះមហាកស្សបត្ថេរ ពួដីជំនុំកណ្តាលចតុបរិស័ទទាំងពួង ទូះអស់មហាក្សត្រផងទាំងឡាយប្រាកដអស្ចារ្យមហិមា សឹងតែសរសើរបុណ្យព្រះមហាក្សត្រកស្សបត្ថេរថា ឱ ! ព្រះមហាកស្សបអើយ សម្តេចព្រះពុទ្ធអង្គទ្រង់មានមេត្តាករុណាព្រះមហាកស្សបនេះវែកចម្លែកក្រៃលែងនឹងអស់សាវ័ក - សាវិកាផងទាំងពួង ៗ ថេរោ ឯព្រះមហាកស្សបត្ថេរសោតក៏អ្នកក្រាបថ្វាយបង្គំទូលសរសើរព្រះគុណព្រះដ៏មានបុណ្យថា ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យព្រះគុណអើយ ព្រះអង្គតែងទ្រង់ជាប់ព្រះមេត្តាខ្ញុំព្រះករុណាកស្សបនេះជាដរាអ្នកឧស្សាហ៍ ខាងធុតង្គចំសុក្កូល ហេតុដូច្នោះបានជាព្រះអង្គស្តេចទ្រង់ព្រះមេត្តាប្រោសព្រះរាជទានចីវរល្អប្រសើរ ឲ្យខ្ញុំកស្សបនេះស្លៀកដណ្តប់ស្មើនឹងព្រះអង្គ ។ កស្សបត្ថេរអ្នកទូលរៀបរាប់សព្វគ្រប់ប្រការស្រេចកាលណាហោង ទ្វេ បាទា រីឯព្រះបាទទាំងគូនោះក៏លឹមចូលទៅក្នុងព្រះមឈូស

មាសនោះវិញទៅ នឹងរកស្នាកស្នាមប៉ុនចំរៀកសក់នោះក៏គ្មានឡើយ ។ បពិត្រអើយគ្រាគោរើងភ្លើងគេដោធាតុ ក៏បង្កើតឡើងនេះព្រះបរមសពនោះឯងប្រាកដហោង ។

បពិត្រអើយនេះនឹងសំដែងឯអស់ភិក្ខុ ភិក្ខុនី ដែលទៅជាបុថុជ្ជននូវអស់ទាំងទេវបុត្រ ទេវតា ទេពអប្សរបរិវារកញ្ញា ក្សត្រា ក្សត្រី នូវរាស្ត្រប្រជា សឹងតែទ្រហោស្រែកទួញយំផំផាំ ទឹកព្រះនេត្រហូរហៀរសស្រោកសស្រោកចាកកាយតែរាល់គ្នា នឹងរកទំនេរតែមួយនាក់ក៏គ្មានឡើយ សឹងតែសោកទួញថា ឱ ! ព្រះគុណអើយព្រះគុណ តាំងតែអំពីថ្ងៃនេះទៅហើយ យើងខ្ញុំទាំងពួងនឹងខានបានស្តាប់ព្រះធម្មវិសេសទេសនា ដ៏ហូរអំពីព្រះពុទ្ធឱស្ឋទិព្វថ្ងៃនោះហើយ ។

បច្ឆាកាលេ គ្រាកាលជាខាងក្រោយនោះ ព្រះមហាកស្សបត្ថេរនូវព្រះអនុរុទ្ធ និងព្រះមហាអានន្ទ និងទោណអាចារ្យជំនុំគិតចែកព្រះបរមសារីរិកធាតុទៅនគរទាំងប្រាំបី (១) ស្រេចហើយទើបព្រះមហាកស្សបត្ថេរអ្នកនឹកទៅពាក្យសុ

---

១– នគរទាំង៨ដែលបានទទួលចំណែកព្រះបរមសារីរិកធាតុនោះគឺ ១– នគររាជគ្រឹះ ដែនមគធៈ, ២– នគរវេសាលី ដែនវជ្ជី, ៣– នគរកបិលព័ស្តុ ដែនសក្ក, ៤– នគរអល្លកប្ប ដែនពូលិ, ៥– នគររាមគ្រាម ដែនកោលិយ, ៦– នគរនៃពួកព្រាហ្មណ៍នៅដែនវេដ្ឋទីបកៈ, ៧– នគរបាវា ដែនមល្ល. ៨– នគរកុសិនារា ដែនមល្ល ។ នគរទាំង ៨ នេះ បានព្រះសិរីរិកធាតុ ២ នាឡិដូចគ្នា ឯពួកក្សត្រមោរិយ; នៅបីប្ផលិវ័នដែលមកក្រោយគេ ក៏បានតែធ្យូងដែលរំលាយសពប៉ុណ្ណោះ ។

កទ្ធភិក្ខុ ដែលស្រដីថាចម្រូងចម្រះក្នុងព្រះពុទ្ធសាសនាហើយអ្នកមានថេរវាចា នឹងព្រះមហាថេរទាំងពួង មានព្រះមហាអនុរុទ្ធត្ថេរជាដើមជាប្រធាន អ្នកមានថេរវាចាថាអនុរុទ្ធអើយយើងនឹងគិតលើកបឋមសង្គាយនា រម្ងាប់ពាក្យមិច្ឆាទិដ្ឋិ អន្យតិរ្ថិយទិរ្ថិក បានម្តងហ្ន៎ ? ។ ព្រះអនុរុទ្ធត្ថេរព្រមគ្នា ទើបមហាកស្សបត្ថេរដ៏ជាសិស្សច្បង អ្នកជ្រើសរើសយកតែព្រះអរហន្តាខីណាស្រពឯណា ដែលបានបដិសម្ភិទាញាណបែកឈានក្នុងព្រះត្រៃបិដក គិតរើសបាន ៤៩៩ អង្គ ទុកឲ្យខ្វះ ១ អង្គ មិនទាន់រាប់បញ្ចូលក្នុងអរហត្តសុក្ខវិបស្សកនោះ មិនបានយកឡើយ ទើបអស់ព្រះភិក្ខុផងទាំងពួងជំនុំគ្នាថា ហេតុព្រះមហាកស្សបត្ថេរលោកពុំបានយកព្រះខីណាស្រពឲ្យពេញគ្រប់ទាំង ៥០០ អង្គតែម្តងឲ្យខ្វះដូច្នេះ ព្រោះគ្មានព្រះខីណាស្រពត្រាស់ដឹងក្នុងល្បែងព្រះត្រៃបិដកឬដូចម្តេច ? វិសជ្ជនាឆ្លើយថា ហៃអស់លោកទាំងពួងអើយ រីព្រះខីណាស្រពលោកឆ្លាយក្នុងល្បែងព្រះត្រៃបិដក នោះក៏ច្រើនណាស់ នឹងរើសមិនអស់ទេ បានជាព្រះមហាកស្សបត្ថេរលោកមិនបានរើសយកឲ្យគ្រប់ហើយខ្វះដូច្នេះ ព្រោះដ្បិតគិតនឹកព្រះមហាអានន្ទឲ្យចូល ផង បើនឹងរាប់បញ្ចូលតែម្តង ដ្បិតព្រះមហាអានន្ទនេះទៅជាសេក្ខបុគ្គលយល់ថា នឹងកើតមានពាក្យធំធៀលធៀលថា ព្រះមហាកស្សបត្ថេរនេះអ្នកជ្រើសរើសយកតែដោយនូវយល់ថា ដ្បិតព្រះមហាអានន្ទនេះ ជាព្រះអនុជនៃព្រះបរមលោកនាថសាស្តាចារ្យ ប្រការមួយវិញទៀតថា បើព្រះមហាកស្សបត្ថេរអ្នកមិន បានយកព្រះមហាអានន្ទចូលផងឡើយ ក៏នឹងធ្វើបឋមសង្គាយនានោះ មិនបាន

គើតនេះ ម៉្យាងព្រះមហាអានន្ទជាអ្នកតែងនិងដើរតាមព្រះបិដិ (ខ្នង) នៃអង្គសម្ដេច ព្រះទ្រង់យស ម៉ើទ្រង់ចំរើនពុះយាងទៅទីស្ថានឯណា ៗ ក៏ព្រះមហាអានន្ទអ្នកតែង ដើរបិណ្ឌបាត្រតាមទៅទីនោះៗ ពុំដែលឃ្លាតឆ្ងាយពីព្រះអង្គកាយ បីដូចស្រមោល តែងតាមនិតមិនដែលឃ្លាតឡើយ បើព្រះអង្គទ្រង់សំដែងថ្លែងព្រះធម្មវិសេស ទេសនា ប្រោសមនុស្សសត្វទេពតា ទ្រង់សម្ដែងគម្ពីរណាៗ ព្រះអានន្ទអ្នកក៏ ចាំព្រះគម្ពីរអត្ថគាថាកាថាធម៌ទាំងពួងខ្ជាប់ពុំមានភ្លេចឡើយ ហេតុនោះទើបសម្ដេច ព្រះបរមគ្រូជាអម្ចាស់ទ្រង់លើកជាឃ្លាំងធម៌ហោង ។

តតោ មុ: តទុទ្ទនុំ លំដាប់នោះព្រះមហាកស្សបត្ថេរ អ្នកប្រជុំអស់ ពួកព្រះខីណាស្រពផងទាំងពួងបាន ៤៩៩ អង្គនោះ ចូលទៅកាន់នគររាជគ្រឹះ ប្រយោជន៍ដើម្បីនឹងធ្វើបឋមសង្គាយនា ដ្បិតនគររាជគ្រឹះនោះធំហើយប្រកបនឹង ទេ[illegible]កាជនាហារនោះច្រើន ល្មមនឹងធ្វើបឋមសង្គាយនាបាន ។

រាជគហានគរំ បត្តោ និមិត្តតែបានទៅដល់នគររាជគ្រឹះកាលឯណាហើយ , ព្រះមហាកស្សបត្ថេរ អ្នកប្រើមហាថេរដទៃឲ្យចូលទៅថ្វាយព្រះពរបិណ្ឌបាតបាត្តកម្ម

អំពីព្រះបាទអជាតសត្រូវ(១) ទីឯឲ្យរុះផុលនូវព្រះវិហារទាំង ៨ ហើយនិងឲ្យធ្វើនូវមហាមេរុបជាថ្មី ១ ដើម្បីធ្វើសង្គាយនាបានតាប់ៗ ។ រាជា តំ សុត្វា បពិត្រអើយ រីព្រះបាទអជាតសត្រូវ កាលណាបើបានស្ដាប់ថេរវាចានៃព្រះមហាថេរទាំងពួងស្រេចកាលណា ក៏ព្រះបរមក្សត្រ ស្ដេចពិតថេរវាចានិងព្រះមហាថេរថាបពិត្រអម្ចាស់ទាំងពួងអើយ អម្ចាស់កុំព្រួយព្រះរាជហឫទ័យឡើយ ខ្ញុំព្រះករុណាជាញោមនឹងធ្វើមណ្ឌបប្រគេន ប្រការ ១ សោត ខាងឯពុទ្ធចក្រធុរៈនោះ មានលោកម្ចាស់ដ៏ចំរើន ខាងឯអាណាចក្រ ធុរៈនោះមានខ្ញុំព្រះករុណាជាញោមហើយ បពិត្រជីតុនអើយ ឯមហាមណ្ឌបនោះ តើនឹងចង់ឲ្យធ្វើនៅទីស្ថានឯណា ? ទ្វារសត្តបណ្ណគុហា ព្រះមហាថេរទាំងពួងថ្វាយព្រះពរថា បពិត្រព្រះមហារាជអើយ សូមមហាបពិត្រធ្វើនៅទៀបទ្វារសត្តបណ្ណគុហាបព៌តជាទីសមគួរ ។

---

១– ព្រះបាទអជាតសត្រូវជារាជបុត្រនៃព្រះបាទពិម្ពិសារ និងនាងទេវេហី ។ ក្សត្រអង្គនេះ បានធ្វើឃាតព្រះបាទពិម្ពិសារជាព្រះបិតាយករាជ្យសោយនៅឆ្នាំទី បាពនាសម័យពុទ្ធកាល, សោយរាជ្យបាន ៨ ឆ្នាំ ទើបព្រះពុទ្ធបរិនិព្វាន ។ ព្រះបាទអជាតសត្រូវ ត្រូវធ្លាក់ទៅនរកអវិចី តែក្រោយសម្លាប់បិតាហើយ ក៏ដល់នូវត្រៃសរណគមន៍ស្មើជីវិត ហើយបានឧបត្ថម្ភ ក្នុងការធ្វើបឋមសង្គាយនានេះផង ក៏ធ្លាក់ទៅត្រឹមតែលោហកុម្ភីនរកប៉ុណ្ណោះ ។ ព្រះបាទអជាតសត្រូវទ្រង់សោយរាជ្យនៅដែនមគធៈនេះបាន ៣២ ឆ្នាំ ក៏ត្រូវរាជបុត្រព្រះអង្គនាម **ឧទយភទ្ទ** ធ្វើឃាតយករាជសោយទៀត ។

លុះព្រះមហាថេរថ្វាយព្រះពរស្រេចហើយ បច្ឆា កាលេ រាជា បពិត្រ អើយក្រោយនោះ ព្រះបាទអជាតសត្រូវស្តេចមានព្រះបន្ទូលត្រាស់បង្គាប់ទៅលើអស់ទាំងចតុស្តម្ភក្រមសេនាមាត្យយោធាធំ - តូច ឲ្យទៅនាំយកឈើ រើសយកឈើណាមានខ្លឹមល្អ ៗ ឯផាប់ស្រាយនោះមិនយកឡើយ ហើយទើបស្តេចឲ្យជ្រើសរើសយកតែនាយជាងធំៗយ៉ាងឯក ៗ ចេះការនោះប្លែកចម្លែកអស្ចារ្យ នឹងអស់ជាងទាំងពួងនោះបាន ៥០០ ឲ្យប្រុងប្រៀបរៀបមណ្ឌបគ្រប់គ្រឿងយ៉ាងល្អឯក ចម្លែកប្លែកនឹងអស់មណ្ឌបក្នុងដែនដីអាយនេះគ្មានឡើយ មានតែមណ្ឌបនៅស្ថានសួគ៌នោះទើបនឹងប្រៀបស្មើបាន ស្តេចឲ្យតែងគ្រប់ប្រការមាននូវគ្រែធម្មាទាំង ៣ នោះល្អវិចិត្របិតសិងតែមាស មិនតែប៉ុណ្ណោះឡើយ ហើយស្តេចឲ្យតែនូវផ្តិតវាលវិជនីទ្រង់ចាម៉រ ដកភ្ញកម័សស្អាតប្រដាប់សម្រាប់គ្រែទាំងបី ហើយស្តេចឲ្យផ្គូសជុលព្រះវិហារទាំង ៨ ស្រេចហើយស្តេចឲ្យចាត់ចែងភោជនាហារទាំងពួងគ្រប់សព្វប្រការ ។

មណ្ឌបវសានេ នាកាលធ្វើមណ្ឌបស្រេចហើយ ទើបសម្តេចព្រះបរមក្សត្រាធិរាជ ស្តេចទ្រង់ត្រាសប្រើអាមាត្យឲ្យទៅពិតថេរវាចាព្រះមហាកស្សបៈត្ថេរ អារាធនានិមន្ត ធ្វើបឋមសង្គាយនាតាមសព្វព្រះរាជហឫទ័យ ។ ថេរោ រីព្រះមហាកស្សបត្ថេរ អ្នកក៏បានស្តាប់ពាក្យរាជអាមាត្យអារាធនានិមន្តដូច្នោះហើយ ក៏ប្រាប់អស់ដំគុំសង្ឃផងទាំងពួងថានឹងធ្វើសង្គាយនាក្នុងថ្ងៃស្អែកនេះឯង ។

**អានន្ទត្ថេរោ** បពិត្រអើយនឹងសំដែងថ្លែងអំពីព្រះមហាអានន្ទត្ថេរកាលក្រោយគ្រានោះ ព្រះមហាអានន្ទទៅកាន់ជំនុំសង្ឃ អ្នកក៏បង្កើតសេចក្តីទោមនស្សអួលអល់តាន់តឹងក្នុងព្រះឱរាក្រៀមក្រមស្ងប់ស្ងៀមស្ងូត គ្រាហ្នាអ្នកក៏ចាយកត្រៃចីវរនៃអង្គសម្តេចព្រះបរមសាស្តាចារ្យ ទឹកព្រះនេត្រាហូរស្រក់ អ្នកក៏ខំយាងយាត្រានាំអស់ទាំងភិក្ខុសង្ឃជាបរិវារព្រះកន្លោះទៅកាន់នគរសាវត្ថី ។

**តទា មហាជនោ** គ្រានោះ រីបណ្តាអស់មហាជនផងក្នុងក្រុងសាវត្ថីទាំងប្រុសស្រី កាលបើបានឃើញព្រះមហាអានន្ទត្ថេរ អ្នកក៏ចាប់យកនូវត្រៃចីវរនៃអង្គសម្តេចព្រះបរមគ្រូត្រៃលោកនាថសាស្តាចារ្យមកដូច្នេះហើយ ក៏សឹងតែដណ្តឹងសួររកអង្គសម្តេចព្រះជិនស្រីជាអម្ចាស់ដ្បិតសព្វដងសព្វគ្រារៀងមក តែងបានឃើញព្រះមហាអានន្ទត្ថេរហើយ ក៏បានឃើញអង្គព្រះវិជិតមារផង គ្រានេះក៏ឃើញតែអ្នកអានន្ទតែម្នាក់ឯង រីអង្គសម្តេចព្រះបរមលោកនាថសាស្តាចារ្យនោះតើព្រះអង្គស្តេចយាងទៅទីស្ថានឯណា ?

**ថេរោ តំ សុត្វា** រីព្រះមហាអានន្ទត្ថេរ **កាលណាបើបានស្តាប់**អស់ពាក្យមហាជនផងទាំងពួងសួរដូច្នោះហើយ ទើបមានថេរវាចាប្រាប់រៀបរាប់សព្វគ្រប់ប្រការ ។ **បរិទេវមានា** បពិត្រអើយ រីអស់មហាជនផងទាំងពួងនោះ កាលបើបានស្តាប់ថេរវាចាព្រះមហាអានន្ទត្ថេរអ្នកប្រាប់ថា សម្តេចព្រះបរមសាស្តាចរិយាញាណ **ទ្រង់ចូលនិព្វានដូច្នោះហើយ ក៏អ្នកទឹងទប់ទល់**

ដីកល់អាត្មាពុំបានឡើយ សឹងតែប្រាសប្រាណនៀលទួញយំដំឱរ៉ា ទឹកនេត្រា ក៏ហូរសស្រាក់សស្រាក់រីយោគសោកសោយ នឹងរកឲ្យមានទំនេរដល់ម្នាក់នោះ គ្មានឡើយ សឹងតែមានសេចក្ដីទុក្ខសោកនោះមហិមាដោយសងខាងមាតា ព្រះមហាអានន្ទត្ថេរអ្នកយាត្រាទៅដល់ត្រង់ទីស្ថានឯណា ក៏ទួញយំត្រង់ទីស្ថាននោះ រីសព្វទំនួញទួញយំនោះឮកងរំពងមហិមា ស្ទើរក្លុកផែនឆសុធា ដោយសងខាងមាតាខ្លះក៏ទួញថា **អយ្យា អានន្ទ** បពិត្រព្រះមហាអានន្ទអម្ចាស់អើយអ្នកកុំយកអង្គសម្ដេចព្រះសាស្ដាចរិយាញាណជាអម្ចាស់នោះ ទៅទុកត្រង់ទីស្ថានឯណារកមិនឃើញ អ្នកយកព្រះអង្គមកផងណាអម្ចាស់ ឱព្រះអម្ចាស់អើយ ញោមបានធ្លាប់ឃើញលោកម្ចាស់ ក៏បានឃើញសម្ដេចព្រះពុទ្ធអង្គជាអម្ចាស់ផង ឱ៎ះ ឱព្រះគុណអើយព្រះគុណ ម្ដងនេះ ខ្ញុំពុំបានឃើញព្រះគុណដ៏ជាអម្ចាស់ដូច្នោះខ្ញុំនេះធ្លាប់តែងធ្វើវត្តប្រតិបត្តិនមស្សការ ស្ដាប់ព្រះធម៌វិសេសទេសនា ដ៏ហូរចេញអំពីព្រះពុទ្ធឱស្ឋទិព្វថ្ងៃនោះពីរោះមហិមា ។

**ថេរោ ជេតវនេ អនុប្បត្តោ** នាកាលព្រះមហាអានន្ទត្ថេរអ្នកពីលាយាត្រាបានដល់ជេតពនមហាវិហារកាលណាហើយ បពិត្រអើយរីអស់ទេវបុត្ត ទេវតា ទាំងអស់មនុស្សប្រុសស្រី ចាស់ទុំក្រមុំកម្លោះមេម៉ាយពោះម៉ាយផងទាំងឡាយ ដែលធ្លាប់ជាអ្នកឧបដ្ឋាកនៃព្រះពុទ្ធអង្គជាអម្ចាស់កាលទ្រង់គង់ធរមាននៅឡើយ នោះក៏សឹងតែទួញយំសោយសោកស្រណោកអាឡោះ

អាល័យ ហាក់បីដូចជាហៀបនឹងក្ស័យជីវិតជន្មាតែគ្រប់ ៗគ្នា ផ្ងាប់វែង ប្រណិប័តន៍សព្វថ្ងៃ សព្វវេលា ទួញយំសោកថា ឱ ឱព្រះគុណអើយ ព្រះគុណ មិនដឹងជាដល់ម្ល៉េះទេណា យើងខ្ញុំទាំងពួងរាល់គ្នា គិតស្មាន ថាអម្ចាស់គង់ធម្មា មានព្រះជន្មនៅវែងទៅ ឥឡូវនេះមកនិព្វានឆាប់អ្វី មាល្បាយដល់ម្ល៉េះ យើងខ្ញុំធ្លាប់ឃើញព្រះអង្គជាម្ចាស់ឥតអាក់ ឥឡូវនេះ ឃើញតែព្រះមហាអានន្ទតែម្នាក់ឯង ។

បពិត្រអើយ ព្រះមហាអានន្ទត្រូវអ្នកយល់សេចក្ដីទុក្ខមកបង្កើតច្រើន ចំពោះមហាជនផងដូច្នោះហើយ ទើបអ្នកសំដែងក្នុងគម្ពីរអធិច្ឆលគុណៈសូត្រ រំលត់នូវសេចក្ដីទុក្ខសោកនៃអស់មហាជនផងទាំងឡាយ ទាំងពួងហើយអ្នកចូល ទៅក្នុងសុគន្ធកុដិ ដែលអង្គសម្ដេចព្រះជិនស្រីទ្រង់គង់អំពីដើម ។ មញ្ចបី ថាទីបដិសារមេត្តា អ្នករៀបក្រែនូវតាំងបោសពោះកៀរអស់សម្រាមផុយផង់ ធុលីគ្រៀម ៗ នោះហើយ ព្រះមហាអានន្ទត្រូវអ្នកតាំងធ្វើវត្តប្រតិបត្តិដូចកាល អង្គសម្ដេចព្រះជិនវង្ស ស្ដេចគង់ព្រះជន្មនៅ មានប្រការដូចម្ដេចមិញ ក៏ ព្រះមហាអានន្ទអ្នកធ្វើដូច្នោះ លុះរៀបសព្វគ្រប់ប្រការហើយ អ្នកក៏ថយចេញ មកអំពីទីនោះ រួចឈរវន្ទាយកវត្តប្រតិបត្តិ ដូចកាលព្រះអង្គគង់ព្រះជន្មនៅ ឡើយ ។

បពិត្រអើយ នាកាលថ្ងៃនោះព្រះមហាអានន្ទ អ្នកស្រមៃហាក់ដូចជា សម្ដេចព្រះពុទ្ធអង្គទ្រង់ឈរចំពោះមុខនោះ អ្នកក៏បង្អើលឡើង [illegible]

ក៏បាត់មិនឃើញឡើយ ម៉្លោះហើយអ្នកក៏ទប់ទល់ដំកល់ព្រះស្មារតីនោះក៏ពុំបាន ប្រះប្រាណរំទូញទ្រង់ព្រះកន្សែងសោកាថា ឱ៎ះ ឱ អនិច្ចាព្រះគុណអើយព្រះគុណ ខ្ញុំព្រះករុណានេះ ស្រមៃឃើញហាក់ដូចជាអង្គសម្ដេចព្រះរៀមគង់នៅដូចសព្វដង រៀងមក ។ អ្នកក៏ទូញយំរកអង្គសម្ដេចព្រះសាស្ដា ការនឹងក្នុងឧរាដូលអាក់ ទឹកនេត្រហូរស្រស្រាក់សរស្រោកលើពសុធា ព្រះអង្គអ្នកនោះញ័រចំប្រប់ ហាក់ដូចជាសន្ទប់កាលគ្រានោះឯង ។

ឯកា ទេវតា គ្រានោះមានទេវតា ១ អង្គ ទិស្វា លុះបានឃើញព្រះមហាអានន្ទ អ្នកកើតមានសេចក្ដីទុក្ខសោកខ្លាំងមហិមាដូច្នោះហើយ ក៏មានថេរវាចាថា អយ្យា អានន្ទ បពិត្រព្រះមហាអានន្ទដ៏ចំរើនអើយ ហេតុអ្វីក៏អ្នកទូញសោយសោកសង្រេងសង្រៃងដូច្នេះ ឱព្រះអានន្ទអើយខ្ញុំគិតថាអ្នកចេះជ្រៅជ្រះច្រើន តែងនឹងសំដែងព្រះធម៌វិសេសទេសនារម្ងាប់នូវសេចក្ដីទុក្ខសោកអស់ទេវៃទៅរាល់គ្នា ឯព្រះអង្គឯងក៏មិនចេះពិចារណាឲ្យឃើញក្នុងសេចក្ដីទុក្ខំ អនិច្ចំ អនត្តា ឲ្យជាក់ច្បាស់ប្រាកដទេ ឬក៏ចេះតែយំចេះតែសោកដូច្នេះ ?

តំ វចនំ សុត្វា ថេរោ បពិត្រអើយ រីព្រះមហាអានន្ទត្ថេរ កាលណាបើអ្នកបានឮវាចានៃទេវតាថាដូច្នោះហើយ អ្នកក៏អើយងើបឡើង ខំទប់ព្រះអង្គបន្ទោរបង់នូវសេចក្ដីទុក្ខសោកនោះ គ្រាន់ស្រាកស្រាន្តស្រាលស្រយាលក្នុងនាំ អ្នកក៏មកទ្រង់ពិចារណាក្នុងព្រះត្រៃលក្ខណៈញាណ។ អញ្ញតរោ ថេរោ បពិត្រអើយគ្រានោះ មានព្រះមហាថេរដទៃ ១ រូប កាលណាបើបានឃើញ

ព្រះមហាអានន្ទត្ថេរ អ្នកនឹងសញ្ចប់សុបសៅព្រះភក្ត្រាដូច្នោះ ទើបអ្នកមានថេរវាចាដាស់តឿនថា អានន្ទអើយថ្ងៃស្អែកនេះហើយ ព្រះមហាកស្សបត្ថេរលោកនឹងចូលបណ្ណាបថ្មី ដ្បិតសម្តេចព្រះជិនស្រីទ្រង់ទំនាយថា អ្នកនេះនឹងបានសម្រេចព្រះធម៌វិសេសក្នុងគ្រានោះឯងហើយ អានន្ទអើយចូរខំសំណាក់ព្រះធម៌ហោង ។

ថេរោ តំ សុត្វា ព្រះមហាអានន្ទត្ថេរ អ្នកក៏បានស្តាប់ថេរវាចាព្រះមហាថេរនោះហើយ ក៏អ្នកលីលាចេញទៅកាន់ស្ថានស្ងាត់ ហើយអ្នកផ្តត់ព្រះភ្នែនពែនព្រះបាទ តាំងព្រះទ័យស្អាតក្នុងព្រះកាយា ខំឧស្សាហ៍ចំរើនព្រះកម្មដ្ឋាន ក៏មិនបានសម្រេចក្នុងបឋមយាមនោះ លុះដល់បច្ឆិមយាម អ្នកក៏គិតពិចារណានឹកដល់ពុទ្ធគុណថា ឱព្រះគុណថ្លៃវិសេសខ្ញុំអើយព្រះអង្គទ្រង់ទាយខ្ញុំអានន្ទថា នឹងបានសំរេចព្រះធម៌វិសេសក្នុងគ្រានេះឥឡូវនេះ ខ្ញុំអានន្ទខំដល់ម្លេះ ក៏មិនបានសំរេចក្នុងបច្ឆិមយាមឡើយ ។

**មច្ឆិមយាមវសានេ** នាកាលទីបំផុតនៃបច្ឆិមយាមនោះវិញ អ្នកគិតពិចារណាថា ឱអាត្មាអញអើយប្រឹងធ្វើព្យាយាមនេះតឹងណាស់ម្លេះ ក៏មិនបានសម្រេចព្រះធម៌ដូច្នេះ អ្នកគិតដូច្នោះហើយ ក៏ប្រែផ្ទៀងផ្ទាត់ប្រយោជន៍ ដើម្បីនឹងទំរេតព្រះកាយ ព្រះកេសពុំទាន់ដល់ខ្នើយនៅឡើយ អ្នកក៏បានដល់ព្រះអរហត្តកំចាត់បង់នូវកិលេសក្នុងខន្ធសន្តានបាន ព្រមទាំងបដិសម្ភិទាញាណ ដែលឈានក្នុងព្រះត្រៃបិដកកាលគ្រានោះឯងហោង ។ ទើបមានពាក្យបុច្ឆាចោទថា

ភោ តុម្ហេ បពិត្រលោកទាំងពួងអើយ ព្រះអានន្ទត្ថេរអ្នកបាន សម្រេចព្រះអរហត្តទេ៖ ក៏ប្រែកម្មែកនឹងអស់ព្រះខីណាស្រពផងទាំងពួង ឯអស់លោកផងថាបើនឹងបានសម្រេចព្រះអរហត្ត ក៏បានដោយនូវឥរិយាបថទាំង ៤ ខ្លះក៏បានក្នុងឥរិយាបថដេក, ខ្លះក៏បានដោយនូវឥរិយាបថដើរ, ខ្លះក៏បានដោយនូវឥរិយាបថឈរ ខ្លះក៏បានដោយនូវឥរិយាបថអង្គុយទាំង ៤ ប្រការ ហេតុដូច្នេះបានជាយើងមានសេចក្តីសង្ស័យ ។ ទើបមានពាក្យវិសជ្ជនាឆ្លើយថា ភោន្តោ បពិត្រអស់លោកទាំងពួងដ៏ចំរើនអើយ ព្រះមហាអានន្ទនេះ បានសម្រេចព្រះអរហត្តផលអស្ចារ្យដាច់នោះ ទើបអស់សាវកផងទាំងពួង បើលុះដល់នឹងចូលព្រះនិព្វានសោត ក៏អណ្តែតឡើងទៅកណ្តាលអាកាស តេជោធាតុបក់ឡើងទៅលើម្ចាយព្រះសព ទើបវាយោធាតុបក់ញែកចែក ព្រះធាតុនោះធ្លាក់ចុះ មកជាពីរផ្នែក បានទៅព្រះញាតិហើយត្រើយស្ទឹងទាំងសងខាងក៏មិនមានចិត្តវិវាទគ្រប់គ្នា ហេតុប្រការដូច្នេះ ទើបសម្តេចព្រះទ្រង់យសទ្រង់ចំពោះលើកឡើងនាឯក ខាងឯបិដកទាំង ៣ ។

បញ្ចសមយោ • នាកាលព្រឹកព្រាងស្វាងព្រះសុរិយារះច្បាស់ឡើង កាលណា ថេរោ វិព្រះមហាអានន្ទត្ថេរ ចិន្តេសិ អ្នកគិតគិតពិចារណាថា នុខោ ដូចអញគិតនេះហើយ ឥឡូវនេះអាត្មាក៏បានសម្រេចដល់ព្រះអរហត្ត ហើយក៏នឹងទៅកាន់ជំនុំសង្ឃនោះ អាត្មានឹង[illegible]ទៅ

ដោយអាកាសវេហាស៍នោះ ក៏សមនឹងរំលងអស់ព្រះខីណាស្រពផងទាំងពួង ដែលលោកបានព្រះអរហត្តចាស់ជាងអាត្មា ហើយក៏ចុះនៅនាកណ្ដាលជំនុំសង្ឃ ឲ្យជាអស្ចារ្យ ឰដ៏កណ្ដាលពួកព្រះខីណាស្រពផងទាំងពួងនេះក៏បានហោង ប៉ុន្តែ អាត្មានេះក៏មានទោសច្រើនប្រការ ព្រោះអាត្មានេះ ទើបនឹងសម្រេចអរហត្តថ្មីជាង អស់ព្រះខីណាស្រពទាំងពួង មួយវិញទៀត បើអាត្មានឹងលើលោយាត្រាដើរ ទៅក៏បាន តែនឹងកើតមានសេចក្ដីសង្ស័យដល់អស់ជំនុំសង្ឃថា អាត្មានេះមិន ទាន់បានសម្រេចអរហត្តទេតើឯបានដើរត្រលប់មកដូច្នេះ ? បើដូច្នោះ គួរតែ អាត្មានេះនឹងមុជប្រែកក្រឡាមហាប្រថពី ដោយនូវឫទ្ធិអំណាចអានុភាពទេស្ដា ភក្ត្រាចំពោះទៅកាន់ជំនុំសង្ឃ ហើយក៏នឹងឡើងគង់លើគ្រែធម្មាសនាជាអស្ចារ្យ ឰដ៏កណ្ដាលជំនុំពួកខីណាស្រពផងៗ សឹងតែសរសើរឲ្យសព្វសាធុការពរថា អើ ព្រះមហាអានន្ទ អ្នកមកដល់ហើយ ។

តតោ នោះ តទនន្តរំ លំដាប់នោះ កស្សបត្ថេរោ បពិត្រអើយព្រះ មហាកស្សបត្ថេរ អ្នកមានថេរវាចាសួរអស់មហាថេរផងទាំងពួងថា អាវុសោ ម្នាលលោកទាំងពួងអើយ ឥឡូវយើងគិតនឹងធ្វើសង្គាយនាបិដកណាមុន ? តំសុត្វា បណ្ដាអស់ព្រះខីណាស្រពផងទាំងពួង បានស្ដាប់ហើយក៏ឆ្លើយថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបដ៏ប្រសើរអើយ វិនយោ នាម រីព្រះវិន័យបិដក

នេះ សម្ដេចព្រះពុទ្ធអង្គជាអម្ចាស់ ទ្រង់ត្រាស់សំដែងទុកថា ជាឫសគល់នៃព្រះសាសនា ថាបើព្រះវិន័យនេះស្ថិតនៅដរាបណា ក៏ព្រះពុទ្ធសាសនាស្ថិតនៅត្រឹមនោះ ហេតុដូច្នេះយើងនឹងធ្វើសង្គាយនាព្រះវិន័យនេះជាមុន តំផុរំ កតានិ ព្រះមហាកស្សបត្ថេរអ្នកដណ្ដឹងទៅវិញទៀតថា អើ រីព្រះវិន័យបិដកនោះ តើយើងទុកធុរៈទៅលើភិក្ខុឯណាហៈ ? ព្រះមហាថេរទាំងពួងក៏ឆ្លើយថា អាយស្មន្តំ ឧបលឹ ភន្តេកស្សប បពិត្រព្រះអរិយកស្សបដ៏ប្រសើរអើយ រីព្រះវិន័យបិដកនោះធុរៈនៅលើព្រះឧបាលិត្ថេរ, កឹ អានន្ទោ នប្បហោតិ រីព្រះមហាអានន្ទ និងសំដែងមិនបានឬដូចម្ដេច ? នោបហោតិ ព្រះមហាថេរទាំងពួងឆ្លើយថា ព្រះមហាអានន្ទមិនគួរនឹងសំដែងឡើយ ដ្បិតសម្ដេចព្រះពុទ្ធអង្គកាលគង់ព្រះជន្មនៅ ទ្រង់លើកព្រះឧបាលិកជាឯតទគ្គខាងឯព្រះវិន័យបិដក ហេតុដូច្នោះយើងនឹងគួរដណ្ដឹងសួរព្រះឧបាលិក្នុងគម្ពីរព្រះវិន័យបិដកក្នុងកាលត្រាឥឡូវនេះ ។

តតោ ថេរោ វិនយំ បុច្ឆិត្វា រីព្រះមហាកស្សបត្ថេរ កាលណាបើបានស្ដាប់ថេរវាចារបស់មហាថេរផងទាំងពួងដូច្នោះហើយ ក៏សព្វព្រះទ័យទទួលជាអ្នកដណ្ដឹងគម្ពីរព្រះវិន័យនឹងព្រះមហាឧបាលិ ឯព្រះមហាឧបាលិក៏ទទួលវិសជ្ជនាឆ្លើយព្រះវិន័យបិដក ឯព្រះមហាអានន្ទត្ថេរ ជាអ្នកឃ្លាំងធម៌ ក៏ទទួលធុរៈជាអ្នកសំដែងគម្ពីរព្រះសូត្របិដក និងព្រះអភិធម្មបិដកនោះហោង ។

អថខោ អាយស្មា មហាកស្សបោ សង្ឃញ្ញាបេសិ

លំដាប់នោះព្រះមហាកស្សបត្ថេរធំមានអាយុ ជាសង្ឃចាស់វស្សា អ្នកក៏ប្រកាសនឹងអស់ជំនុំសង្ឃផងទាំងពួងថា សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ ឧបាលឹ វិនយំ បុច្ឆេយ្យំ អាវុសោ ម្នាលអ្នកទាំងឡាយអើយ សង្ឃោ បណ្តាជាសង្ឃ សុណាតុ ចូរស្តាប់ វចនំ នូវពាក្យ មេ នៃអញខ្ញុំ យទិ ថាបើ បត្តកល្លំ ជាកាលគួរ សង្ឃស្ស ដល់អស់ជំនុំសង្ឃ អហំ រីអញខ្ញុំ វិនយំ បុច្ឆេយ្យំ ក៏នឹងដណ្តឹងសួរនូវព្រះវិន័យ ឧបាលឹ នឹងព្រះឧបាលិ ។

នាកាលបើអ្នកប្រកាសនឹងអស់ជំនុំសង្ឃស្រេចហើយ ក៏ប្រែព្រះអង្គឡើងគង់លើព្រៃធម្មាសនៈដ៏ប្រសើរ ក្នុងគ្រានោះហោង ។

# បឋមសង្គាយនាត្រៃបិ

## ព្រះមហាកស្សបត្ថេរចោទសួរ
## ព្រះវិន័យនិងព្រះឧបាលិត្ថេរ
## ព្រះឧបាលិត្ថេរ ឆ្លើយព្រះវិន័យ
## និងព្រះមហាកស្សបត្ថេរ

---

### ព្រះមហាកស្សបត្ថេរ ផ្ដើមសេចក្ដី

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

តតោ ថេរា អាយស្មា មហាកស្សបោ ថេរាសនេ និសីទិត្វា អាយស្មន្តំ ឧបាលិ វិនយំ បុច្ឆតិ លំដាប់នោះ ព្រះមហាកស្សបត្ថេរដ៏មានអាយុ កាលណាបើអ្នកឡើងគង់លើអាសនៈស្រេចកាលឯណាហើយ ក៏អ្នកដណ្ដឹងសួរនូវព្រះវិន័យបិដកនឹងព្រះឧបាលិត្ថេរថា.

បុច្ឆា ១- វិនយំ កតិកប្បមាណំ អាវុសោ ហៃអាវុសោ ឧបាលិត្ថេរដ៏ចំរើន មានអាយុផ្នួសយើនយូរអើយ អ្នកតើយវិព្រវិន័យមិដកនោះ តើសម្ដេចព្រះអនាវរណញ្ញាណ ជាអម្ចាស់ មានព្រះពុទ្ធដីកាត្រាស់ថា មានប៉ុន្មានគម្ពីរហេៈអ្នក ?

## ព្រះឧបាលិត្ថេរប្រកាសសេចក្តី

អាយស្មា ឧបាលិ សង្ឃញាបេសិ ឮដំគ្រានោះព្រះមហាឧបាលិត្ថេរ អ្នកប្រកាសអស់ផងនុំសង្ឃ ដោយពាក្យថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មា មហាកស្សបេន វិនយំ បុដ្ឋោ វិស្សជ្ជេយ្យំ ។ ភន្តេ បពិត្រលោកទាំងពួង សុណាតុ ក៏ចូរស្តាប់ វចនំ នូវពាក្យ មេ នៃអញខ្ញុំ វិនយំ វិសជ្ជេយ្យំ នឹងសំដែងដោះស្រាយនូវព្រះវិន័យ យទិ ថាបើ បត្តកល្លំ ជាកាលគួរ សង្ឃស្ស ដល់សង្ឃ អហំ រីខ្ញុំ មហាកស្សបេន ដ្បិតព្រះមហាកស្សប បុដ្ឋោ អ្នកដណ្តឹងសួរហើយ វិសជ្ជេយ្យំ គប្បីដោះស្រាយជាទីសណ្តាប់ប្រាប់អស់ជំនុំសង្ឃក្នុងគ្រានេះឯង ៗ

( កាលណាព្រះឧបាលិត្ថេរ អ្នកបានប្រកាសដូច្នោះហើយ ព្រះហត្ថាក៏ចាប់យកនូវផ្លិតវាលវិជនី វិចិត្រសុទ្ធតែងងក្ខុកជំស្នាត ពត់ព្រះភ្នែនពេនព្រះបាទស្អាតលើគ្រែធម្មាសនៈ ហើយក៏ឆ្លើយព្រះវិន័យបិដកនោះនឹងព្រះមហាកស្សមត្ថេរថា : )

វិសជ្ជនា ១. — បឋមំ វិនយបិដកំ ភន្តេ កស្សប

បពិត្រព្រះអរិយកស្សបដ៏ប្រសើរអើយ វិព្រះវិន័យបិដកនោះ សម្តេចព្រះបរ
សាស្តាចារ្យទ្រង់ត្រាស់សំដែងថាមាន ៥ គម្ពីរណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ២- កតមំ បករណំ អាវុសោ ហៃអាវុសោ ឧបាលិ
ដ៏ចំរើនអើយ អ្នកអើយ វិគម្ពីរទាំង ៥ នោះ តើមានឈ្មោះអ្វីខ្លះហ្ន៎អ្នក ?

ទិ. ២- អាទិកម្មំ បាចិត្តិយំ មហាវគ្គំ ចុល្លវគ្គំ បរិវារំ ។
ភន្តេ បពិត្រព្រះអរិយកស្សបដ៏ប្រសើរអើយ គម្ពីរទាំង ៥ នោះ ឈ្មោះ
ថាអាទិកម្ម១, បាចិត្តិយ១, មហាវគ្គ១, ចុល្លវគ្គ១, បរិវារ១, ផ្សំទាំងអស់
ផងគ្នាត្រូវជាព្រះវិន័យមាន ៥ គម្ពីរណាព្រះករុណាសូមទ្រង់ជ្រាប ។

បុ. ៣- ចតុបកណំ ថបេត្វា អាវុសោ ម្នាល ឧបាលិ
ប្អូនដ៏មានអាយុអើយ អ្នកកើយ ក្នុងគម្ពីរទាំង៤នោះ សូមលើកទុកសិនចុះ
យើងនឹងដណ្តឹងសួរអ្នកតែក្នុងគម្ពីរអាទិកម្ម . ជាដើម ជាបឋម តើសម្តេច
ព្រះទ្រង់ញាណ ទ្រង់មានព្រះពុទ្ធដីកាត្រាស់សំដែង ចែកញែកចេញជា
សិក្ខាបទមានប៉ុន្មានទៅហ្ន៎អ្នក ?

ទិ. ៣- សត្តវីសតាធិកានិ ទ្វេសតសិក្ខាបទានិ ។ ភន្តេ
កស្សប បពិត្រព្រះអរិយកស្សបដ៏ប្រសើរអើយ សម្តេចព្រះសាស្តាចារ្យ

ទ្រង់មានព្រះពុទ្ធដីកាថា មានសិក្ខាបទនោះ ២២៧ ណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ៤- កតមានិ ឧទ្ទេសានិ អាវុសោ ឧបាលិ ម្នាលអាវុសោឧបាលិអើយ ក្នុងសិក្ខាបទ២២៧នោះ បើចែកចេញជាឧទ្ទេស មានប៉ុន្មានហ:អ្នកឧបាលិ?

វិ. ៤_ អដ្ឋ ឧទ្ទេសានិ ភន្តេ បពិត្រព្រះអរិយកបអម្ចាស់អើយ ក្នុងសិក្ខាបទ២២៧នោះ មានឧទ្ទេស ៨ ក្នុង ឧទ្ទេសមួយ ៗ មានផ្សេងពីគ្នា ក្នុងឧទ្ទេសបទដើមឈ្មោះបារាជិក មានសិក្ខាបទ ៤, សង្ឃាទិសេសមានសិក្ខាបទ ១៣ អនិយតមាន ២, និស្សគ្គិយបាចិត្តិយ ៣០ សុទ្ធិកបាចិត្តិយ៩២, បាដិទេសនីយ ៤ សេក្ខិយវត្ត ៧៥ រួមទាំងអធិករណសមថ ៧ ផង ត្រូវជាសិក្ខាបទ ២២៧ ណាអម្ចាស់សូមទ្រង់ជ្រាប ។

បុ. ៥_ សាធុ អាវុសោ ឧបាលិ ម្នាលឧបាលិដ៏ចំរើនអើយ ល្អហើយអ្នកអើយ យើងនឹងចង់ដណ្តឹងសួរអ្នកក្នុងឧទ្ទេស បទដើមឈ្មោះ បារាជិក ដែលអ្នកសំដែងថាមានសិក្ខាបទ ៤ ចុះក្នុងសិក្ខាបទទី ១ នោះ តើមានឈ្មោះដូចម្តេចហ:អ្នក ?

វិ. ៥- មេថុនធម្មំ បារាជិកំ ភន្តេ បពិតព្រះអរិយកសង្រួម

ជាអម្ចាស់ ឯសិក្ខាបទទី ១ ឈ្មោះមេថុនធម្មបារាជិក ណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ៦– កិំ អារព្ភ អាវុសោ ម្នាលអាវុសោ ឧបាលិអើយ ចុះមេថុនធម្មសិក្ខាបទនោះតើព្រះឈ្មះមារទ្រង់ប្រារព្ធចំពោះបុគ្គលណាហ្ន៎ះអ្នក ?

ឆ. ៦- សុទិន្នំ កលន្ទបុត្តំ ។ ភន្តេ បពិត្រព្រះអរិយកស្សប រីសម្តេចព្រះដ៏ទ្រង់យស ទ្រង់ប្រារព្ធចំពោះសុទិន្នភិក្ខុ ជាកលន្ទបុត្តណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ៧- កិស្មឹ វត្ថុស្មឹ អាវុសោ ម្នាលអាវុសោ ឧបាលិអើយសម្តេចព្រះបរមសាស្តាចារ្យទ្រង់ប្រារព្ធដោយនូវហេតុវត្ថុអ្វីហ្ន៎ះ អ្នក ?

ឆ. ៧- ភន្តេ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ព្រះបរមសាស្តាចារ្យទ្រង់ប្រារព្ធនឹងសុទិន្នភិក្ខុ ដែលសេពមេថុនធម្មជាមួយនាងបុរាណទុតិយិកា ជាប្រពន្ធពីដើមណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ៨- កត្ថ បញ្ញត្តំ អាវុសោ ម្នាលអាវុសោ ឧបាលិអើយ ព្រះមានព្រះភាគសម្តេចទ្រង់បញ្ញត្តនៅទីឋានឯណាហ្ន៎ អ្នក ?

ឆ. ៨– វេសាលិយំ ភន្តេ បពិត្រព្រះអរិយកស្សប សិក្ខាបទ

នេះ សម្តេចព្រះទ្រង់យស ទ្រង់បញ្ញត្តនៅក្នុងក្រុងវេសាលី ណាអម្ចាស់ សូមទានក្រាប ។

ប. ៩- សាធុ អាវុសោ ឧបាលិ ម្នាលឧបាលិ ដ៏ចំរើនអើយ ការម៉្យាអ្នកឆ្លើយដោះសាមគក្នុងមេថុនធម្មសិក្ខាបទ ដែលព្រះពុទ្ធអង្គទ្រង់ប្រារព្ធចំពោះនឹងអ្នកសុទិន្នភិក្ខុនោះ ខ្ញុំដឹងហើយណាឧបាលិអើយ ឥឡូវយើងនឹងដណ្តឹងសួរអ្នកតទៅទៀត ក្នុងសិក្ខាបទជាគម្រប់ពីរ តើសម្តេចព្រះសព្វ-ញ្ញុតញ្ញាណទ្រង់សំដែងថា ឈ្មោះអ្វីហ្ន:អ្នក ?

ឋិ. ៩- អទិន្នាទានំ ទុតិយំ បារាជិកំ ។ ភន្តេ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ វីសិក្ខាបទជាគំរប់ពីរនោះ សម្តេចព្រះសព្វញ្ញុតញ្ញាណទ្រង់មានព្រះពុទ្ធដីកាសំដែងថា ឈ្មោះ អទិន្នាទានជាបារាជិកណាព្រះករុណា សូមទ្រង់ជ្រាប ។

ប. ១០- កំ អារព្ភ អាវុសោ ឧបាលិ ម្នាលឧបាលិអើយ អ្នកអើយវីអទិន្នាទានជាបារាជិកនោះ តើទ្រង់ប្រារព្ធនឹងបុគ្គលឈ្មោះអ្វីហ្ន:អ្នក ?

១០- ធនិយំ កុម្ភការបុត្តំ អារព្ភ បពិត្រព្រះអរិយកស្សបដ៏ចំរើន អទិន្នានបារាជិកនេះ ព្រះសម្ពុទ្ធម្ចាស់លោកទ្រង់ប្រារព្ធនឹងធនិយត្ថេរជាកូនស្មូនឆ្នាំងណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ១១. កឹស្មឹ វត្ថុស្មឹ អាវុសោ ម្នាលឧបាលិ ដ៏មាន អាយុអើយ តើសម្ដេចព្រះឈ្មោះមារទ្រង់ប្រារព្ធ ដោយហេតុវត្ថុអ្វីហ្ន៎ះអ្នក ?

ឋិ. ១១- អទិន្នាទានវត្ថុ ។ ភន្តេ បពិត្រព្រះអរិយកស្សបជាអម្ចាស់ បានផាសម្ដេចព្រះឈ្មោះមារទ្រង់ប្រារព្ធនឹងធនិយត្ថេរ ដោយលោកបានយកព្រះរាជទ្រព្យ ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា ណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ១២- កត្ថ បាវេទ អាវុសោ ម្នាលអាវុសោ ឧបាលិ ចុះព្រះអង្គទ្រង់បញ្ញត្តនៅក្នុងនគរណាហ្ន៎ះអ្នក ?

ឋិ. ១២- រាជគហេ ភន្តេ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សម្ដេចព្រះទ្រង់យសទ្រង់បញ្ញត្តសិក្ខាបទនោះ នៅក្នុងក្រុងរាជគ្រឹះណាអម្ចាស់ សូមទានជ្រាប ។

បុ. ១៣- សាធុ អាវុសោ ម្នាលអាវុសោ ឧបាលិអើយ ចម្លើយអ្នកឆ្លើយមកនេះលោកទាំងពួងដឹងរាល់គ្នាហើយ ម្នាលអាវុសោឧបាលិអើយ យើងចង់ដណ្ដឹងសួរអ្នកនូវសិក្ខាបទជាគម្រប់ ៣ តទៅទៀត តើសម្ដេចព្រះជិនស្រីមុនីសារពេជ្ញ ស្ដេចទ្រង់ត្រាស់សំដែងថាឈ្មោះអ្វីហ្ន៎ះអ្នក ?

ឋិ. ១៣. មនុស្សវិគ្គហំ ។ ភន្តេ បពិត្រព្រះអរិយកស្សប

អម្ចាស់អើយ វិសិក្ខាបទជាគំរប់ ៣ សម្តេចព្រះមុនីនាថសាស្តាចារ្យចរិយាវង្ស ទ្រង់សំដែងថាឈ្មោះមនុស្សវិគ្គហសិក្ខាបទ ណាអម្ចាស់សូមទ្រង់ជ្រាប ។

បុ. ១៤- កំ អារព្ភ អាវុសោ ហៃអាវុសោ ឧបាលិអើយ ចុះព្រះពុទ្ធអង្គទ្រង់ប្រារព្ធនឹងបុគ្គលណាហ អ្នក ?

វិ. ១៤- សដ្ឋី ភិក្ខូ ។ ភន្តេ បពិត្រព្រះអរិយកស្សប អម្ចាស់អើយ សម្តេចព្រះសាស្តាចរិយាវង្ស ទ្រង់ប្រារព្ធចំពោះនឹងភិក្ខុទាំងឡាយ ៦០ រូបណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ១៥- កិស្មឹំ វត្ថុស្មឹ អាវុសោ ឧបាលិ ម្នាលឧបាលិដ៏មានអាយុអើយ សម្តេចព្រះពិជិតមារទ្រង់ប្រារព្ធចំពោះហេតុអ្វីហ អ្នក ?

វិ. ១៥- ភន្តេ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ព្រះបរមសាស្តាចរិយាវង្ស ទ្រង់ប្រារព្ធនឹងភិក្ខុទាំងឡាយ ៦០ រូប ដែលបេសម្រាប់ខ្លួនឯង ណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ១៦- កត្ថ បានេ អាវុសោ ម្នាលអាវុសោ ឧបាលិអើយ សម្តេចព្រះទ្រង់យសទ្រង់ប្រារព្ធបញ្ញត្តនៅទិឋានឯណាហ អ្នក ?

វិ. ១៦- រាជគហេ ភន្តេ បពិត្រព្រះអរិយកស្សបអម្ចាស់

អើយ សម្តេចព្រះបរមគ្រូ ទ្រង់បញ្ញត្តសិក្ខាបទនេះ នៅនគរណាផ្ទះ ណាអម្ចាស់ សូមទ្រង់ជ្រាប ។

ប. ១៧— សាធុ អាវុសោ ឧបាលិ ម្នាលឧបាលិដ៏មានអាយុដ៏សអើយ ចម្លើយអ្នកឆ្លើយនេះពីរោះពេកហើយ អើអ្នកអើយ យើងចង់សួរអ្នកក្នុងសិក្ខាបទ ជាគំរប់ ៤ ត ទៅទៀត តើសម្តេចព្រះជិនស្រីសារពេជ្ញស្តេចទ្រង់សំដែងថាឈ្មោះអ្វីហ្ន៎ អ្នក ?

ទ. ១៧- ឧត្តរិមនុស្សធម្មំ បពិត្រព្រះអរិយ កស្សបអម្ចាស អើយ វិសិក្ខាបទជាគំរប់ ៤ ឈ្មោះឧត្តរិមនុស្សធម្មបារាជិក ណាអម្ចាស់ សូមទ្រង់ជ្រាប ។

ប. ១៨- កំ អារព្ភ អាវុសោ ម្នាលអាវុសោ ឧបាលិ អើយ ចុះសិក្ខាបទនេះ សម្តេចព្រះសព្វញ្ញុតញ្ញាណ មានព្រះពុទ្ធដីកា ប្រារព្ធនូវបុគ្គលពួកណាហ្ន៎ អ្នក ?

ទ. ១៨- សម្ពហុលេ ភិក្ខូ បពិត្រព្រះមហាកស្សប សម្តេចព្រះបរមគ្រូ ទ្រង់ប្រារព្ធបញ្ញត្តសិក្ខាបទនេះ ចំពោះភិក្ខុទាំងឡាយ ៦០ រូប ណាអម្ចាស់ សូមទ្រង់ជ្រាប ។

ប. ១៩- កិស្មឹ វត្ថុស្មឹ អាវុសោ ឧបាលិ ម្នាល ឧបាលិដ៏មានអាយុ ចុះព្រះឈ្នះមារមានព្រះពុទ្ធដីកាប្រារព្ធនូវហេតុអ្វីហ្ន៎ អ្នក ?

ថិ. ១៩— ឧត្តរិមនុស្សធម្មវត្ថុ ។ ភន្តេ បពិត្រព្រះអរិយកស្សប អម្ចាស់អើយ សម្ដេចព្រះពុទ្ធអង្គទ្រង់ប្រារព្ធនឹងភិក្ខុទាំងឡាយ ៦០ រូប ដែលស្រដីអួតនូវគុណវិសេស មានឈាន សមាបត្តិជាដើមដែលមិនមាន ក្នុងខ្លួន ណាអម្ចាស់ សូមទ្រង់ជ្រាប ។

ប៉ុ. ២០- កត្ថ បានេ អាវុសោ ម្នាលអាវុសោឧបាលិអើយ ចុះព្រះឈ្មោះមារទ្រង់បញ្ញត្ត ឧត្តរិមនុស្សធម្មសិក្ខាបទនេះ នៅទីស្ថានឯណាហេ៎អ្នក ?

ថិ. ២០— សាវត្ថិយំ ភន្តេ បពិត្រព្រះអរិយកស្សបជាអម្ចាស់ សម្ដេចព្រះទ្រង់យស ទ្រង់បញ្ញត្តនៅនគរសាវត្ថី ណាអម្ចាស់ សូមទ្រង់ជ្រាប ។

ប៉ុ, ២១- កថេហិ អាវុសោ ម្នាលអាវុសោ ឧបាលិអើយ អ្នកមានប្រាជ្ញាប្រពៃណាស់ ចូរអ្នកនាំនិទានឲ្យបានពិស្ដារមកកាលគ្រាឥឡូវនេះ មកមើលហ៎អ្នក ?

ថិ. ២១-(សត្ថា ជេតវនេ វិហរន្តោ សាវត្ថិយំ ឧបនិស្សាយ បពិត្រអើយ នាកាលគ្រានោះ ព្រះមហាឧបាលិត្ថេរ កាលណាបើបានស្ដាប់ព្រះមហាកស្សបត្ថេរទ្រង់បង្គាប់ឲ្យស់ដែងដូច្នោះ

ហើយ អ្នកក៏អធិប្បាយថា) ភន្តេ មហាថេរ បពិត្រព្រះអរិយ កស្សបអម្ចាស់អើយ នាកាលសម្តេចព្រះជិនវង្សសាស្តាចារ្យ វិហរន្តោ ព្រះ អង្គកាលគង់នៅ ជេវតនេ ក្នុងវត្តជេតពនសុតន្តកុដីមហាវិហារ ឧប និស្សាយ ទ្រង់តែងនឹងយាងដោយព្រះបាទាលីលាទៅយកព្រះបិណ្ឌបាត្រ សង្វាតប្រោសសត្វ សាវត្ថិយំ ក្នុងនគរសាវត្ថី មានសម័យថ្ងៃ ១ លោកភិក្ខុទាំង ៦០ រូប រៀនវិបស្សនាកម្មដ្ឋាននឹងព្រះអភិធម្ម អំពីព្រះពុទ្ធឥស្ស ទ្រង់ប្រោសប្រទាន បានស្រេចកាលណាហើយ ក៏បាននិមន្តទៅស្រុកក្រៅ លំនៅជនបទឆ្ងាយ ប្រយោជន៍ដើម្បីនឹងចំរើនមេត្តាករុណាព្រះវិបស្សនាកម្មដ្ឋាន ដើម្បីឲ្យបានសម្រេចមគ្គផល កាលគ្រានោះ ។ រីឯអ្នកស្រុកទាំងពួង បង្កើតជាទុរ្ភិក្សរាំងអត់បាយ មានទាំងជម្ងឺទាំងឡាយក៏មានច្រើន ម្នោះហើយ អស់មហាជនផងទាំងឡាយក៏សឹងមិនអាចដើម្បីនឹងមានអ្នកឯណាមានចិត្ត សទ្ធា បូជានូវចតុប្បច្ច័យទាំង ៤ ដំពូកនេះឡើយ ។

គ្រានោះ អស់ភិក្ខុទាំង ៦០ រូប ដំនុំគិតគ្នាថា អាវុសោ ម្នាល អាវុសោផងទាំងពួងអើយ អស់យើងរាល់គ្នា យើងនឹងគិតធ្វើដូចម្តេច? ភិក្ខុខ្លះឆ្លើយថា ខ្ញុំមានប្រាជ្ញាឧបាយកល១ បើលោកទាំងអស់អង្គព្រមចូល ចិត្តរាល់គ្នា យើងនឹងបានសម្រេចបំណងនេះមិនខាន គឺកាលណាយើង

ឃើញអស់ឧបាសក ទាយករទាយិកាមកដល់កាលណាហើយ យើងត្រូវមាន
វាចាស្រដីអួតកុហកមុសាប្រាប់ថា អាត្មាចំរើនវិបស្សនាកម្មដ្ឋាន បានឃើញស្ថាន
សួគ៌ស្ថាននរកប្រេតទាំងឡាយ ឃើញអស់ខ្មោចបីសាចជីដូនជីតារបស់អស់អ្នកពួង
រាល់គ្នាឈ្មោះដូច្នេះៗ សឹងតែយំស្រែកទីទៃ ៗ ក៏បាននូវសេចក្ដីស្រេក
ឃ្លានរាល់គ្នា លោកខ្លះថាបាននូវគុណវិសេស មានឈានសមាបត្តិជាដើម
ជាប្រធាន ព្រមទាំងឈានលោកិយផង ថាបើអ្នកឯណា ១ មានជម្ងឺទឹង
ស្លាប់រស់ក្ដីគ្រប់ប្រការ ។ បពិត្រអើយ ក្នុងកាលនោះ ពួកភិក្ខុទាំង
នោះ កាលឃើញទាយកទាយិកាមកដល់ហើយ ក៏អួតអាងសព្វគ្រប់ ។
តំ សុត្វា មហាជនទាំងឡាយ កាលណាបើបានស្ដាប់ភិក្ខុទាំងឡាយ
និយាយគ្នាថា ដូច្នោះហើយ ក៏តិតក្ការកប្រដាប់ប្រដាភោជនាហារទៀនធូបភ្ញីផ្កា
ស្វាម្ពូជាយ៉ាងឧឡារិក តឹកកងមហិមា

តតោ បដ្ឋាយ លាភសក្ការោ ឧប្បជ្ជិ បពិត្រ
អើយ ចាប់តាំងពីថ្ងៃនោះមក លាភសក្ការៈ ក៏កើតមិរមុណិ ដល់ភិក្ខុ
ទាំងនោះហើយពាក្យនោះ ក៏វាមិនបាត់ឡើយ ក៏ឮជ្រួតជ្រាបទៅដល់ព្រះ
សោតទិព្វថ្ងៃនៃអង្គសម្ដេចព្រះសាស្ដាចារ្យ ព្រះអង្គទ្រង់ជ្រាបកាលណាទ្រង់ក៏
ឲ្យហៅភិក្ខុទាំង ៦០ រូប មកដល់កាលណាហើយទ្រង់បញ្ញត្តសិក្ខាបទឧត្តរិមនុស្ស

ធម្មបារាជិកនេះឡើងក្នុងកាលគ្រានោះឯង បពិត្រព្រះអរិយកស្សបជាអម្ចាស់សូមទ្រង់ជ្រាប ។

ម្ចុ. ២២— សាធុ សាធុ អាវុសោ ឧបាលិ

ម្នាលឧបាលិអើយ អ្នកនាំនិទានពីភិក្ខុ ៦០ រូបមកនេះ ពីព្រោះពេកហើយតែកស្សបនៅសង្ស័យនឹងសម្តេចព្រះពុទ្ធអង្គថា ហេតុអ្វីបានជាទ្រង់មិនបញ្ញត្តអំពីមុន លុះដល់ភិក្ខុធ្វើខុសហើយ ទើបទ្រង់បញ្ញត្តជាខាងក្រោយដូច្នេះហៈអ្នកឧបាលិ ចូរអ្នកនាំសេចក្តីកាត់ការសង្ស័យនៃយើងខ្ញុំទាំងពួងមើលហៈអ្នក?

ចិ. ២២— (តំ សុត្វា ឧបាលិត្ថេរោ ព្រះមហាឧបាលិត្ថេរកាលណាបើបានស្តាប់ព្រះកស្សបអ្នកទ្រង់សួរដូច្នោះហើយ ក៏មានថេរគាថាថា) ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយបានជាព្រះពុទ្ធអង្គមិនបានទ្រង់បញ្ញត្តជាមុនព្រោះទ្រង់ឈ្វេងយល់ហេតុ ២ ប្រការ គឺប្រការទី ១ សោតដូចជាពេទ្យចេះថ្នាំហើយ បើបុគ្គលគ្មានជម្ងឺមិនដែលពេទ្យណាយកថ្នាំទៅចាក់ឲ្យជាមុនដូច្នោះឡើយ លុះតែបុគ្គលមានជម្ងឺ ទើបពេទ្យយកថ្នាំទៅព្យាបាលប្រការ ១ វិញសោតទៀត នឹងតាំងឈ្មោះបុគ្គលដូច្នោះ ៗ មានស្រុកលំនៅដ៏ប្រាកដ កុំឲ្យមានពាក្យនិន្ទាថាព្រះបរមសាស្តាចារ្យសំដែងបញ្ញត្តរកទីកំណត់គ្មាន ។ ហេតុដូច្នេះ បានជាសម្តេចព្រះពុទ្ធអង្គមិនទ្រង់បញ្ញត្តជាមុនណាអម្ចាស់សូមទ្រង់ជ្រាប កុំបីមានការសង្ស័យទៅទៀតណាអម្ចាស់ ។

បុ. ២៣ សាធុ សាធុ ឧបាលិ ម្នាលឧបាលិអើយ អ្នកហោងដំមានប្រាជ្ញាប្រពៃ អធ្យាស្រ័យល្អះចេះកាត់នូវសន្ទិះសង្ស័យយើងទាំងពួងគ្រប់គ្នាចូលចិត្តហើយ អើ ឧបាលិអើយ តែកស្សបបងនៅសង្ស័យនឹងចទបារាជិក បានជាសម្តេចព្រះពុទ្ធអង្គទ្រង់សំដែងថា បារាជិកនោះតើបានសេចក្តីយ៉ាងណាទៅហ អ្នក ចូរឧបាលីប្អូននាំសេចក្តីអធិប្បាយស្រាយក្នុងបទបារាជិកមកមើលហ៎ះអ្នក ?

ឆ. ២៣- (ឧបាលិត្ថេរោ តំសុត្វា ព្រះឧបាលិត្ថេរ កាលណាបើបានស្តាប់សេចក្តីព្រះកស្សប ទ្រង់បង្គាប់ឲ្យសំដែងអធិប្បាយប្រែស្រាយក្នុងបារាជិកហើយ អ្នកក៏ឆ្លើយតបវិញថា) ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមចាំស្តាប់ខ្ញុំ ឧបាលិនឹងសំដែងអធិប្បាយតាមព្រះពុទ្ធដីកា ។ សម្តេចព្រះជិនវង្សទ្រង់សំដែងក្នុងបទបារាជិកនេះ ប្រែថាការចាលចាញ់ក្នុងព្រះសាសនា និមិត្តតែគេត្រូវទោសនេះកាលឯណាហើយនឹងបុសជាភិក្ខុវិញពុំបានឡើយ ហេតុដូច្នេះហើយបានជាសម្តេចព្រះសយម្ភូញាណទ្រង់មានព្រះពុទ្ធដីកាកំណត់ទុកមកយ៉ាងនេះ ណាអម្ចាស់សូមទ្រង់ជ្រាប ។

បុ. ២៤ – (កស្សបត្ថេរោ តំ សុត្វា ព្រះមហាកស្សបត្ថេរ

កាលណាបើបានស្ដាប់ថេរវាថាព្រះឧបាលិអ្នក នាំសេចក្ដី អធិប្បាយ តាមព្រះពុទ្ធដីកាមកដូច្នេះអ្នកចូលចិត្តហើយ ទើបឆ្លើយថា សាធុ ពីរោះពេកហើយ អើឧបាលិអើយ កស្សបបងនឹងចង់ដណ្ដឹងសួរអ្នក ទៅវិញទៀត ឯបទបារាជិកនេះ បើភិក្ខុឯណាត្រូវបារាជិកនីមួយ ។ នោះតើនឹងចាលចាញ់ព្រះសាសនា នឹងបួសវិញមិនបានដូចម្ដេចទៅហ្ន៎អ្នក ?

ទិ. ២៤— ថេរោ តំ សុត្វា ព្រះឧបាលិត្ថេរ កាលបើបានស្ដាប់ ថេរវាថាព្រះ មហាកស្សប អ្នក ដណ្ដឹងសួរដូច្នោះហើយ ក៏ពិតថេរវាចាវិញថា ភន្តេ ថេរ: បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីសិក្ខាបទទាំង ២២៧ នោះ សម្ដេចព្រះទ្រង់ញាណ ទ្រង់លើក យកសិក្ខាបទ ៤ នេះជាមូលកល់នៃសិក្ខាបទផងទាំងពួង ថាបើភិក្ខុឯណា ១ សេពមេថុនធម្ម កាលឯណាហើយ ព្រះពុទ្ធអង្គទ្រង់ត្រាសថា ដូចជាមនុស្សកំបុតក្បាល ។ អទិន្នំ ថេយ្យសង្ខាតំ អធិប្បាយថា បើភិក្ខុឯណា បានយកទ្រព្យគេដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចា ត្រឹមតែថ្ងៃ ១ បាទហើយ ព្រះពុទ្ធទ្រង់ត្រាសថា ដូចជាស្លឹកឈើជ្រុះអំពីដើម មិនអាចនឹងជាប់វិញបានឡើយ ។ មនុស្ស វិគ្គហំ បើភិក្ខុណាសម្លាប់មនុស្សហើយ សម្ដេចព្រះទ្រង់ញាណទ្រង់ប្រៀបដូចជាត្នោតកំបុតក ។ ឧត្តរិមនុស្សធម្មំ បើភិក្ខុឯណា ១ ស្រដីភូតព្រៃ

លែងនឹងមនុស្សផងទាំងពួង ថាបានឈាន សមាបត្តិ ឬ ដូចជាលោក ផង ទាំងពួងថា អង្គុយធម៌ទៅឃើញខ្មោចបិសាច ឃើញ កម្ម ពៀរអ្នក នោះ ៗ ដូច្នោះ ៗ នោះហៅខុសផ្លូវនពលោកុត្តរធម៌ទាំង ៩ ប្រការ សម្តេច ដណ្ដឹមារទ្រង់ ប្រៀបដូច ជាថ្មបាក់ មិនដែល ណានឹងជាប់ វិញ បានឡើយ ។ ហេតុដូច្នោះហើយបានជា សម្តេចព្រះទ្រង់ញាណទ្រង់មានពុទ្ធដីកាថា ភិក្ខុណាត្រូវអាបត្តិបារាជិកណាមួយហើយ ហៅថាចាលចាញ់ព្រះសាសនា នឹង បួសវិញមិនបានឡើយ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ២៥— **សាធុ អាវុសោ** ម្នាលឧបាលីដ៏ចំរើនអើយ អ្នក ឆ្លើយមកនេះពីរោះពេក ត្រូវតាមព្រះពុទ្ធដីកាហើយ សោតឯយើងក៏ចូលចិត្ត ហើយឧបាលិអើយ តែយើងនៅសង្ស័យតទៅទៀតដូចជាអ្នកថា អ្នកត្រូវ អាបត្តិបារាជិកនឹងត្រូវចាលចាញ់ព្រះពុទ្ធសាសនា នឹងបួសក៏ពុំបានដូច្នោះ ចុះ បើសឹកទៅជាគ្រហស្ថយកវាសរក្សាសីល ព្យាយាមដរាបដល់អស់អាយុទៅ តើនឹងបានសម្បត្តិសួគ៌ ឬ ទេហ ឧបាលិ ចូរអ្នកនាំសេចក្តីមកមើលហះអ្នក?

វិ. ២៥- **តំ សុត្វា** ព្រះឧបាលិត្ថេរ កាលណាបើបាន ស្តាប់ថេរវាចា ព្រះមហាកស្សបអ្នកដណ្ដឹងសួរដូច្នោះហើយ ក៏មានថេរវាចា ថា **ភន្តេ កស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ **យោ បន ភិក្ខុ** រីភិក្ខុឯណា កាលត្រូវអាបត្តិបារាជិកណានីមួយ ហើយត្រូវថ្ងៃណាក៏ផ្លាស់

គេទថ្ងៃនោះ រក្សាសីល ៥ ចាំស៊ីល ៨ ដរាបដល់អស់ជីវិតទៅអ្នកនោះឯង នឹងបានសម្បត្តិសួគ៌ពិតប្រាកដមិនខានឡើយ បពិត្រព្រះអរិយកស្សប សូមទ្រង់ជ្រាប ។

វិនយំ បុច្ឆាវសានេ ព្រះមហាកស្សបត្ថេរ អ្នកដណ្តឹងសួរនូវព្រះវិន័យបិដក នឹងព្រះឧបាលិត្ថេរដោះសង្ខេបកថា គឺស្រេចហើយ សូមនិមន្តព្រះមហាថេរទាំង ៤ អង្គ ស្វាធ្យាយនូវបទខ្មែរ ឲ្យព្រម ។ គ្នាគ្រប់ព្រះអង្គទៅហោង ។

ចប់សំនួរ និង ចម្លើយ

ក្នុងព្រះវិន័យបិដក

# បឋមសង្គាយនាវគ្គ ៣

## ព្រះមហាកស្សបចោទសួរព្រះសូត្របិដក
## នឹងព្រះមហាអានន្ទ

## ព្រះមហាអានន្ទ ឆ្លើយព្រះសូត្របិដក
## នឹងព្រះមហាកស្សបត្ថេរ

### ព្រះមហាកស្សបត្ថេរផ្តើមចោទសួរ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

តទនន្តរំ លំដាប់នោះ វិនយបុច្ឆាវសានេ នាកាលព្រះមហាកស្សបត្ថេរ បានចោទសួរព្រះវិន័យស្រេចកាលឯណាហើយ គ្រានេះអ្នកកំណត់ឯងសួរនូវគម្ពីរព្រះសូត្រ នឹងព្រះមហាអានន្ទត្ថេរ ជាកំណត់ទៅទៀត ៗ

បុច្ឆា- ១- សុត្តន្តបិដកំ កតិប្បមាណំ អាវុសោ

ម្នាលអាវុសោ អានន្ទអើយ រីព្រះសូត្របិដកនោះ តើសម្តេចព្រះជិនស្រី ទ្រង់សំដែងជាមានចំនួនគម្ពីរប៉ុណ្ណោះ អានន្ទអ្នក ?

# ព្រះអានន្ទត្ថេរចាប់ឆ្លើយ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

អានន្ទោ សង្ឃញាបេសិ គ្រានោះព្រះមហាអានន្ទ អ្នកប្រ-
កាសអស់ដំនុំសង្ឃផងទាំងពួងថា សុណាតុ មេ ភន្តេ សង្ឃោ
យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មា មហាកស្សបេន
សុត្តន្តបិដកំ បុដ្ឋោ វិស្សជ្ជេយ្យំ ។ ភន្តេ បពិត្រព្រះសង្ឃ
ទាំងឡាយដ៏ចំរើនអើយ សង្ឃោ រីអស់ព្រះសង្ឃ សុណាតុ ក៏ចូរស្តាប់
វចនំ នូវពាក្យ មេ នៃអញខ្ញុំព្រះករុណា វិស្សជ្ជេយ្យំ គប្បីសំដែង
សុត្តន្តបិដកំ នូវព្រះសូត្របិដក, យទិ ថាបើ អយំកាលោ
រីកាលនេះ បត្តកល្លំ ដាកាលគួរ សង្ឃស្ស ដល់អស់ដំនុំសង្ឃហើយ
អហំ រីអញខ្ញុំ មហាកស្សបេន គឺព្រះមហាកស្សបត្ថេរ បុដ្ឋោ
អ្នកដណ្តឹងសួរហើយ សុត្តន្តបិដកំ នូវព្រះសូត្របិដក វិស្សជ្ជេយ្យំ
គប្បីដោះស្រាយ ។

កាលព្រះមហាអានន្ទ មានថេរដីកាដូច្នោះហើយ ក៏អ្នកប្រែអង្គឡើង
គង់លើគ្រែធម្មាសនៈ ហត្ថាអ្នកចាប់យកនូវផ្លិតវាលវីជនីពិចិត្រប្រកបដោយនូវ
ដងភ្លុកដ៏សស្អាតពត់ព្រះភ្នែនពែនព្រះបាទកាលគ្រានោះឯង ។

វិសជ្ជនា ១_ បញ្ចវិធំ ភន្តេ កស្សប បពិត្រព្រះអរិ-
យកស្សបអម្ចាស់អើយ វិព្រះសូត្របិដកនោះ សម្តេចព្រះសព្វញ្ញុពុទ្ធទ្រង់មាន
ព្រះពុទ្ធដីកាសំដែងថាមាន ៥ គម្ពីរណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ២. កតមំ បរណំ អាវុសោ ហៃអាវុសោ អានន្ទ
អើយ ចុះគម្ពីរទាំង ៥ នោះ តើឈ្មោះអ្វីខ្លះ ៗ ហះអានន្ទអ្នក ?

វិ. ២_ ទីឃនិកាយោ មជ្ឈិមនិកាយោ សំយុត្តនិកា
យោ អង្គុត្តរនិកាយោ ខុទ្ទកនិកាយោ ភន្តេ កស្សប បពិត្រ
ព្រះអរិយកស្សបអម្ចាស់អើយ វិគម្ពីរទាំង ៥ នោះ ឈ្មោះទីឃនិកាយ ១,
មជ្ឈិមនិកាយ ១, សំយុត្តនិកាយ ១, អង្គុត្តរនិកាយ ១, ខុទ្ទកនិកាយ ១,
ប្រជុំផងគ្នាត្រូវជា ៥ គម្ពីរ ណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ៣_ ចតុបករណំ ឋបេត្វា អាវុសោ ម្នាលអាវុសោ
អានន្ទអើយ វិគម្ពីរទាំង ៥ នោះយើងលើកទុកសិនចុះ យើងនឹងផណ្ដឹងអ្នក
តែគម្ពីរ ១ ឈ្មោះទីឃនិកាយជាមុនសិន ឯក្នុងគម្ពីរទីឃនិកាយនេះតើព្រះពុទ្ធ
អង្គទ្រង់សំដែងចែកចេញជាសូត្រ មានប៉ុន្មាន ។ សូត្រហៈអានន្ទអ្នក ?

វិ. ៣- ចតុត្តឹសសុត្តំ ភន្តេ កស្សប បពិត្រព្រះអរិយ-
កស្សបអម្ចាស់អើយ វិក្នុងគម្ពីរទីឃនិកាយនោះ មានសូត្រ ៣៤ សូត្រណា
អម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ៤- បឋមំ សុត្តំ អាវុសោ ម្នាលអាវុសោ អានន្ទ អើយ អ្នកអើយក្នុងសូត្រទាំង ៣៤ នោះ តើមានឈ្មោះអ្វីខ្លះហ្ន៎ អានន្ទអ្នក ?

ទិ. ៤- កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីសូត្រទាំង ៣៤ នោះ មានព្រហ្មជាលសូត្រ, សាមញ្ញផលសូត្រ, អម្ពដ្ឋសូត្រ ជាដើម មានទសុត្តរសូត្រជាទីបំផុតណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ៥- កស្សបបងនៅសង្ស័យ នឹងសូត្រ ៣៤ នោះ តើគឺសូត្រទន្ទេធំ ឬសូត្រខ្សាច់កណ្ដាល វាលស្បូវ ចាក់អវ្ងៀង ស្វាយពពែ ច្បារអំពៅ ឬសូត្រកៀនស្វាយ ស្វាយជ្រំ ឬសូត្រដែលឲ្យញ្ចាញសំពត់ ឬក៏សូត្រជម្រាបព្រះគាថាមន្តទាំងឡាយទាំងពួងហ្ន៎អានន្ទអ្នក ចូរអានន្ទអ្នកចាត់ចែងសំដែងវោហារក្នុងអដ្ឋកថា ប្រែស្រាយរាយរ៉ាប់ប្រាប់មកបពិត្រផងទាំងពួង បានស្ដាប់រាល់គ្នាមើលហ្ន៎អានន្ទ ?

ទិ. ៥- ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីសូត្រទាំង ៣៤ សូត្រនោះ មិនគឺសូត្រ ទន្ទេធំ ខ្សាច់កណ្ដាល ចាក់អវ្ងៀង ស្វាយពពែ ច្បារអំពៅ កៀនស្វាយ ស្វាយជ្រំ ក៏ទេដែរ រីសូត្រនោះគឺគម្ពីរទាំង ៥ គម្ពីរតែងចងអស់បទធម៌ព្រះគាថាបាលីផងទាំងពួង មិនឲ្យខ្វាក់ខ្វាយចេញឆ្ងាយ បានឡើយណាអម្ចាស់សូមទ្រង់ជ្រាប ។

ប៉ុ. ៦- កំ អារព្ភ ម្នាលអាវុសោ អានន្ទអើយ អ្នកហោងដ៏មានសិរីសួស្តីប្រសើរ អើអានន្ទអើយ ឯព្រហ្មជាលសូត្រនោះ តើព្រះសាស្តាទ្រង់សំដែងប្រារព្ធ នឹងបុគ្គលឈ្មោះអ្វីហ៎ះអានន្ទអ្នក ?

ទិ. ៦- សុប្បិយបរិព្វាជកស្ស ព្រហ្មទត្តមាណវំ អន្តេវាសិកំ ភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ព្រះសយម្ភូទ្រង់ប្រារព្ធនឹងព្រហ្មទត្តមាណព ជាសិស្សនៃសុប្បិយបរិព្វាជក ណាអម្ចាស់ សូមទ្រង់ជ្រាប ។

ប៉ុ. ៧- កិស្មឹ វត្ថុស្មឹ អាវុសោ ម្នាលអាវុសោ អានន្ទអើយព្រះសាស្តាចរិយាវង្សទ្រង់សំដែង តើដោយហេតុអ្វីខ្លះហ៎ះអ្នក ?

ទិ. ៧- ភន្តេ បពិត្រព្រះអរិយកស្សបបានជាព្រះពុទ្ធអង្គទ្រង់ប្រារព្ធចំពោះមាណពនោះ ព្រោះហេតុអ្នកទាំងពីរតិះដៀលគ្នា សូមទានជ្រាប ។

ប៉ុ. ៨- កត្ថ ឋានេ អាវុសោ អានន្ទ ម្នាលអាវុសោអានន្ទអើយ ព្រះសាស្តាចរិយាវង្សទ្រង់សំដែងនៅទីស្ថានឯណាហ៎ះអានន្ទអ្នក ?

ទិ. ៨- ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ វិសម្តេចព្រះទ្រង់ញាណ ទ្រង់សំដែងនៅអម្ពលដ្ឋិកវន ជាសួនឧទ្យាន នៃ

ព្រះបាទពិម្ពិសាររាជ ក្នុងដែនមគធៈ ណាអម្ចាស់សូមទ្រង់ជ្រាប ។

បុ. ៩_ កថេហិ អានន្ទ ម្នាលអាវុសោ អានន្ទអើយ ចូរអ្នកនាំសេចក្ដីក្នុងព្រហ្មជាលសូត្រនេះមកសំដែងមើលហៈអានន្ទអ្នក ?

ទិ. ៩_ អានន្ទោ តំ សុត្វា អានន្ទៈ កាលណាបើបានស្ដាប់ថេរវាចា ព្រះមហាកស្សបត្ថេរ អ្នកទ្រង់បង្គាប់ឲ្យសំដែងដូច្នោះហើយ ពុំយូរឡើយអ្នកក៏នាំនិទានមកសំដែងថា ឯកំ សមយំ ភគវា រាជគហេ វសន្តោ អានន្ទអ្នកប្រកាសដោយព្រះអង្គ ឯងថា ឯតំ សុត្តំ រីសូត្រនេះ ព្រហ្មជាលសុត្តំ មានឈ្មោះថាព្រហ្មជាលសូត្រ មយា គឺខ្ញុំ អានន្ទត្ថេរេន ឈ្មោះអានន្ទត្ថេរ សុតំ បានស្ដាប់មកហើយ សម្មុខា ភគវតោ ចំពោះព្រះភក្ត្រព្រះមានបុណ្យ ឯវំ អាការេន ដោយនូវអាការយ៉ាងនេះ ខ្ញុំអានន្ទក៏ចងចាំបានតាមព្រះពុទ្ធដីកា ប្រោសប្រទានមក ឯកំ សមយំ បពិត្រអើយ មានកាលសម័យថ្ងៃ ១ ភគវា រីព្រះដ៏មានព្រះភាគ ទ្រង់នាំព្រះឱណាស្រេព ៥០០ អង្គនិមន្តដោយមាគ៌ា បានភក្ត្រាទៅកាន់អម្ពល្ដិកឧទ្យាន គ្រានោះមានបរិព្វជកបួសក្រៅព្រះពុទ្ធសាសនា ឈ្មោះស-

ប្បិយបរិព្វាជក នាំសិស្សទាំង ៥០០ មានព្រហ្មទត្តមាណពឯងជាសិស្សច្បង និមិត្តតែបានឃើញសម្តេចព្រះសាស្តាចរិយាវង្សដ៏មានសិរីសួស្តីដ៏ល្អអស្ចារ្យ នឹងទប់ទល់ពុំបាន ក៏មានវាចាសរសើរថា ឱព្រះសមណគោតមអើយ ភគវា ព្រះអង្គមានវង់ទ្រង់ព្រះភក្ត្រព្រះថ្លាបីដូចព្រះចន្ទពេញបូរមីឮដ៏កណ្តាលតារាផងទាំងឡាយទាំងពួង **សុគតោ** ព្រះអង្គមានដំណើរល្អ យាងទៅមានអស់ព្រះខីណាស្រពផងទាំងពួងជាបរិវារ ប្រៀបគណនាបីដូចជារាជសីហា ចេញអំពីគុហាមាសកណ្តាលម្រឹគម្រឹគានានាផងទាំងពួង **អរហំ** ព្រះអង្គឆ្ងាយអំពីវដ្តសង្សារ ពោលគឺកិលេស **សម្មាសម្ពុទ្ធោ** ព្រះអង្គត្រាបច្បាស់នូវព្រះធម៌ដោយព្រះអង្គឯង គ្មានគ្រូអាចារ្យឯណា នឹងប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ព្រះអង្គប្រកបព្រមដោយនូវវិជ្ជានិងចរណៈ **អនុត្តរោ** ព្រះអង្គប្រសើរក្រៃលែងជាងលោកទាំងពួង ។ **តំ សុត្វា** សុប្បិយបរិព្វាជកដ៏ជាអាចារ្យ កាលណាបើបានស្តាប់ពាក្យព្រហ្មទត្តមាណពដ៏ជាសិស្សសរសើរព្រះពុទ្ធអង្គដូច្នោះហើយ ក៏មានវាចាថា ឱព្រហ្មទត្តមាណពអើយ សព្វថ្ងៃនេះ អញទុកចិត្តបាឯងដូចកូនបង្កើត ឥឡូវនេះបាទៅសរសើរព្រះសមណគោតមវិញព្រហ្មទត្តមាណពអើយ ព្រះស្តែងពេញជាអ្នកអកតញ្ញូមិនដឹងគុណគ្រូអាចារ្យឡើយព្រហ្មទត្តមាណព បែរជាសរសើរព្រះពុទ្ធគុណ ធម្មគុណ

សង្ឃគុណ ជាអនេកប្បការ ។ សុប្បិយបរិញ្ជក ក៏នឹងត្មះតិះដៀល សង្ឃព្រះពិដតមារ អ្នកទាំងពីរសិស្សនិងអាចារ្យទាស់ទែងគ្នា ។

គ្រានោះ សម្តេចព្រះសាស្តាចារ្យបែរព្រះភក្ត្រាញញឹមនឹងព្រះអានន្ទជាពុទ្ធុបដ្ឋាក អានន្ទក៏ផណ្ដឹងសួរថា ភន្តេ ភគវា បពិត្រព្រះមានបុណ្យប្រសើរអើយហេតុអ្វីបានជាព្រះអង្គទ្រង់ញញឹម ?

តំ សុត្វា សម្តេចព្រះបរមលោកនាថសាស្តាចារ្យ ទ្រង់មានព្រះពុទ្ធដីកាថា អានន្ទអើយ អើអានន្ទ អ្នកមិនដឹងទេឬ មិនឮទេរឺ សុប្បិយបរិញ្ជកនិងព្រហ្មទត្តមាណព គ្រូនិងសិស្សទាស់ទែងគ្នា, ព្រហ្មទត្តមាណពជាសិស្សពោលសរសើរតថាគត ឯសុប្បិយបរិញ្ជកជាអាចារ្យត្មះតិះដៀលតថាគត អ្នកទាំងពីរកើតបដិបក្សទាស់ ទែងគ្នាហើយនឹងមក កាន់សំណាក់តថាគតក្នុងកាលឥឡូវនេះឯង, មិនលែងឡើយ ។

បពិត្រអើយ នឹងសំដែងអំពីព្រហ្មទត្តមាណព និមិត្តតែទាស់ទែងគ្នាកាលណាក៏លាអាចារ្យ កក្ត្រាឆ្ពោះទៅកាន់អម្ពលដ្ឋិករ័ធឧទ្យាន មានសិស្សសុប្បិយបរិញ្ជក ទាំង ៥០០ ក៏ទៅតាម ព្រហ្មទត្តមាណពក៏ក្រាបថ្វាយបង្គំព្រះសាស្តាចារ្យទូលពតិមាននោះចំពោះព្រះអង្គអំពីហេតុ នៃសុប្បិយបរិញ្ជកជាអាចារ្យដែលទាស់ទែងគ្នា ។ តទា កាលេ ឰដ៏កាលនោះ សម្តេចព្រះបរម៏

សាស្តាចារ្យក៏ទ្រង់សំដែងព្រហ្មជាលសូត្រជាទីសណ្តាប់នៃជនទាំង ៥០០ មាន ព្រហ្មទត្តមាណពនេះឯងប្រធានលុះចប់កាលណាហើយ ជនទាំងនោះ ក៏បាន សម្រេចមគ្គផលទីទៃ ៗ កាលត្រានោះឯង ។ បពិត្រព្រះអរិយកស្សបអើយ ខ្ញុំអានន្ទនាំនិទានក្នុងព្រហ្មជាលសូត្រ ដោយសង្ខេបតែប៉ុណ្ណោះឯង សូមទ្រង់ជ្រាប ។

បុ. ១០- តំ សុត្វា ថេរោ មហាកស្សបោ ព្រះមហាកស្សបត្ថេរ កាលណាបើបានស្តាប់ថេរវាចានៃអានន្ទអ្នកនាំនិទានមកសំដែងក្នុងព្រហ្មជាលសូត្រដូច្នោះហើយ ទើបមានថេរវាចាទៅថា សាធុ សាធុ អានន្ទអើយ អ្នកសំដែងកក្នុងព្រហ្មជាលសូត្រនេះ ពេញជាពីរោះក្បោះក្បាយទូលាយត្រូវតាមព្រះពុទ្ធដីកាហើយអានន្ទអើយ ឥឡូវយើងចង់ដណ្តឹងសួរអ្នកឲ្យបានពិស្តារតទៅទៀត ។ អានន្ទអើយកស្សបបងមានសេចក្តីសង្ស័យចំពោះមនុស្សយើងសព្វថ្ងៃ កើតមកក្នុងលោកនេះមិនត្រូវគ្នា អ្នកខ្លះកើតមកមានសម្បត្តិច្រើន តែគ្មានបងប្អូនញាតិឯលានសន្តានគេមិនសូវចូលចិត្ត. អ្នកខ្លះមានសន្តានបងប្អូនច្រើនតែគ្មានទ្រព្យសម្បត្តិផងទាំងពួង តើដោយហេតុដូចម្តេចហ្ន៎ អានន្ទ ចូរអានន្ទអ្នកអធិប្បាយស្រាយជាសណ្តាប់ប្រាប់បពិត្រផងទាំងពួងរាល់គ្នាមកមើលហ្ន៎អានន្ទអ្នក?

ទិ. ១០- អានន្ទោ តំ សុត្វា អានន្ទអ្នក កាលណាអើ

បានស្តាប់ថេរវាទាមហាកស្សបត្ថេរសួរដូច្នោះហើយ អ្នកក៏មានថេរវាចាថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអើយ យោ បុគ្គលោ រីបុគ្គលឯណាមួយមានចិត្តប្រកបដោយញាណសម្បយុត្ត គ្មានអ្នកឯណាមួយមកជួយរំលឹកដាស់តឿនក្នុងការកុសលឡើយ មានសទ្ធាគិតធ្វើបុណ្យឲ្យទានកាលណា ក៏មិនបានបបួលអ្នកដទៃឲ្យធ្វើបុណ្យទានជាមួយនឹងអាត្មា ព្រោះហេតុខ្លាចទាស់ទែងគ្នា ហេតុប្រការដូច្នោះបានជាអ្នកនោះកើតមកក្នុងជាតិឥឡូវនេះ មានទ្រព្យ ៣ ហើយរកបងប្អូនគ្មាន ទោះបីអ្នកនោះនឹងយកអ្នកដទៃធ្វើជាញាតិឲ្យទ្រព្យសម្បត្តិប្រើប្រាស់ចាយវាយដល់ប៉ុន្មានក្តី ក៏បង្កើតជាទោសទៅវិញ ព្រោះហេតុតែអកុសលចិត្តតិកខុសមកអំពីជាតិមុន ។

បុគ្គលជំពូក ១ វិញទៀត កាលបើនឹងធ្វើបុណ្យឲ្យទានហើយ មានចិត្តប្រកបដោយមច្ឆរិយកំណាញ់ កើតឡើងក្នុងគ្រានោះ ម្ល៉ោះហើយក៏ដើរបបួលអ្នកដទៃបញ្ចុះបញ្ចូលអ្នកដទៃឲ្យគេរាល់គ្នាធ្វើ ឯអាត្មាសោតមិនបានយកទ្រព្យទៅចាយវាយធ្វើបុណ្យឲ្យទានឡើយ ហេតុដូច្នោះហើយអ្នកនោះកើតមកកាលណា មានបងប្អូនសាច់សន្តានគេសឹងតែមានទ្រព្យសម្បត្តិរាល់គ្នា ឯអាត្មាឯងជាអ្នកកំសត់ពិបាក ទោះបីបងប្អូនគេជួយសង្គ្រោះដល់ប៉ុន្មានក្តី នឹងធ្វើជាអ្នកមានមិនបានឡើយគ្រាន់តែចិញ្ចឹមជីវិតអាត្មា ព្រោះពីស៊ុះដោយចិត្តកំណាញ់នោះឯង ឲ្យតែប្រយោជន៍អ្នកដទៃហេតុផលនោះឯង បានជាអស់បងប្អូនគេជួយចិញ្ចឹមជីវិត

វិញ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ខ្ញុំអាននូនាំសេចក្ដីដោះស្រាយពីបុគ្គល ២ ជំពូកមានសភាពដូច្នេះឯង សូមទ្រង់ជ្រាប ។

ឋុ. ១១ — សាធុ សាធុ អាននូអើយ ចម្លើយអ្នកឆ្លើយដោះស្រាយអំពីបុគ្គលទាំងពីរជំពូកនេះ កស្សបខ្ញុំចូលចិត្តហើយ ចូលចិត្តទៀត អើអាននូអើយ អាននូ កស្សបបងនៅសង្ស័យតទៅទៀត អើអាននូអើយដូចបុគ្គលខ្លះ កើតមកមានបងប្អូនសាច់សន្ដានសឹងតែមានទ្រព្យសម្បត្តិច្រើនហើយរាប់អានគ្នា, អ្នកខ្លះកើតមកជាអ្នកកំសត់អត់ឃ្លាននឹងរកធី ក៏មិនផ្អែតពោះសោះ ទោះបីក៏នឹងខ្ចីបុលគេក៏គេមិនឲ្យនោះតើមានប្រការដូចម្ដេច អាននូអ្នក ចូរសំដែងមកកស្សបបងនឹងស្ដាប់ផងហ៎ះអាននូអ្នក ?

ចិ. ១១— តំ សុត្វា អាននូអ្នកកាលណាបើបានស្ដាប់ថេរវាចា ព្រះមហាកស្សបអ្នកដណ្ដឹងសួរពីបុគ្គលពីរជំពូក ដូច្នោះហើយអ្នកក៏ឆ្លើយថា កស្សបបពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីឯបុគ្គលជំពូក ១ កើតមក មានទ្រព្យសម្បត្តិច្រើន បងប្អូនត្រកូលសឹងតែមានច្រើន ទ្រព្យសម្បត្តិក៏មានច្រើនដូចគ្នា អ្នកនោះកាលពីជាតិមុនឡើយ បើនឹងគិតធ្វើបុណ្យទានក៏មានចិត្តនោះត្រេកអរក្នុងផ្ទាយសន្ដាន មានមេត្តាករុណា រីអ្នកកំសត់ទុគ៌តក៏បបួលឲ្យចូលនឹងអាត្មា ខ្លះខាតត្រង់ណាជួយទំនុកបំរុង ក៏កើតបានជាកុសល ហេតុដូច្នោះហើយ អ្នកនោះកើតមានទ្រព្យសម្បត្តិស្មើគ្នា គ្មានទាស់ទែងគ្នាឡើយ ។

បុគ្គលជំពូក ១ វិញទៀត ថាបើបងប្អូនញាតិសន្ដាន គេនៅបបួលធ្វើបុណ្យ

ក្រោយទៀត ចិត្តនោះមិនត្រេកអរ មានតែស្រងីស្រងោកបោះបង់ទៅ រកតែវិញ ព្រោះតែកម្មនោះឯង ក៏បង្កើតជាអ្នកកំសត់ទុគ៌តអត់ឃ្លាន បើនឹងទៅរកខ្ចីបុលគេ ក៏គេមិនឲ្យដោយកម្មអកុសលពីដើមមក ។ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ខ្ញុំអានន្ទអធិប្បាយក្នុងសប្បុរសនិងអសប្បុរសទាំងពីរនេះ មានសភាពយ៉ាងនេះឯងសូមទ្រង់ជ្រាប ។

ប. ១២ – សាធុ អានន្ទអើយ អ្នកអធិប្បាយក្នុងបុគ្គល ៤ ជំពូកនេះ ត្រូវតាមព្រះពុទ្ធឱស្ឋទ្រង់ប្រោសប្រទានហើយ ខ្ញុំកស្សបគ្មានសង្ស័យឡើយ អើ អានន្ទអើយ យើងនឹងចង់ដណ្ដឹងសួរអ្នកតទៅទៀតថា ដូចជាបុគ្គលខ្លះមានទ្រព្យសម្បត្តិ ហើយមិនបានបរិភោគប្រើប្រាស់ស្លៀកពាក់ធ្វើបុណ្យឲ្យទានឡើយ ហើយស្លាប់ទៅចោលទ្រព្យសម្បត្តិនេះ ១ ជំពូក១ទៀតអ្នកខ្លះ រករបស់ទ្រព្យបានច្រើនហើយអន្តរាយ មានចោរលួច ភ្លើងឆេះ លង់ទូក កើតក្ដីគេលក់ពិន័យ លេងបៀរប៉ោវឆ្នោត កំសាត់ តើដូចម្ដេចហ្ន៎អានន្ទអ្នក ចូរអធិប្បាយប្រែស្រាយនូវបុគ្គលទាំងពីរប្រការ កស្សបបងនឹងស្ដាប់ផង ហ្ន៎អានន្ទអ្នក ?

ឆ. ១២ – តំ សុត្វា អានន្ទអ្នកកាលណាបើបានស្ដាប់ថេរវាចា ព្រះមហាកស្សបអ្នកដណ្ដឹងសួរនូវបុគ្គល២ប្រការដូច្នោះហើយ អ្នកក៏ឆ្លើយថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ យោបុគ្គលោ រីបុគ្គលឯណា ១ មានទ្រព្យសម្បត្តិហើយស្លាប់ទៅចោលទ្រព្យនោះឥតបានប្រើប្រាស់ កាលមុនឡើយធ្វើបុណ្យឲ្យទានកាលណាក៏សម្លាប់បំផ្លាញជីវិតសត្វដោយខ្លួនឯង ហើយយក

មកធ្វើបុណ្យឲ្យទានហេតុដូច្នេះ អ្នកនោះកើតមកមានទ្រព្យច្រើន តែជាអ្នកអាយុខ្លី មិនបាននៅបរិភោគទ្រព្យសម្បត្តិនោះឡើយ ក៏ស្លាប់ទៅអស់ការឥតការ ដោយអំណាចសម្លាប់គេយកមកធ្វើការកុសល ផលនោះជួយឲ្យបានទ្រព្យតែបែរជាមានអាយុខ្លីទៅវិញ ។

ជំពូក១វិញទៀត អ្នកខ្លះកើតមករកទ្រព្យបាន តែមានសេចក្តីអន្តរាយទ្រព្យសម្បត្តិនោះទៅវិញ កាលជាតិមុនឡើយ ធ្វើបុណ្យឲ្យទានកាលណាចិត្តនោះបៀតបៀនយកទ្រព្យសម្បត្តិអ្នកដទៃ មកធ្វើបុណ្យឲ្យទាន ហេតុដូច្នេះ អ្នកនោះកើតមកកាលណា ក៏រកទ្រព្យសម្បត្តិបាន ហើយអន្តរាយទៅ បពិត្រព្រះអរិយកស្សបអើយ សូមទ្រង់ជ្រាប ។

ចុ. ១៣ — សាធុ អាននូអើយ ចំលើយអ្នកឆ្លើយ ៗកនេះពីរោះ ពេកហើយអាននូអើយ តែកស្សបបងសង្ស័យនឹងសេចក្តីដែលអ្នក សម្តែងអំពីបុណ្យនោះ ចុះដូចជាអ្នកខ្លះមានទ្រព្យច្រើននៅក្នុងផ្ទះអាត្មា នឹងធ្វើការកុសលណាក៏ខ្លាចខាតបង់ហើយទៅសម្លាប់បំបាត់ជីវិតសត្វយកមកធ្វើបុណ្យឲ្យទាននេះ, មួយវិញទៀត អ្នកខ្លះទៅលួចទ្រព្យគេដូចជាត្រីបន្លែគេក្តី ពុំទិញពុំដូរដូចគេផងទាំងពួងឡើយ ខ្លាចអស់របស់ទ្រព្យអាត្មានោះ តើមានប្រការដូចម្តេចហៈអាននូអ្នក ? ចូរអ្នកអធិប្បាយបរិយាយស្រាយប្រាប់មកកស្សបបង នឹងចង់ស្តាប់មើលហៈអ្នក ?

**ឆ. ១៣- ភន្តេ កស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ខ្ញុំ

ព្រះករុណានឹងអធិប្បាយតាមព្រះពុទ្ធដីកា ដែលទ្រង់សំដែងថា **មនោ បុព្វង្គមា ធម្មា** ជាដើមជាប្រធាន សម្តេចព្រះទ្រង់ញាណទ្រង់មានព្រះពុទ្ធដីកាថា ចិត្ត ជាអធិបតិ ជាប្រធាននៃបុគ្គលទាំងពួងដែលកើតចិត្តជ្រះថ្លាកាលណាហើយ កុសល ក៏កើតកាលគ្រានោះឯង អ្នកឯណា ១ ដែលធ្វើបុណ្យឲ្យទាន កាលគ្រានោះឯង មានចិត្តកំណាញ់មិនចេញទិញផ្សារ ដូចជាអស់គេឡើយ ហើយទៅបំបាត់ជីវិត លួចទ្រព្យអ្នកដទៃយកមកធ្វើបុណ្យឲ្យទាន សម្តេចព្រះដ៏ទ្រង់ញាណទ្រង់សំដែង ថា គ្មានប្រយោជន៍អ្វីសោះអាសារឥតការ បពិត្រព្រះអរិយកស្សបអើយ សូម ទ្រង់ជ្រាប ។

**បុ. ១៤– កស្សបត្ថេរោ តំ សុត្វា** ព្រះកស្សបត្ថេរ កាលណា បើបានស្តាប់អានន្ទ អ្នកដោះស្រាយតាមព្រះពុទ្ធដីកាហើយអ្នកក៏ចូលចិត្ត ហើយរឹង ចូលចិត្ត តែអ្នកដណ្តឹងសួរទៅទៀតថា អានន្ទអើយ ដូចជាបុគ្គលខ្លះ មាន ទ្រព្យសម្បត្តិច្រើនអំពីក្មេង ដល់ចាស់បែរជាខ្សត់ខ្សោយវិញ បុគ្គលខ្លះខ្សត់ ខ្សោយពីក្មេង ដល់ចាស់ប្រែថាមានទ្រព្យសម្បត្តិវិញនេះ តើហេតុដូចម្តេចហ្ន៎ះ អានន្ទអ្នក ចូរអ្នកចាត់ចែងសំដែងមកកស្សបបងនឹងស្តាប់ផងណាះអានន្ទអ្នក ?

**វិ. ១៤- តំ សុត្វា ថេរោ** បពិត្រ វព្រះអានន្ទត្ថេរនោះ កាលណាបើបានស្តាប់ថេរវាចាព្រះមហាកស្សបត្ថេរ អ្នកដណ្តឹងសួរដូច្នោះហើយ

អ្នកមានថេរវាចាថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សប អម្ចាស់អើយ យោ បុគ្គលោ រីបុគ្គលឯណា ១ មានសម្បត្តិទ្រព្យអំពីក្មេង ដល់ចាស់ក៏ខ្សត់ខ្សោយវិញ អ្នកនោះឯងកាលជាតិមុនឡើយធ្វើបុណ្យឲ្យទានតែអំពីក្មេងដល់ចាស់កំណាចកំណាញ់វិញមិនធ្វើបុណ្យឲ្យទានឡើយ ហេតុដូច្នោះបានជាអ្នកនោះ កើតមកមានទ្រព្យតែពីក្មេងដល់ចាស់ខ្សត់ខ្សោយវិញ ។

ចំណែកឯអ្នកខ្សត់អំពីក្មេងដល់ចាស់មានទ្រព្យសម្បត្តិយសសក្តិវិញ អ្នកនោះកាលជាតិមុនឡើយ កំណាចកំណាញ់តែអំពីក្មេង ដល់ចាស់បែរជាមានសទ្ធាជ្រះថ្លាធ្វើបុណ្យឲ្យទានវិញ ហេតុដូច្នោះ អ្នកនោះកើតមកខ្សត់ពិបាកតែអំពីក្មេង ដល់ចាស់មានទ្រព្យសម្បត្តិវិញ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ១៥- សាធុ អានន្ទអើយ ចម្លើយអ្នកឆ្លើយមកនេះពេញពោរជាពីរោះពេកហើយ អានន្ទអើយយើងសង្ស័យ នឹង មនុស្ស កើត មក សព្វថ្ងៃមានសម្បត្តិមិនស្មើគ្នា អ្នកខ្លះកើតមកជាអ្នកមានធំ ខ្លះមានបង្គួរ ខ្លះមានគ្រាន់តែចិញ្ចឹមជីវិត បុគ្គលទាំង ៣ ជំពូកនេះតើមានប្រការដូចម្តេចហៈអានន្ទអ្នកចូរអ្នកសំដែងមក ដើម្បីកស្សបឯងនឹងបានស្តាប់ហៈអានន្ទ ?

ឆ. ១៥- តំ សុត្វា អានន្ទោ កាលណាបើបានស្តាប់

ថេរវាចា ព្រះអរិយកស្សបដណ្តឹងសួរដូច្នោះហើយ អានន្ទអ្នកឆ្លើយទៅថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបដ៏ចំរើនអើយ ឯបុគ្គល ៣ ជំពូកនេះ បានជាមិនត្រូវគ្នាដោយកិរិយាធ្វើមានសភាពផ្សេងអំពីគ្នា អ្នកខ្លះធ្វើសាមិទាន ក៏បានសម្បត្តិជាធំក្រៃលែងជាងបុគ្គលទាំងពួង, អ្នកខ្លះក៏មានបង្គួរ អ្នកនោះធ្វើតែសហាយទាន បុគ្គល ១ ជំពូកទៀតមានទ្រព្យសម្បត្តិ គ្រាន់តែចិញ្ចឹមជីវិតដូច្នេះកាលពីជាតិមុនឡើយ ធ្វើតែត្រឹមទាសទាន បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ១៦— កស្សបត្ថេរោ តំ សុត្វា កាលណាបើបាន ស្តាប់ថេរវាចាអានន្ទអ្នកសំដែងមកដូច្នោះហើយ អ្នកក៏ដណ្តឹងតទៅទៀតថា អានន្ទអើយ អ្នកសំដែងអំពីបុគ្គលទាំង ៣ ជំពូកកស្សបបងចូលចិត្តហើយ តែអស់បពិត្រសប្បុរសជនទាំងពួង ឃើញនៅមានការសង្ស័យនឹងទានទាំង ៣ គឺ សាមិទាន សហាយទាន និងទាសទាននោះ តើដូចម្តេច ? ចូរអានន្ទអ្នកចាត់សំដែងអធិប្បាយប្រែស្រាយជាសណ្តាប់ប្រាប់អស់បពិត្រជនទាំងពួង នឹងបានស្តាប់រាល់គ្នាមើលហ្ន៎ៈអានន្ទអ្នក ?

វិ. ១៦- អានន្ទោ តំ សុត្វា រីព្រះអានន្ទត្ថេ អ្នកបាន ស្តាប់ថេរវាចា ព្រះមហាកស្សបអ្នកដណ្តឹងសួរដូច្នោះហើយ អ្នកក៏ឆ្លើយវិញថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីទានទាំង ៣ ជំពូកនេះ

សម្ដេចព្រះសាស្ដាចារ្យ ទ្រង់សំដែងថា សាមិទានមានផលប្រសើរណាស់ បើបុគ្គលឯណានឹងធ្វើនោះ ដូចជាពួកអ្នកកំសត់មានតែចង្កឹះ ១ ច្រកដណ្ដាំបាយនឹងស៊ី ហើយមានចិត្តជ្រះថ្លាឲ្យទៅជាទានសមណព្រាហ្មណ៍ ហានលះបង់ជីវិតអាត្មាមិនបានបរិភោគឡើយ បពិត្រអើយ ទាននេះឯងឈ្មោះថាជាសាមិទាន ។

ឯសហាយទាននោះ ដូចជាអ្នកទាំងពួងមានទ្រព្យជាសម្លាញ់ ដូចជាអ្នកមានហូលព្រៃក្ដី តែទុកដាក់លាក់រក្សាលុះមានសទ្ធាកាលឯណាហើយ ក៏យកទៅបូជាធម៌ជាទានក្ដី ឲ្យទៅស្មូមយាចកក្ដី ទាននេះឈ្មោះថាសហាយទាន ។

រីឯទាសទាន នោះដូចជាទ្រព្យសម្រាប់អាត្មាប្រើប្រាសសព្វថ្ងៃ ទឹងធ្វើបុណ្យកាលណា យកទៅធ្វើជាទាននោះឯង បានជាគេហៅថាទាសទាន បពិត្រព្រះអរិយកស្សបអើយ បានជាខ្ញុំអានន្ទសំដែងដូច្នោះ ព្រោះតាមព្រះពុទ្ធដីកាទ្រង់សំដែងទុកមកថា ទានទាំងអស់នេះសាមិទានប្រែថាទានជាម្ចាស់ ឯសហាយទាននោះ ថាដូចជាខ្ញុំកំដរប្រើប្រាស់សព្វថ្ងៃ ។ បពិត្រព្រះអរិយម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ១៧– កស្សបត្ថេរោ តំ សុត្វា ព្រះមហាកស្សបត្ថេរកាលណាបើបានស្ដាប់អនុមោទនា ដែលមហាអានន្ទបានសំដែងអំពីទានទាំង ៣ ប្រការហើយ អ្នក[illegible]ទៅថា អានន្ទនើយអ្នកសំដែងមកនេះហៅ

ត្រូវតាមព្រះពុទ្ធដីការហើយ អើអានន្ទអើយ យើងនឹងសួរអ្នកទៅទៀត ថា ដូចជាសាមីទានទៀតសោត កម្រក្រក្រៃនឹងមានអ្នកឯណាធ្វើ ប្រសិនបើមានអ្នកឯណាធ្វើបានជាសាមីទានតែម្តងនេះ តើនឹងបានមគ្គផលដូចម្តេចខ្លះហ្ន៎អ្នក ? ឯសហាយទាន និងទាសទាននេះ តើនឹងបានមគ្គផលដូចម្តេចដែរ ចូរអានន្ទអ្នកអធិប្បាយប្រែស្រាយប្រាប់មកបពិត្រផងទាំងពួងរាល់គ្នា. មើលហ្ន៎អានន្ទអ្នក ?

ទី. ១៧_ កំ សុត្តា អានន្ទអ្នកកាលណាបើបានស្តាប់ព្រះមហាកស្សបត្ថេរអ្នកបង្គាប់ឲ្យសំដែងដូច្នោះហើយ អានន្ទក៏មានបវរវាចា ដូច្នេះ ថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ យោ បុគ្គលោ បុគ្គលឯណា ១ ធ្វើសាមីទានបានតែម្តងហើយ អ្នកនោះនឹងបានទៅសោយសម្បត្តិសុគតិដាន់ចាតុម្មហារាជិកា លុះអស់អាយុអំពីនោះហើយក៏ឡើងទៅកើតនៅឋានតាវត្តិង្សសួគ៌ លុះអស់អាយុអំពីនោះទៅ ក៏ទៅកើតនៅយាមាសួគ៌ លុះអស់អាយុទៅ ក៏ទៅកើតនៅឋានតុសិត លុះអស់អាយុពីតុសិតទៅ ក៏បានទៅកើតនៅនិម្មានរតីសួគ៌ លុះអស់អាយុពីនោះទៅ ក៏ទៅកើតនៅបរនិម្មិតវសវត្តី លុះអស់អាយុទៅ ក៏ចុះមកកើតក្នុងយាមាវៀងៗ មកដល់ចាតុម្មហារាជិកា សាវចុះសាវឡើងទៅមក តែក្នុងសួគ៌ទាំង ៦ ជាន់គម្រប់ ៦ ជាតិ ក្នុងខន្ធនីមួយ ៗ កំណត់ ១ សែនកល្ប សេសសល់ផលអំពីកាមាវចរសួគ៌វិញ

ក៏បានសម្រេចមគ្គផលបាននិព្វាន ។ បើនៅក្នុងកាលវដ្តសង្សារនឹងបានសោយសម្បត្តិដូចអនុរុទ្ធត្ថេរ កាលនៅជាគហ្ពតីបុរសនោះ ព្រោះបានធ្វើសាមីទាន តាំងចិត្តប្រាថ្នា មិនឲ្យស្គាល់ត្បាន ។ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សាមីទាននេះ បើបុគ្គលឯណាធ្វើបានរ:មួតក្តីក៏បាន សោយផលដូចជាអនុរុទ្ធត្ថេរដូច្នោះឯង មួយវិញទៀត ដូចជាសហាយទាន បើបុគ្គលឯណា ១ បានធ្វើសហាយទានហើយនឹងបានកើតក្នុងស្ថានតាវតិង្សសួគ៌ អស់កំណត់ពីតាវត្តិង្សសួគ៌ នឹងបានមកកើតក្នុងស្ថានចាតុម្មហារាជិកាសួគ៌, លុះអស់អាយុអំពីចាតុម្មហារាជិកា នឹងបានមកកើតជាស្តេចសាមន្តរាជ ឬទេសរាជ សេសសល់ផលមកក៏បានមកកើតជាសេនីយមន្ត្រីរៀងទៅ ។ ឯសហាយទាន បានផលតែយ៉ាងកណ្តាល បើនឹងបានជាស្តេច ៗ នោះមិនចំណុះគេ តែនឹងរកគេចំណុះខ្លួនវិញគ្មានឡើយ, បើសេនីយមន្ត្រីអ្នកមានក្តីមានតែយ៉ាងកណ្តាល ។ បពិត្រព្រះអរិយកស្សប នេះផលទាសយទាន បើបុគ្គលឯណាធ្វើហើយ នឹងបានទៅកើតជាទេវតានៅចាតុម្មហារាជិកាសួគ៌ លុះអស់អាយុទៅក៏មកកើតនៅនាមនុស្សលោកនេះ បានជាស្តេចបទេសរាជចំណុះស្តេចដទៃ ពីព្រោះតែដោយខ្លួនអំណាចធ្វើទានយ៉ាងចង បានតែទាសទាន , អ្នកនោះកើតក្នុងមនុស្សលោកយើងនេះ ទោះបីជាសេដ្ឋីកុដុម្ពីក៏ ឬជាស្តេចក៏បានយ៉ាងកណ្តាល បើកើតទៅជារាស្ត្រគ្រាន់តែចិញ្ចឹម

ជីវិតគ្រប់គ្រាន់ ។ បពិត្រព្រះអរិយកស្សបដ៏ម្ចាស់ សូមទ្រង់ផ្រាម ។

ឬ. ១៨- សាធុ អាវុសោ អានន្ទ ម្នាលអាវុសោអានន្ទ ហើយ ចម្លើយអ្នកឆ្លើយមកនេះ ពីរោះពេកហើយអានន្ទអើយ យើងបានទោទ ឆ្លើយអំពីបុគ្គលទាំងពួងធ្វើទានមានសភាពដូចជាសំដែងមកនេះអានន្ទអើយ កស្សប បងនៅសង្ស័យនឹងបុគ្គលទាំងពួង កើតមកមានរូបល្អអាក្រក់ផ្សេង ៗ អំពីគ្នានោះ តើមានប្រការដូចម្ដេចហ្ន៎អានន្ទអ្នក ចូរអានន្ទសំដែងមក កស្សបបងនឹងចង់ស្ដាប់មើលហា អានន្ទអ្នក ?

ទិ. ១៨- ថេរោ តំ សុត្វា អានន្ទត្ថេរ កាលណាបើបាន ស្ដាប់ថេរវាចា ព្រះមហាកស្សបត្ថេរ, អ្នកសណ្ដាំងអំពីបុគ្គលមានរូបល្អអាក្រក់ ដូច្នោះហើយអ្នកមានថេរវាចាថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សប អម្ចាស់អើយ វីបុគ្គលឯណាមួយមានរូបអាក្រក់ មិនជាទីស្រឡាញ់នៃអ្នកផង ទាំងពួង កាលពីជាតិមុនឡើយ មិនបានឧស្សាហ៍ព្យាយាមរក្សាសីល ហើយស្រដីបោះបោកបញ្ឆោរទៅឲ្យគេថា បើឯងរក្សាសីល រក្សាតែឯងទៅ ចុះ ហេតុដូចនេះអ្នកនោះកើតមកក្នុងជាតិឯណាក្តី នឹងមានរូបអាក្រក់វិស័យ ជាប្រេតតិរច្ឆានគ្មានគេស្នេហាចូលចិត្ត ពីព្រោះតែស្រដីពាក្យទសុរោះទៅកាន់ អ្នកដ៏មានសីល ។

មួយវិញទៀត អ្នកខ្លះកើតមកមានរូបល្អ ជាទីស្រឡាញ់នៃទេវតា មនុស្សម្នាទាំងពួង នោះកាលជាតិមុនឡើយ ជាអ្នករក្សាសីល ពិព្យាយាមមិនឲ្យសៅហ្មង ហេតុដូច្នោះ . អ្នកនោះកើតមកមានរូបល្អគ្រប់ បញ្ចេន្ទ្រិយ គ្មានអាក្រក់ត្រង់ណាមួយ បពិត្រព្រះអរិយកស្សបម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ១៨- ថេរោ តំ សុត្វា ព្រះកស្សបត្ថេរ អ្នកទ្រង់សវនានឹងអានន្ទអ្នកសំដែងដូច្នោះហើយ អ្នកសព្វព្រះទ័យហើយមានថេរវាចាថា សាធុ អានន្ទអើយ អ្នកឆ្លើយមកនេះ យើងចូលចិត្តហើយ អ្នកឆ្លើយមកនេះ យើងចូលចិត្តហើយ អើអានន្ទអើយអានន្ទយើងសួរអ្នកទៅទៀតថា ដូចជាអ្នកខ្លះកើតមកមានរូបនោះអាក្រក់ តែមានទ្រព្យសម្បត្តិត្រកូលជាពង្សខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម មានអំណាចលើអ្នកមានរូបល្អវិញនោះ តើមានប្រការដូចម្ដេចហ្ន៎ អានន្ទអ្នក ?

ចំ. ១៨- តំ សុត្វា អានន្ទត្ថេរោ បពិត្រអើយ គ្រានោះព្រះអានន្ទត្ថេរនិមិត្តតែបានស្ដាប់ថេរវាចាព្រះមហាកស្សបត្ថេរ ផ្ដាំងសួរដូច្នោះ ហើយអ្នកឆ្លើយថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបម្ចាស់អើយ រីអ្នកដែលមានរូបគំរ័បគំបាក់ ត្រងោលត្រគាលក្បាលទំពែក គង់តែជាយ ព្រោះនោះកាលពីជាតិមុន ជាអ្នកឧស្សាហ៍ប្រណិប័តន៍ទានមិនឲ្យដាច់ តែងនឹកទុំនុកបំរុងក្នុងព្រះពុទ្ធ

សាសនា ឬជាគ្រែធម្មាសន.ក្រឡាសំណឹងគ្រប់ប្រការ ហេតុដូច្នោះអ្នកនោះ កើតមកបានត្រកូលខ្ពង់ខ្ពស់ឧត្តុង្គឧត្តម សមនឹងអាមាត្យមុខមន្ត្រីប្រកបទៅដោយនូវទ្រព្យសម្បត្តិច្រើន ព្រោះដោយនូវអំណាចបានថ្វាយទ្រព្យទៅជាទានមិនកំណាញ់ឡើយ បពិត្រអើយអ្នកដ៏មានរូបអាក្រក់ ព្រោះមិនព្យាយាមរក្សាសីលឡើយ បើទទួលសីលហើយឲ្យដាច់សីលមួយរំពេច ។

ឯអ្នកមានរូបល្អ ហើយខ្សត់ទ្រព្យសម្បត្តិ បំរើបម្រើអ្នកដ៏មានទ្រព្យសម្បត្តិច្រើននោះវិញ អ្នកនោះកាលជាតិមុនឡើយ មានចិត្តព្យាយាមឧស្សាហ៍រក្សាសីលបរិសុទ្ធល្អ តែកំណាញ់ទ្រព្យរបស់មិនឧស្សាហ៍ធ្វើបុណ្យឲ្យទាន ដូច្នេះបានជាអ្នកនោះកើតមកមានរូបល្អ ជាទីស្រឡាញ់នៃជនផងទាំងពួង. ហេតុដែលនាំឲ្យខ្សត់សម្បត្តិ ព្រោះមានចិត្តកំណាញ់មកពីដើម បពិត្រព្រះអរិយកស្សបអើយ សូមទ្រង់ជ្រាប ។

ឫ. ២០- សាធុ សាធុ អាវុសោ ម្នាលអាវុសោ អានន្ទអើយ ចម្លើយអ្នកឆ្លើយដោះសារនូវបុគ្គល ២ ប្រការ កស្សបបងចូលចិត្តហើយ អើអានន្ទអើយ អ្នកសំដែងមកនេះ ពេញជាត្រូវហើយពីរោះផង ឥឡូវកស្សបបងនឹងសួរអ្នកតទៅទៀត ដូចជាអ្នកខ្លះកើតមកមានប្រាជ្ញស្មារតី ដោះសារអាថ៌ប្រស្នាផងទាំងពួងគ្មានទើសទាល់សល់ជំពាក់ អ្នកខ្លះកើតមកជាអ្នកខ្លៅអាប់ឥតប្រាជ្ញា អ្នកទាំងពីរប្រការបានជាមានភេទផ្សេង ៗ ពីរគ្នានោះតើមានប្រការដូចម្តេច ចូរអានន្ទឆ្លើយមកមើលបោះអ្នក ?

**ថ. ២០– តំ សុត្វា ថេរោ** ព្រះអានន្ទត្ថេរ កាលណាបើបានស្ដាប់ព្រះមហាកស្សបត្ថេរចោទសួរដូច្នោះហើយ ក៏ឆ្លើយថា **ភន្តេ** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ វីអ្នកខ្លះកើតមកមានប្រាជ្ញានោះកាលពីជាតិមុន ជាអ្នកបានឲ្យធម្មទាន ជាវេត្ដីរជាក់វត្តអារាម ហើយឧស្សាហ៍ចំរើនការនាត្រិះរិះពិចារណាសព្វហេតុការគ្រប់យ៉ាង ទើបកើតមកជាតិនេះបានជាអ្នកមានប្រាជ្ញាស្មារតីច្រើន , ឯអ្នកគ្មានប្រាជ្ញានោះវិញ កាលពីជាតិមុនឡើយ មិនបានបូជាព្រះធម៌ធ្វើធម្មទានដូចគេឡើយ ម្ល៉ោះហើយក្នុងជាតិនេះ ក៏គ្មានប្រាជ្ញាដូចគេឡើយ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

**ប. ២១– សាធុ សាធុ** អានន្ទអើយ ចម្លើយអ្នកឆ្លើយមកនេះ ក្បោះក្បាយឆ្ងាយទូលាយងាយចូលចិត្តហើយ អើអានន្ទអើយយើងចង់សួរអ្នកតទៅវិញទៀត ដូចជាបុគ្គលខ្លះកើតមកក្នុងលោកនេះមាន រោគាព្យាធិជរាដំបៅពកក្អកហឺតរបេងរីងរៃនោះ តើបានធ្វើអំពើកម្មនោះដូចម្ដេចហ្នះអានន្ទ ?

**ថ. ២១– ភន្តេ** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ វីអ្នកមានជម្ងឺឈឺចាប់ប្រចាំក្នុងរាងកាយដូច្នេះ មកពីកាលជាតិមុនមិនបានឲ្យទានជាថ្នាំរក្សារោគដល់អ្នកជម្ងឺ ឬអ្នកកំសត់ទុរគតដល់ម្ដងសោះឡើយបាន ជាជាតិនេះមានជម្ងឺប្រចាំកាយដូច្នេះ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ២២- សាធុ អានន្ទអើយ ចំលើយអ្នកឆ្លើយមកនេះត្រូវពិតហើយតែកស្សបបងនឹងចង់ផល្អិងសួរអ្នកតទៅទៀតថា ដូចជាអ្នកខ្លះ កើតមកក្នុងនាលោកិយនេះ មានកាយគមគាត់កំបោទទំលាយលោង ក្លូរក្លែងក្លង់ រីអ្នកទាំងអម្បាលនោះ តើធ្វើអំពើតរុកម្មដូចម្ដេចហ្ន៎ អានន្ទអ្នក ?

ចិ. ២២- តំ សុត្វា អានន្ទត្ថេរោ កាលណា បើបានស្ដាប់ថេរវាចាព្រះមហាកស្សបត្ថេរ ដូច្នោះហើយ ក៏មានវាចាឆ្លើយវិញភ្លាមថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ រីអ្នកកំបាក់ក្លូរក្លែង កាលពីជាតិមុនជាអ្នកកំប្លែងត្រាប់គេសើចលេង កម្មនោះឯងតែងមកបង្កើតផលដល់បុគ្គលទាំងអម្បាលនោះ កំណត់ ៥០០ ជាតិ ដូចនាងខុជ្ជុត្តរាធ្វើត្រាប់តាមព្រះបច្ចេកពុទ្ធ កាលនោះនាងក៏កើតជាស្ត្រីគម ៥០០ ជាតិ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ២៣- កស្សបត្ថេរោ តំ សុត្វា ព្រះមហាកស្សបត្ថេរកាលណាបើបានស្ដាប់ថេរវាចា មហាអានន្ទអ្នកសំដែងមកដូច្នោះហើយក៏ឆ្លើយថា អាវុសោ អានន្ទអើយ យើងនឹងផ្ដើមឯតទៅទៀត ដូចជាអ្នកក្រៅព្រះពុទ្ធសាសនា មានផ្កា បារាំង ក្លិង ជាដើម អស់អ្នកទាំងអម្បាលនោះម្ដេចក៏បានទ្រព្យច្រើន ហើយនគរគេក៏ធំទូលាយ អស់នគរពុទ្ធ

សាសនីបានជាសម្បត្តិតិច ហើយនតរតូចផង តើមានហេតុធ្វើដូចម្តេចហ: អ្នកទាំងអម្បាលនោះតើធ្វើទានដោយសទ្ធិ:សង្ស័យទីទៃ ៗ ឬដូចម្តេចហ:អានន្ទអ្នក ចូរអានន្ទអ្នកចាត់ចែងសំដែងវោហារក្នុងអដ្ឋកថាប្រែស្រាយបរិយាយប្រាប់មក នឹងបានស្តាប់មើល ហ:អានន្ទអ្នក?

ទិ. ២៣- តំ សុត្វា អានន្ទោ ព្រះមហាអានន្ទ កាលណាបើបានស្តាប់ថេរវាចា ព្រះមហាកស្សបត្ថេរ អ្នកដណ្តឹងសួរដូច្នោះហើយ អ្នកក៏ឆ្លើយថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ វីអ្នកទាំងអម្បាលនោះ នឹងធ្វើទានឲ្យបានកើតទ្រព្យសម្បត្តិយសសក្តិ ជាស្តេចអាមាត្យមុខមន្ត្រីអ្វី ៗ ក៏មិនបានឡើយ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ វីអ្នកទាំងអំបាលនោះ កាលជាតិមុនកើតក្នុងពុទ្ធសាសន៍ ជាអ្នករក្សាសីលធ្វើបុណ្យឲ្យទាន តែមានចិត្តនោះអាក្រក់នឹងសមណព្រាហ្មណ៍អ្នកមានសីលតែងទាស់ទែងគ្នា ហើយជេរត្មះតិះដៀលហេតុដូច្នោះ អ្នកនោះលុះរំលាយជាតិកំណើតអំពីក្នុងពុទ្ធសាសនាកាលណា ក៏ទៅកើតជាយក្ស អសុរ ចាមផ្កា បារាំង ក្លិង្គបពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

ប៉ុ. ២៤- អើអានន្ទអើយ កស្សបបងនឹងសួរទៅទៀតថាបើបុគ្គលឯណា ១ បានរក្សាសីល បាណាតែ ១ បានដាក់ប្រាកដហើយ អ្នកនោះឯងនឹងបានទៅកើតនៅស្ថានឯណា ៗ ខ្លះ ហ:អានន្ទអ្នក ចូរចាត់ចែងសំដែង

វោហារក្នុងអដ្ឋកថាប្រែស្រាយអធិប្បាយប្រាប់មកយើង នឹងស្ដាប់រាល់ៗ គ្នា មើលហៈអានន្ទ ?

ទិ. ២៤- ភន្តេ បពិត្រព្រះកស្សបដ៏ចំរើនអើយ សូម លោកម្ចាស់ផ្ទៀងព្រះកាម្ចាទាំងសងខាង ចាំត្រង់ត្រាប់ស្ដាប់ខ្ញុំអានន្ទ នឹង សំដែងថ្វាយថា បើបុគ្គលឯណានីមួយជាអ្នករក្សាសីលបាណាតែ១នោះកាន់ខ្ជាប់ ប្រាកដហើយ វីអ្នកនោះឯង ក៏បានទៅកើតជាស្ដេចធំឧត្តមប្រសើរឰដ៏ឫទ្ធិទ្វីប មានប្រាសាទកែវទាំង៧ មានសម្បុរល្អដូចកែវមុក្ដាមានមុខនោះល្អដូចវង្សព្រះចន្ទ ពេញបូរមី ដ៏មានកំពស់នោះ ៥ ភ្យាម ដ៏មានអាយុ ៨ ម៉ឺនឆ្នាំ បើនឹងចង់ នឹចំណីអាហារអ្វីហើយ ក៏ឡើងទៅលើអាកាសវែ្ហតឯង បើនឹងអស់ជីវិតទៅ ហើយ ពុំបានធ្លាក់នរកឡើយ ហើយបានមកកើតឰដ៏ជម្ពូទ្វីបនោះឯង បាន ជាមហាចក្រពត្រាធិរាជប្រកបទៅដោយសម្បត្តិរតនទាំង៧ប្រការនោះហោង បពិត្រ ព្រះអរយកស្សបគម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ២៥- កស្សបត្ថេរោ តំ សុត្វា ព្រះមហាកស្សបត្ថេរកាលបានស្ដាប់អានន្ទត្ថេរ សំដែងក្នុងសីលបាណា ក៏ចាប់ចិត្តពីរោះណាស់ ហើយ តែកស្សបនៅតែសង្ស័យសួរទៅទៀតថា បើបុគ្គលឯណា ១ នឹង រក្សាសីលអទិន្នាទានតែ ១ នេះខ្ជាប់ប្រាកដកហើយ តើអ្នកនោះឯងនឹងបាន

ទៅកើតនៅស្ថានឯណាហៈអានន្ទអ្នក ចូរអធិប្បាយប្រែប្រួល ការមើល ?

ខ. ២៥- កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ បើបុគ្គលឯណា ១ បានរក្សាសីលអដ្ឋង្គទានតែ ១ នោះខ្ជាប់ប្រាកដហើយ អ្នកនោះឯងបានទៅកើតជាស្តេចធំនៅនគរឧត្តរកុរុទ្វីប មានប្រាសាទ ១ រំង ៩ ហើយមានរូបសម្បត្តិល្អ ប៊ិដូចជាមាសនពគុណមានកំពស់ ៤ ក្បាម មានអាយុនោះ ៥០០ ឆ្នាំ បើនឹងធ្លីចំណាំដោយនូវកាលណា ក៏នឹងមានបរិបូណ៌កើតឯង ថាបើនឹងអស់ជីវិតទៅ ពុំដែលទៅនរកឡើយ ហើយនឹងបានមកកើតក្នុងជម្ពូទ្វីបមនុស្សលោកយើងនេះ នឹងបានជាមហាសេដ្ឋី មានទ្រព្យសម្បត្តិ ១៥០ យ៉ាំងនោះប្រាកដហោង បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

ប. ២៦- អើអានន្ទអើយ កស្សបបងនឹងសួរអ្នកតទៅទៀតថា បើបុគ្គលឯណា១ នឹងរក្សាសីលអុបោសថតែ ១ ខ្ជាប់ហើយ អ្នកនោះឯងនឹងបានទៅកើតក្នុងនគរស្ថានណាហៈអានន្ទអ្នក ?

ខ. ២៦- កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ បើបុគ្គលឯណា ១ នឹងរក្សាសីលអុបោសថតែ ១ ខ្ជាប់ហើយ អ្នកនោះនឹងបានទៅកើតក្នុងអមរគោយានទ្វីប ហើយបានទៅជាស្តេចធំឧត្តម មានរូប

ល្អសម្បុរដូចផ្កាកររតន៍ មុខនោះល្អដូចព្រះចន្ទ ១ ចំហៀង មានកំពស់នោះ ៦ ព្យាម មានអាយុ ៦ ម៉ឺនឆ្នាំ បើនឹងចំអិនចំណី តែនឹងរស្មីព្រះអាទិត្យ ស្ដេចនោះក្ស័យទៅពុំដែលទៅនរកឡើយ សឹងបានមកកើតក្នុងជម្ពូទ្វីបយើងនេះវិញ មានទ្រព្យសម្បត្តិច្រើនកោដិឃ្លាំង បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ២៧- អើអានន្ទអើយ អានន្ទ បើបុគ្គលឯណា ១ បានរក្សាសីលមុសាតែ ១ ខ្ទាប់ប្រាកដហើយ អ្នកនោះឯងនឹងបាន ទៅកើតឋានណាហ្នះអ្នក ?

និ. ២៧- កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ថាបើបុគ្គលឯណាបានរក្សាសីលមុសាតែ ១ ខ្ទាប់ប្រាកដហើយ អ្នកនោះឯងនឹងបានមកកើតជាស្ដេចធំឧត្ដមប្រសើរឮដ៏កំពែងចក្រវាឡ ណាអម្ចាស់សូមទ្រង់ជ្រាប ។

បុ. ២៨- អើអានន្ទអើយ ចុះបើបុគ្គលឯណា ១ បានរក្សាសីលសុរាតែ ១ ខ្ទាប់ អ្នកនោះឯងនឹងបានទៅកើតស្ថានឯណាខ្លះ ហ្នះអានន្ទអ្នក ?

និ. ២៨- កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ថាបើបុគ្គលឯណា ១ បានរក្សាសីលសុរាតែ ១ ខ្ទាប់ហើយ អ្នកនោះនឹងបានកើត

ជាស្តេចធំឧត្តមប្រសើរញ្ញស័ចតុមហារាជិកា  មានអាយុ ៥០០ ឆ្នាំ  នឹងគណនាក្នុងថ្ងៃមនុស្សលោកយើងត្រូវជា ៧ លានឆ្នាំហោង  ទើបបានជា១ថ្ងៃចតុម្មហារាជិកានោះឯង  បពិត្រព្រះអរិយកស្សបអម្ចាស់អើយ  សូមទ្រង់ជ្រាប ។

សុត្តន្តបិដកវសានេ  បពិត្រអើយ  ព្រះមហាកស្សបត្ថេរ  អ្នកបុច្ឆាព្រះសូត្របិដកស្រេចកាលឯណាហើយ  ក៏និមន្តព្រះមហានាគត្ថេរស្វាធ្យាយរាយនូវបទខ្មែរប្រែស្រែកលលាក់លលែក  ចែកសំដែងឲ្យព្រមៗ  គ្នាគ្រប់ៗ  ព្រះអង្គទេវហោង ។

ចប់ព្រះសុត្តន្តបិដក

## បឋមសង្គាយនាវគ្គ ៣

## ព្រះមហាកស្សបចោទសួរព្រះអភិធម្ម
## នឹងព្រះមហាអានន្ទ

## ព្រះមហាអានន្ទ ឆ្លើយព្រះអភិធម្ម
## នឹងព្រះមហាកស្សបត្ថេរ

### ព្រះមហាកស្សបត្ថេរផ្ដើមចោទសួរ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សុត្តន្តបិដកភាគសាវនៃ បពិត្រអើយ កាលបើចប់ព្រះសូត្របិដកស្រេចកាលណាហើយ ព្រះមហាកស្សបត្ថេរក៏ចាប់ផ្ដើមសួរគម្ពីរព្រះអភិធម្មបិដក នឹងព្រះមហាអានន្ទត្ថេរតទៅទៀតថា :

ប. ១_ អភិធម្មំ កតិកប្បមាណំ អាវុសោ អានន្ទ

ម្នាលអាវុសោ អានន្ទអើយ តើសម្ដេចទ្រង់ញាណទ្រង់សំដែងព្រះអភិធម្មបិដកនោះ មានប៉ុន្មានគម្ពីរហេះអានន្ទអ្នក ?

# ព្រះអានន្ទត្ថេរឆ្លើយ

ទិ. ១– នមោ តស្ស ភគវតោ អរហតោ សម្មា សម្ពុទ្ធស្ស ។ អានន្ទោ តំ សុត្វា ព្រះមហាអានន្ទត្ថេរ កាលណាបើបានស្តាប់ថេរវាចា ព្រះមហាកស្សបត្ថេរ អ្នកដណ្តឹងសួរគម្ពីរព្រះអភិធម្មទ្វារហើយ មិនយូរឡើយ អានន្ទ អ្នកក៏សំដែងតាមដោយព្រះពុទ្ធឱស្សប្រាប់ទេសនាថា អយំ អភិធម្មោ សព្វញ្ញុតញ្ញាណំ អរហត្តបត្តកាលេ ។ ភន្តេ កស្សប បពិត្រព្រះអរិយកស្សបម្ចាស់អើយ នាអាចិព្រះអភិធម្មនេះ គឺព្រះអង្គសញ្ជឹងរំពឹងឮដ៏កាល ព្រះអង្គបានសម្រេចការត្រាស់ដឹងហើយ ក៏ព្រះអង្គទេសនាថា មាន ៧ គម្ពីណា អម្ចាស់ សូមទ្រង់ជ្រាប ។

ប៉ុ. ២– កតមំ បករណំ អាវុសោ ម្នាលអាវុសោ អានន្ទអើយ គឺគម្ពីទាំង ៧ នោះ តើមានឈ្មោះអ្វីខ្លះ ៗ ទៅណ៎ះអ្នក ?

ទិ. ២– ភន្តេ កស្សប បពិត្រព្រះអរិយកស្សបម្ចាស់អើយ ថាបើព្រះអង្គពុំទាន់ជ្រាបដូច្នេះ ខ្ញុំព្រះករុណានឹងសម្តែងថ្វាយ តាមដោយព្រះពុទ្ធដីកាព្រះពិធីតមានវាចាអម្ចាស់ ស្តេចទ្រង់ត្រាស់ទេសនា

ថា កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា នេះឯងជាប្រធាន ជាដើមបទ ហើយបើចែកជាគម្ពីរមាន ៧ គម្ពីរដូច្នេះថា បឋមា ធម្មសង្គណិ ទុតិយោ វិភង្គោ តតិយោ ធាតុកថា ចតុត្ថោ បុគ្គលបញ្ញត្តិ បញ្ចមោ កថាវត្ថុ ឆដ្ឋមោ យមកំ សត្តមោ មហាបដ្ឋានំ មាតិកា ។ ភន្តេ បពិត្រព្រះអរិយកស្សប អម្ចាស់អើយ រីព្រះអភិធម្មទាំង ៧ គម្ពីរនេះ មានឈ្មោះយ៉ាងនេះឯង សូមទ្រង់ជ្រាប ។

ប. ៥- មហាកស្សបត្ថេរ កាលណាបើបានស្ដាប់ថេរវាចា ព្រះមហាអានន្ទអ្នកសំដែងមកដូច្នោះហើយ អ្នកក៏ដណ្ដឹងសួរតទៅទៀតថា អានន្ទអើយ ឯការតបគុណអ្នកដ៏មានគុណនោះ តើដូចម្ដេច ? ការដឹងគុណអ្នកដ៏មានគុណនោះ តើដូចម្ដេច ? ការសងគុណអ្នកដ៏មានគុណនោះ តើដូចម្ដេច ? ចូរអានន្ទអ្នកចាត់ចែងសំដែងអធិប្បាយប្រែស្រាយ បរិយាយប្រាប់បពិត្រជនទាំងឡាយ នឹងបានស្ដាប់រាល់គ្នា មើលហ៎ អានន្ទអ្នក ?

ឧ. ៥- ភន្តេ កស្សប បពិត្រព្រះកស្សបអម្ចាស់អើយ ឯការតបគុណអ្នកដ៏មានគុណនោះ មានតែការឲ្យទឹកបញ្ចុកជាយលោងអាច

ច្របាច់ទោមនោះឯង មួយទៀត បើបានចំណីឯណាគាត់ប្រសើរឆ្ងាញ់ៗ ហើយយកទៅជូនលោកដ៏មានគុណពីសា ហៅថាតបគុណ ។ ដំពូក ១ ឯការ ដឹងគុណអ្នកដ៏មានគុណនោះ មានតែតួអក្ខរាអក្សរ ន មោ ក ខ នេះឯង ។ ជំពូកមួយវិញទៀត អ្នកសងគុណ អ្នកដ៏មានគុណ គឺទាល់តែយកព្រះ អភិធម្ម ៧ គម្ពីរនេះ សងគុណទើបបាន បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ៦– អើអានន្ទអើយ អ្នកសំដែងមកនេះ កស្សប បងស្ដាប់ បាន ចូលចិត្តហើយ ពីរោះហើយ អានន្ទអើយ កស្សប បង នៅសង្ស័យថា គុណព្រះមាតា ១២ តើជាគនជាល់តប់ចំបាច់ គុនដីបង ជាវវែង ជាវខ្លី ឬ គុណលេខ ឬ គុណអ្វីហ្ន៎ះអានន្ទអ្នក ?

វិ. ៦– កស្សប បពិត្រព្រះអរិយ កស្សប អម្ចាស់អើយ រីឯគុណ ១២ នោះ មិនគឺ គុនចំបាច់ ជាវវែងខ្លីក៏ទេវែរ ឯគុណមាតា ១២ នោះគឺ តួអក្ខរាអក្ស ន ប ផ ព ភ ម យ រ ល វ ស ហ នេះ ជាគុណមាតាណា អម្ចាស់សូមទ្រង់ជ្រាប ។

បុ. ៧– អើអានន្ទអើយ កស្សប បងនឹងសួរតទៅទៀត ឲ្យតព្យញ្ជនទ្រទ័រថា អានន្ទមានប្រាជ្ញា ប្រតិពលយល់ឆ្ងាយ ធម៌ផង ទាំងឡាយ មិនចេះទើសទាល់ប្រាជ្ញាអានន្ទឡើយ អើអានន្ទអើយ

កុំអ្នកស្លប់ចុះ [illegible]ប្រូបបងឡើយ **អានន្ទអើយ** កាលនាងសិរិមហាមាយា ប្រាថ្នាឲ្យបានជាព្រះកន្សោង ឲ្យបានជាព្រះមាតាពោធិសត្វនោះ ច្រើនជាតិ ច្រើនកំណើត យើងក៏ដឹងហើយ **អើអានន្ទអើយ** **អានន្ទ**កាលពោធិសត្វ មកចាប់បដិសន្ធិនោះ តើតួអក្សរណានាំមកបង្កើតហៈអានន្ទអ្នក ?

ទិ. ៧-- កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ កាលនាងប្រាថ្នាសូមបុត្រនោះ នាងបន់សច្ចាថាឲ្យបានប្រកបនូវបុត្រនោះ ជាអ្នកមានបុណ្យបារមីល្បីឮទូទៅរទៅដល់នគរបរទេស ហើយឲ្យមានចិត្តនោះល្អចំពោះ សមយាចកផងទាំងឡាយ ប្រកបដោយទសពិធរាជធម៌ ទាំង ១០ ប្រការ ព្រះឥន្ទ្របានទៅនិមន្តព្រះពោធិសត្វមកចាប់បដិសន្ធិ គឺតួ ម នេះឯងណាអម្ចាស់សូមទ្រង់ជ្រាប ។

បុ. ៨- អើ អានន្ទអើយ ចុះកាលកើតមកបានជាអង្គហើយនោះ តើតួអក្សរនាំបង្កើតបានជាអង្គនោះ ហៈ អានន្ទអ្នក លុះគ្រប់ ១០ ខែហើយនោះ តើតួអក្សរណានាំចេញមក ហៈ **អានន្ទអ្នក** ក៏ចូលអានន្ទអ្នកចាត់ចែងសំដែងវោហារក្នុងអត្ថគាថាប្រែស្រាយប្រាប់មកកស្សបបងនឹងស្តាប់ផងហ **អានន្ទអ្នក?**

ទិ. ៨- កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ឯការបង្កើតបានជាអង្គនេះ គឺតួ អ នេះឯង បង្កើតជាអង្គគ្រប់បញ្ចិន្ទ្រិយទាំង ៥ បពិត្រព្រះ

អរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ៩- សាធុ សាធុ អានន្ទអើយ ចុះសម្ដេចព្រះបរមលោកនាថសាស្ដាចារ្យទ្រង់សំដែងព្រះធម៌វិសេសទេសនា ព្រះសត្តប្បករណាភិធម្មនោះ តើទ្រង់សំដែងគម្ពីរអ្វីជាមុន ហ្ន៎ អានន្ទអ្នក ?

ថិ. ៩- ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់សំដែងគម្ពីរព្រះធម្មសង្គណីមុនណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ១០- ព្រះមហាកស្សបត្ថេរ ទ្រង់សណ្ដាប់ស្រេចហើយ ក៏ឆ្លើយថា អើអានន្ទអើយ ព្រះពុទ្ធអង្គទ្រង់សំដែងព្រះធម្មសង្គណីនោះ តើមានព្រះធម្មក្ខន្ធនោះប៉ុន្មាន ? មានលក្ខណនោះប៉ុន្មាន ? ចែកចេញជាបទ ជាតិកនោះ តើមានប៉ុន្មានហ្ន៎អានន្ទអ្នក ចូរអ្នកអធិប្បាយស្រាយប្រាប់មកកស្សបនឹងស្ដាប់មើលហ្ន៎អានន្ទអ្នក ?

ថិ. ១០- អានន្ទោ បពិត្រអើយ ព្រះមហាអានន្ទត្ថេរ កាលណាបើបានស្ដាប់ថេរវាចា ព្រះមហាកស្សបសួរផ្ទោះហើយ អ្នកក៏អធិប្បាយតាមព្រះពុទ្ធដីកាថា ភន្តេ បពិត្រព្រះអរិយកស្សបជាអម្ចាស់អើយ សូមផ្ទង់សោតទាំងសងត្រងត្រាប់ស្ដាប់ខ្ញុំ អានន្ទនឹងសំដែងតាមព្រះពុទ្ធអង្គ កាលទ្រង់សំដែង

ប្រោសសម្តេចព្រះមាតាញដ៏តាវត្តីង្សានោះ ទ្រង់ចែកព្រះគម្ពីរធម្មសង្គណិជា ១៣០០ ព្រះធម្មក្ខន្ធ ចែកចេញជាកណ្ឌមាន ៤ កណ្ឌ ចែកជាបទមាន២ ហើយចែកជាតិកមាន២ ណាអម្ចាស់សូមទ្រង់ជ្រាប ។

បុ. ១១ – **សាធុ សាធុ អាវុសោ** អានន្ទអើយ ចម្លើយអ្នកឆ្លើយមកនេះពេញជាពីរោះពេកហើយ អើអានន្ទអើយ កស្សបបងទៅសង្ស័យ ដ្បិតអ្នកនាំសេចក្តីនេះចែកជាពួកជាកង អស់បពិត្រផងទាំងពួង នៅមិនទាន់ចូលចិត្តរាល់គ្នានៅឡើយ, ចុះព្រះធម្មក្ខន្ធនោះតើដូចម្តេច មានតួអក្សរនោះប៉ុន្មាន ហៅថា ១ ធម្មក្ខន្ធ ហើយប៉ុន្មានធម្មក្ខន្ធហៅថាបទ ១ តើមានប៉ុន្មានបទ ហៅថា តិក , តើមានប៉ុន្មានតិកទើបហៅថាកណ្ឌ ចូរអានន្ទអ្នកសំដែងចែកញែកជាពួក ជាកងឲ្យច្បាស់ឃើញប្រាកដ នឹងបានជាទីរណ្តាប់ នៃអស់បពិត្រផងទាំងពួងបានស្តាប់រាល់គ្នា មើលហ៎អានន្ទអ្នក?

វិ. ១១– **អានន្ទត្ថេរោ** បពិត្រអើយ រីព្រះអានន្ទត្ថេរ កាលណាបើបានស្តាប់ថេរវាចាព្រះមហាកស្សបដូច្នោះហើយ ក៏ពិត្រថេរវាចាថា **ភន្តេ កស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់ សូមសវនាខ្ញុំអានន្ទ នឹងសំដែងតាមព្រះពុទ្ធឱស្ឋទ្រង់ប្រោសប្រទានធម្មវិសេសទេសនា ដល់ព្រះពុទ្ធមាតា ទ្រង់មានព្រះពុទ្ធដីកាថា **កុសលា ធម្មា អកុសលា ធម្មា អព្យាកតា**

ធម្មា ដូច្នេះជាដើមបទជាប្រធាន សម្ដេចព្រះសព្វញ្ញុតញ្ញាណ ទ្រង់ចែកជាធម្មក្ខន្ធ នូវ កុសលា នេះជាធម្មក្ខន្ធ ១ ធម្មា នេះជាធម្មក្ខន្ធ ១ បីព្រះធម្មក្ខន្ធ ហៅថា បទនេះឯង រីបទនោះដូចជា កុសលា ធម្មា ដូច្នោះឈ្មោះ ថា មាតិកាឯបទភាជនីយនោះដូចជាបទចុងជាអព្យាកតាធម្មានេះ ហៅថា បទភាជនីយ ឯបទកណ្ដាលមិនបានសំដែងឡើយ បពិត្រព្រះអរិយកស្សប អើយ ហើយឯបទនោះរាប់ ៣ បទដូចជា អកុសលា ធម្មា អព្យាកតា ធម្មា ដូច្នេះបានឈ្មោះថាជា តិក ១ រាប់ដរាបទៅដល់ សនិទស្សនសប្បដិឃា ធម្មា អនិទស្សនសប្បដិឃា ធម្មា ត្រូវជា ២២ បានជាមានព្រះបាលីថា ពាវីសតិ តិកមាតិកា ធម្មសង្គណិ ថាមាន តិក ២២ ក្នុងព្រះអភិធម្មសង្គណិ ឯកណ្ឌនោះព្រះពុទ្ធអង្គទ្រង់សំដែងញែកជាពួកជាគង គឺចិត្តវិភង្គកណ្ឌបទដើមនោះ ទ្រង់សំដែងញែកតែចិត្ត និងចេតសិក ឯរូបវិភង្គកណ្ឌ ទ្រង់សំដែងអំពីរូបកាយនៃសត្វទាំង...... ... ល្មមទ្រង់ជ្រាប ។

បុ. ១២ – សាធុ សាធុ ចម្លើយអ្នកឆ្លើយមកនោះ ពេញជាពីរោះក្បោះក្បាយអស់ញាតិញោមផងទាំងឡាយ ក៏ចូលចិត្តហើយ អើអាននុអើយ តែគស្សបបងនៅសង្ស័យអំពី ចិត្ត និង ចេតសិក ដូចម្ដេចហៅថា ចិត្ត និង ចេតសិក អាននុអើយចូលអ្នកចាត់ចែងសំដែង មកជាទីសណ្ដាប់ ប្រាប់អស់បពិត្រផងទាំងពួងស្ដាប់រាល់គ្នាមើល ហះអាននុអ្នក ?

**ចិ. ១២- ភន្តេ កស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ វិចិត្តនិងចេតសិកនោះ មានលក្ខណៈសភាព និងមុខងារខុសគ្នា ដូចជាទាយនិងកូនក្មួយ ធម្មតាកូនក្មួយ មិនដែលគិតការអ្វីឲ្យស្រេចគិតហើយមានតែជម្រាបប្រាប់នាយ បើនាយព្រមសម្រេចការជាកុសល នូវអកុសល ផងទាំងពួង បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ឯចិត្តនិងចេតសិក បើគិតព្រមគ្នា ក៏បានសេចក្តីសោមនស្សត្រេកអរតែបើមិនព្រមគ្នា កាលណា ក៏បង្កើតនូវសេចក្តីទុក្ខទោមនស្សកាលគ្រានោះបពិត្រព្រះអរិយកស្សប អម្ចាស់អើយសូមទានជ្រាប ។

**ប. ១៣- អាវុសោ អានន្ទ** ម្នាលអានន្ទអើយ អ្នកមានប្រាជ្ញាប្រពៃ កាត់សេចក្តី គ្មានទើសទាល់សល់ជំពាក់ត្រង់ណាឡើយ អើអានន្ទអើយ យើងនឹងចង់ដណ្តឹងអ្នក តទៅវិញទៀតថាឯសោមនស្ស ,ទោមនស្ស, ឧបេក្ខាទាំងបីនេះ តើដូចម្តេចហៅថាសោមនស្ស ទោមនស្ស ហៅថាឧបេក្ខា អានន្ទអើយ ចូលអានន្ទអ្នកអធិប្បាយ ប្រែស្រាយបទទាំងបីនេះមក កស្សបបងនឹងស្តាប់មើល ហះអានន្ទអ្នក ?

**ចិ. ១៣- អានន្ទត្ថេរោ វិសជ្ជេតា** ព្រះមហាអានន្ទត្ថេរ អ្នកពិតថេរវាចាថា **ភន្តេ កស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយឯទីកើតនៃសោមនស្សមាន ៦ ប្រការគឺចក្ខុទ្វារ ១ សោតទ្វារ ១ ឃានទ្វារ ១ ជិវ្ហាទ្វារ ១

កាយទ្វារ១ មនោទ្វារ ១ ឯចក្ខុទ្វារ គឺភ្នែកនិមិត្ត តែឃើញនូវរូបស្រីជាដើមជាប្រធានហើយ ចិត្តត្រេកអរ បង្កើតនូវសោមនស្សប្រការ ១ ឯសោតទ្វារ គឺត្រចៀកតែងស្តាប់នូវសម្លេងច្រៀងតូរ្យតន្ត្រីជាដើមជាប្រធាន ហើយមានចិត្តត្រេកអរ គឺបង្កើតសោមនស្សកាលគ្រានោះ ឯឃានទ្វារគឺច្រមុះ តែងនឹងធុំក្លិន មា[illegible]ក្រអូបជាដើមជាប្រធានហើយ បង្កើតសោមនស្ស ត្រេកអរកាលគ្រានោះឯង ឯជិវ្ហាទ្វារ គឺអណ្តាត បើបានចំណីឆ្ងាញ់ពិសាបរិភោគហើយ ក៏មានចិត្តត្រេកអរ បង្កើតជាសោមនស្សកាលគ្រានោះឯង ឯកាយទ្វារគឺខ្លួន បពិត្រទាំងពួងរាល់គ្នា ដែលបានសំពត់ហូលអាវព្រៃយ៉ាងឯកប្លែកអស្ចារ្យ តែរាល់គ្នាហើយ បង្កើតនូវសោមនស្សត្រេកអរ ឯមនោទ្វារ គឺចិត្តនិងចេតសិក គិតព្រមគ្នាស្រួលសប្បាយក្នុងកាយសន្តាន មានសោមនស្ស កាលគ្រានោះឯង បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ឯសោមនស្សដែលឃើញត្រាប់ចិត្ត ត្រូវចិត្តដូចសំដែងមកនេះ ក៏ត្រេកអរបាននូវសេចក្ដីសោមនស្ស ឯទោមនស្ស ដែលឃើញវត្ថុមិនគាប់ចិត្តមិនត្រូវនឹងចិត្តកាលណា ក៏អាក់អន់ចិត្តទោមនស្ស កាលគ្រានោះឯង ឯឧបេក្ខាមិនដូច្នោះទេ តែយ៉ាងកណ្តាល បើឃើញល្អឆ្ងាញ់ពិសា៑ ក៏មិនត្រេកអរ បើដូចអាក្រក់ក៏មិនអាក់អន់ ដូច្នោះហៅថា ឧបេក្ខា ឯចិត្តឧបេក្ខានោះប្រសើរជាចំបងអស់ចិត្តសោមនស្សទាំងពួង ណាអម្ចាស់សូមទានជ្រាប ។

បុ. ១៤- កស្សបត្ថេរោ តំ សុត្វា ព្រះមហាកស្សបត្ថេរ អ្នកបានស្តាប់អានន្ទអធិប្បាយ ដូច្នេះហើយ ក៏មានថេរវាចាដណ្ដឹងទៅវិញទៀតថា អានន្ទអើយ ឯទីកើតកុសលនោះ តើអាស្រ័យដោយនូវហេតុអ្វីខ្លះ ហ៎ះអានន្ទអ្នក ?

ចិ. ១៤- អានន្ទត្ថេរោ ព្រះមហាអានន្ទត្ថេរ ក៏ពោលថេរវាចាថា ភន្តេ កស្សប បពិត្រព្រះមហាកស្សបអើយ រីឯទីកើតនៃកុសលនោះអាស្រ័យនឹងញាណ ២ ប្រការគឺ ញាណវិប្បយុត្ត ១ ញាណសម្បយុត្ត ១ ។ ឯញាណវិប្បយុត្តនោះ ដូចជាបុគ្គលផងទាំងពួង បើគិតធ្វើបុណ្យឲ្យទានមានទិដ្ឋិនោះរឹងរូស ចាំតែប្រាប់ជំរាបអាត្មា ទើបទៅធ្វើបុណ្យឲ្យទានមានចិត្តនោះរីករាយសប្បាយ ដូច្នេះឈ្មោះថា ញាណវិប្បយុត្ត ។ ឯញាណសម្បយុត្ត មានចិត្ត សទ្ធាតាក់តែងខ្លួនឯងធ្វើជាការកុសលហើយបបួលបញ្ចុះបញ្ចូលចិត្តគេរាល់គ្នាឲ្យកើតមគ្គផល ដូច្នេះឈ្មោះថា ញាណសម្បយុត្ត ៗ នេះ មានផលច្រើនជាងញាណវិប្បយុត្ត បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

ចិ. ១៥- ព្រះមហាកស្សបត្ថេរ អ្នកទ្រង់សណ្ដាប់ ហើយក៏មានថេរវាចាថា សាធុ សាធុ អាវុសោ អានន្ទអើយ អ្នកអធិប្បាយមក

នេះពេញជាពីរោះហើយ អើអានន្ទអើយ យើងទាំងពួងរាល់គ្នាឃើញថាអស់សង្ស័យ ហើយ អានន្ទអើយ អណ្តាប់ពីនេះទៅទៀត តើសម្តេចព្រះជិនវង្ស ស្តេចទ្រង់ សំដែងគម្ពីរអ្វីទៅទៀតហ្ន៎ះ អានន្ទអ្នក ?

ថ. ១៥ = អានន្ទោ តិ សុត្វា គ្រានោះព្រះមហាអានន្ទត្ថេរ បានស្តាប់ថេរវាចាព្រះមហាកស្សបត្ថេរ ដណ្តឹងសួរដូច្នោះហើយ អ្នកក៏ឆ្លើយថា ភន្តេ ថេរ បពិត្រព្រះអរិយកស្សបម្ចាស់អើយ សម្តេចព្រះជិនវង្សទ្រង់ សំដែងគម្ពីរវិភង្គ តទៅទៀតណាម្ចាស់សូមទ្រង់ជ្រាប ។

បុ. ១៦ — សាធុ សាធុ អាវុសោ អានន្ទអើយ សម្តេច ព្រះមុនីនាថសាស្តាចារ្យវង្ស ស្តេចទ្រង់សំដែងព្រះគម្ពីរវិភង្គនេះ តើចែកចេញ ជាព្រះធម្មក្ខន្ធ មានប៉ុន្មានវិភង្គ ហ្ន៎ះអានន្ទអ្នក ?

ថ. ១៦ - ភន្តេ បពិត្រព្រះអរិយកស្សបម្ចាស់អើយ សម្តេច ព្រះពុទ្ធអង្គទ្រង់សំដែងចែកជាធម្មក្ខន្ធមាន ៦៩០០ ធម្មក្ខន្ធចែកជាវិភង្គមាន ១៨ មានខន្ធវិភង្គជាដើម មានតិរច្ឆញាណវត្ថុវិភង្គជាបរិយោសានណាម្ចាស់ សូម ទ្រង់ជ្រាប ។

បុ. ១៧- សាធុ សាធុ អានន្ទអើយអ្នកឆ្លើយមកនេះពេញ ជាពីរោះពេកហើយ អើអានន្ទអើយ ក្នុងវិភង្គទាំង ១៨ នោះយើងនឹង

អស់អើយ យើងនឹងផ្ដើងសួរទៅទៀតថាក្នុងពិភពលោកមួយឈ្មោះខន្ធវិភង្គជា ដើម ជាប្រធាន សម្ដេចព្រះទ្រង់ញាណ ទ្រង់ចែកចេញជាខន្ធនោះមានប៉ុន្មានហៈ អានន្ទអ្នក ?

**ឆ. ១៧– អានន្ទោ តំ សុត្វា** ព្រះមហាអានន្ទត្ថេរ អ្នកស្ដាប់ថេរវាចា ព្រះមហាអរិយកស្សប ផ្ដើងសួរដូច្នោះហើយអ្នកមានថេរវាចាថា **ភន្តេ ថេរ** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សម្ដេចព្រះពុទ្ធអង្គទ្រង់សំដែង ចែកចេញជាខន្ធគឺ រូបក្ខន្ធប្រការ ១ វេទនាខន្ធប្រការ ១ សញ្ញាខន្ធប្រការ ១ សង្ខារក្ខន្ធប្រការ ១ វិញ្ញាណក្ខន្ធប្រការ ១ ដ្បិតផងគ្នាត្រូវជារូបក្ខន្ធមាន ៥ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

**ប្ុ. ១៨–** ព្រះមហាកស្សបត្ថេរ អ្នកផ្ដើងសួរទៅទៀតថា **អាវុសោ** អានន្ទអើយ បានជាសម្ដេចព្រះពុទ្ធអង្គទ្រង់សំដែងក្នុងរូបក្ខន្ធ ថៈរូបក្ខន្ធនេះតើដូចម្ដេច បានជាហៅថារូបក្ខន្ធ ចូលអានន្ទអ្នកអធិប្បាយប្រែស្រាយជាៈមចក្ខិម។ កស្សបបងនឹងបានស្ដាប់ផងមើលហៈអានន្ទអ្នក ?

**ឆិ. ១៨–** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ បើដូច្នោះសូមចាំស្ដាប់ខ្ញុំអានន្ទនឹងអធិប្បាយ តាមព្រះពុទ្ធដីការថាបានជាទ្រង់សំដែងថារូបក្ខន្ធនោះ ព្រោះក្នុងរូបកាយយើងនេះ មានវត្ថុប្រកបដោយពួកដោយក្រុមផ្សេង ៗ គ្នា គឺ

ទឹក ដី ភ្លើង ខ្យល់ នៅក្នុងខ្លួនយើងទាំងពួងរាល់គ្នា ណាអម្ចាស់សូមទ្រង់ជ្រាប ។

ប្រ. ១៩— កស្សបត្ថេរោ តំ សុត្វា ព្រះមហាកស្សបត្ថេរ អ្នកទ្រង់ព្រះសណ្ដាប់ហើយមានថេរវាចាថា អានន្ទអើយដូចអ្នកសំដែងមកថា មានទឹក មានដី មានភ្លើង មានខ្យល់ ក្នុងរូបកាយនៃសត្វផងទាំងពួងនោះ តើទឹកដីភ្លើងខ្យល់នោះ មានប៉ុន្មានបះ អានន្ទអ្នក ចូលអានន្ទអ្នកសំដែងមក កស្សបបងនឹងបានស្ដាប់មើលបះអានន្ទអ្នក ?

ឆ. ១៩_ អានន្ទត្ថេរោ ព្រះមហាអានន្ទត្ថេរ មានថេរវាចាថា បពិត្រព្រះអរិយកស្សបអម្ចាស់អើយ បណ្ដាសត្វផងទាំងឡាយទាំងពួង ដែលកើតមកក្នុងវដ្ដសង្សារ មានធាតុទាំង ៤ ជាទីតាំងរូបកាយមានអាបោធាតុ ១២ រាប់តាំងពីបិត្ត ដរាបដល់មុត្ត ជាបរិយោសាន ឯធាតុដីទាំង ២១ រាប់ពីកេសា ដល់មត្ថកេ ជាបរិយោសាន ឯតេជោធាតុភ្លើង មានឈ្មោះសន្តប្បត្តិជាដើមជាប្រធាន ឯវាយោធាតុ គឺជាខ្យល់ ៦ ឯខ្យល់នោះឈ្មោះ ឧទ្ធង្គមវាតប្រការ ១ អធោវាតប្រការ ១ កោដ្ឋាសវាតប្រការ ១ អង្គមង្គានុសារីវាតប្រការ ១ អស្សាសបស្សាសវាតប្រការ ១ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ឯភូតធាតុទាំង ៤ គឺ ទឹក ដី ភ្លើង ខ្យល់ នេះ ហៅថាភូតរូប បានជាហៅឈ្មោះ ព្រោះរូបទាំង ៤ នេះ ជាធំជាទីតាំងរូប

កាយ នៃសត្វទាំងពួង បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូម
ទ្រង់ជ្រាប ។

បុ. ២០- កស្សបត្ថេរោ តំ សុត្វា ព្រះមហាកស្សបត្ថេរ អ្នកទ្រង់សណ្តាប់ហើយ ក៏មានថេរវាចាថា អានន្ទអើយ ចូរអានន្ទនាំសេចក្តី តួធាតុទាំង ៤ មកដាក់ទីសណ្តាប់ ប្រាប់អស់បពិត្រផងទាំងពួងរាលគ្នាមើល ហះ អានន្ទអ្នក ?

វិ. ២០- អានន្ទត្ថេរោ បពិត្រអើយ ព្រះមហាអានន្ទអ្នកទាន ថេរវាចាថា បពិត្រលោកទាំងពួងអើយ ចូរផ្តង់សោតប្រសាទចាំស្តាប់ខ្ញុំអា-នន្ទនឹងសំដែងតាមព្រះពុទ្ធដីកា ឯធាតុដីទាំង ២១ នោះមាន កេសា សក់ជាដើម គឺសក់ក្បាលយើង មានប្រមាណ ៩ លានសរសៃ លោមា គឺរោមយើង មានប្រមាណ ៩ កោដិសរសៃ, នខា គឺក្រចកយើងទាំង២០, ទន្តា គឺធ្មេញ ៣២, តចោ គឺស្បែក, មំសំ គឺសាច់យើងប្រមាណបាន ៩១០ ដុំ នហារូ គឺសរសៃតូច-ធំ ទាំង ៤០០ អដ្ឋិ គឺឆ្អឹងរាប់បាន ១០០ កំណាត់ ឆ្អឹងធំ ២៤ អដ្ឋិមិញ្ជំ គឺខួរក្នុងឆ្អឹង វក្កំ គឺទាច ហទយំ គឺសាច់ចិត្ត មានពណ៌ដូចផ្កាឈូកស្ថិតនៅលើថ្លើម យកនំ គឺថ្លើម ស្ថិតនៅលើដើមទ្រូងលើដោះ មានសភាពដូចផ្កាឈូករីក បើអ្នកល្ងង់ខ្លៅ គ្មានដែករីកឡើយ កិលោមកំ គឺក្រដាសរុំថ្លើម វែង ៣០០ កំណាត់ បិហកំ

គឺក្រពះ **បញ្ញាសំ** គឺសួត **អន្តំ** ពោះវៀនធំ **អន្តគុណំ** ពោះវៀនតូច **ឧទរិយំ** អាហារថ្មី **ករីសំ** អាហារចាស់ **មត្ថកេ** លលាដ៍ក្បាល ផ្សំផងគ្នាត្រូវជា ២១ ឈ្មោះបឋវីធាតុ ឯអាបោធាតុបានដល់ធាតុ **ទឹក** គឺ **បិត្តំ** ប្រមាត់, **សេម្ហំ**, ស្លេស្មំ, **បុព្វោ** ខ្ទុះ, **លោហិតំ** ឈាម, **សេទោ** ញើស, **មេទោ** ខ្លាញ់ខាប់, **អស្សុ** ទឹកភ្នែក, **វសា** ខ្លាញ់រាវ, **ខេឡោ** ទឹកមាត់, **សិង្ឃាណិកា** ទឹកសំបោរ, **លសិកា** ទឹកខ្លាញ់សន្ទាក់ក្នុងឆ្អឹង, **មុត្តំ** ទឹកមូត្រ ផ្សំផងគ្នាទាំងអស់ត្រូវជា ១២ ប្រការនេះ ឈ្មោះថាអាបោធាតុ ឯតេជោធាតុ ៤ មានសន្តប្បតិ ភ្លើងឆេះក្នុងកាយនិមិត្តតែឆេះឡើងកាលណា ស្ងួតស្អប់សៅហ្មងក្នុងកាយសន្តាន នៃអ្នកទាំងពួងរាល់គ្នាភ្លើងបរិទយ្ហតិនោះ ឆេះរោលរាលក្ដៅក្រហាយទាំងអស់ ឯភ្លើងឈ្មោះជីរណតិ ឆេះឡើងកាលណា ជ្រួញជ្រីវចាស់ជរា ឯបរិណាមតិនោះ ឆេះឡើងរំលួលអាហារ ផ្សាយគ្រប់សព្វរោមសរសៃមានកម្លាំងសុខសប្បាយ ក្នុងកាយ សន្តានយើងរាល់គ្នា ឯវាយោធាតុ ៦ មានខ្យល់ ១ ឈ្មោះ ឧទ្ធង្គមវាតនោះ បក់ពីចុងជើងដល់ក្បាល ឯអធោគមវាត ខ្យល់បក់ពីក្បាលដល់បាទជើង ឯខ្យល់ឈ្មោះកុច្ឆិសយវាត បក់តែក្នុងពោះវៀនតូច ពោះវៀនធំ អង្គមង្គានុសារីវាត ខ្យល់បក់ដល់ម្រាមដៃ ម្រាមជើង ឯខ្យល់អស្សាសបស្សាសវាត គឺខ្យល់ដង្ហើមចេញចូល សុខសប្បាយនៃបុគ្គលរាល់គ្នា បពិត្រព្រះ

អរិយកស្សប ខ្ញុំអធិប្បាយនាំសេចក្តីមហាភូតរូបទាំង ៨ នេះបញ្ចប់តែប៉ុណ្ណេះឯង សូម...អានជ្រាប ។

ពុ. ២១— កស្សបត្ថេរោ បពិត្រអើយ ព្រះមហាកស្សបត្ថេរ អ្នកបានស្តាប់ព្រះមហាអានន្ទត្ថេរ សំដែងដូច្នោះហើយ កស្សបទ្រង់សរសើរថា សាធុ, សាធុ អានន្ទអើយ អ្នកសំដែងមកនេះ ពេញពោរថាពីរោះ ត្រូវតាមព្រះពុទ្ធដីកា យើងរាល់គ្នា ក៏ចូលចិត្តហើយ រឹងចូលចិត្តទៀត អើអានន្ទអើយ កស្សបបងនឹងដណ្តឹងសួរអ្នកតទៅទៀតថា សម្តេចព្រះមុនីនាថស្តេចទ្រង់សំដែងភូមិកៀទៀតឬ អានន្ទអ្នក ?

វិ. ២១— ភន្តេ កស្សប បពិត្រព្រះអរិយកស្សប អម្ចាស់អើយ សម្តេចព្រះពុទ្ធអង្គ ទ្រង់សំដែងនូវគម្ពីរព្រះវិភង្គចប់ស្រេច សម្តេចព្រះបរមលោកនាថសាស្តាចារ្យ ទ្រង់សំដែងព្រះធាតុកថា តទៅទៀតណាអម្ចាស់ សូមទ្រង់ជ្រាប ។

ពុ. ២២— សាធុ សាធុ អាវុសោ អានន្ទអើយ សម្តេចព្រះមហាករុណា ទ្រង់សំដែងព្រះធាតុកថានោះ តើទ្រង់ចែកជាព្រះធម្មក្ខន្ធមានប៉ុន្មាន ? ចែកចេញជាបទមានប៉ុន្មាន ? ចែកជាមាតិកា មានប៉ុន្មាន ? ឬ អានន្ទអ្នក ចូរអានន្ទអ្នកសំដែងចែកចេញជាពួក ជាកងមក កស្សបបងនឹងបានស្តាប់មើលឬ អានន្ទអ្នក ?

ទិ. ២២- អានន្ទា តំ សុត្វា ព្រះមហាអានន្ទត្ថេរអ្នកបានស្តាប់ព្រះមហាកស្សបត្ថេរ ផណ្តឹងសួរដូច្នោះហើយ ក៏មានថេរវាចាភន្តេ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សម្តេចព្រះពុទ្ធអង្គទ្រង់សំដែងចែកចេញ ជាព្រះធម្មក្ខន្ធមាន ៧០០ធម្មក្ខន្ធ ចែកជាបទមាន ១៤បទ មានសង្គហោ ជាដើម មានសង្គហិតំ ជាបរិយោសាន ចែកជាមាតិកាមាន ៥ គឺនិយមាតិកាប្រការ ១ អនន្តមាតិកាប្រការ ១ និយមមាតិកាប្រការ ១ លក្ខណមាតិកាប្រការ ១ ពាហិរមាតិកាប្រការ ១ ផ្សំផងគ្នាទាំងអស់ ត្រូវជាមាតិកាមាន ៥ បពិត្រព្រះអរិយកស្សបអម្ចាស់សូមទ្រង់ជ្រាប ។

ចុ. ២៣- សាធុ សាធុ អាវុសោ អានន្ទអើយ ចម្លើយអ្នកឆ្លើយមកនេះពេញជាពីរោះពេកហើយ អើអានន្ទអើយមាតិកាទាំង ៥ នោះយើងទុកសិនចុះ យើងនឹងផណ្តឹងសួរអ្នកតែក្នុងបទមាតិកា ដែលអ្នកសំដែងថា មានសង្គហោជាដើមជាប្រធាន មានសង្គហិតំ ជាបរិយោសាន សម្តេចព្រះទ្រង់ញាណទ្រង់សំដែងថាដូចម្តេចហ្ន៎ អានន្ទអ្នក ចូរអានន្ទ អធិប្បាយប្រែស្រាយ ជាសេចក្តីមកកស្សបងនឹងបានស្តាប់មើលហ្ន៎អានន្ទអ្នក ?

ទិ. ២៣– ភន្តេ បពិត្រព្រះអរិយកស្សប ព្រះបរមសាស្តាចារ្យទ្រង់សំដែងក្នុងបទ ១២ មានសង្គហោ និងអសង្គហោ ជាដើម ជាប្រធាន សម្តេចព្រះទ្រង់ញាណទ្រង់សំដែងថា បណ្តាធម៌ទាំងពួងបទជាធម៌រមបញ្ចូលគ្នា

ដូចជារូបក្ខន្ធ និងមហាភូតរូប និងមហាឧបាទានរូបទាំងអម្បាលនោះហៅថា សង្គហោ ឯអសង្គហោនោះ មិនបានបញ្ចូលគ្នាលដូចជាបទរូបក្ខន្ធ និងអាយតនៈនូវចតុរារិយសច្ច ដោយពួក ដោយកងទីទៃពីគ្នាហេតុដូច្នេះ បានជាទ្រង់សំដែងហៅថាអសង្គហោ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ២៤- សាធុ សាធុ អាវុសោ អានន្ទអើយ អ្នកឆ្លើយមកនេះពេញជាហៅពីរោះពេកហើយ អើអានន្ទអើយ ឯបទទាំងពីរគឺ សង្គហោ និងអសង្គហោនេះ តើសង្គហោ ដែលអ្នកសំដែងថាបញ្ចូលគ្នានឹងរូបក្ខន្ធ និងមហាភូតរូប និងឧបាទានរូប ឯរូបក្ខន្ធ និងមហាភូតរូបនោះអ្នកសំដែងរួចហើយ អើអានន្ទអើយ ឧបាទានរូបនៅឡើយ ដូច្នេះចូរអ្នកចាត់ចែងសំដែងអធិប្បាយ ប្រែស្រាយមកជាទីសណ្ដាប់នៃអស់សប្បុរសទាំងពួងរាល់គ្នា នឹងបានស្ដាប់មើលមហាអានន្ទអ្នក ។

ឆិ. ២៤- អានន្ទោ តំ សុត្វា ព្រះមហាអានន្ទអ្នកទទួលធុរៈដោអ្នកសំដែងហើយ ក៏មានថេរវាចាថា បពិត្រព្រះអរិយកស្សបអម្ចាស់អើយខ្ញុំអានន្ទនឹងសំដែងតាមព្រះពុទ្ធដីកាថា ឧបាទានរូប ៥ ចែកជាវិសយរូប ៤ កាយរូប ២ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ វិញ្ញត្តិរូប ១ វិការរូប ៣ លក្ខណរូប ៤ ផ្សំផងគ្នាត្រូវជា ២៤ ប្រការ បពិត្រព្រះអរិយកស្សប សូមទ្រង់ជ្រាប ។

បុ. ២៥- ព្រះមហាកស្សបត្រេកទ្រង់ព្រះសណ្ដាប់ ព្រះអានន្ទអ្នកនាំសេចក្ដីក្នុងឧទានរូប ២៨ ដូច្នេះហើយ អ្នកក៏ដណ្ដឹងតទៅទៀតថា អាវុសោ

អានន្ទអើយ អ្នកសំដែងនូវថ្មោះហើយ អស់បពិត្រផងទាំងពួងឃើញ
ថា នៅសង្ស័យរាល់គ្នា បើដូច្នោះ ក៏ចូរអានន្ទអ្នកអធិប្បាយប្រែស្រាយជា
សេចក្តីមកជាទីសណ្តាប់អស់ សប្បុរសផងទាំងពួង នឹងបានស្តាប់រាល់គ្នា មើល
ហ្ន៎ អានន្ទអ្នក ?

ទិ. ២៥- អានន្ទោ តំ សុត្វា ព្រះមហាអានន្ទត្ថេរ អ្នកបាន.
ស្តាប់ហើយ ក៏ទ្រង់សំដែងយ៉ាងពិស្តារតទៅទៀតថា បពិត្រលោកទាំងពួង
អើយ ចូរផ្ចង់សោតប្រសាទទាំងសង ត្រងត្រាប់ស្តាប់ខ្ញុំអានន្ទ នឹងសំដែង
តាមព្រះពុទ្ធដីកាថា ឯប្រសាទទាំង ៥ គឺចក្ខុប្រសាទ ១ សោតប្រសាទ ១
ឃានប្រសាទ ១ ជិវ្ហាប្រសាទ ១ កាយប្រសាទ ១ ដ្បិតទាំងអស់ត្រូវជាប្រ-
សាទរូប ៥ ប្រសាទ ៦ គឺចក្ខុ ភ្នែកយើងសព្វថ្ងៃ ឯភ្នែកតែងនឹងមើលវត្ថុអ្វី
អាស្រ័យនឹងប្រសាទ ឯចក្ខុប្រសាទរូបនោះ មានទំហំប៉ុនក្បាលចៃនៅក្នុងភ្នែក
យើង ថាបើគ្មានហើយនឹងមើលអ្វីៗ ក៏មិនឃើញ ឯសោតប្រសាទ គឺត្រ
ចៀកទាំងស្តាប់ឮ នូវសម្លេងទាំងពួងអាស្រ័យនូវសោតប្រសាទនោះឯង ឯសោត
ប្រសាទនោះ មានប៉ុនរោមនៅក្នុងរន្ធត្រចៀកយើង ថាបើគ្មានដូច្នោះហើយ ក៏
ចង់នឹងស្តាប់អ្វីនោះក៏មិនឮឡើយ ឯឃានប្រសាទនោះជាទីធំក្លិននូវវត្ថុទាំងពួងនោះ
ក៏អាស្រ័យនឹងឃានប្រសាទ ។ នោះ មានសណ្ឋានបីដូចជើងពពែ បើគ្មានឃាន
ប្រសាទទេ នឹងមិនដឹងក្លិនស្អុយក្រអូបអ្វីឡើយ ឯជិវ្ហាប្រសាទ តែងនឹងដឹងរស

ពីសាទាំងពួង អាស្រ័យជីវ្ហាប្រសាទ ។ មានសណ្ឋានបីដូចជាស្រទាប់ផ្កាឈូក នៅកណ្ដាលអណ្ដាត បើគ្មានជីវ្ហាប្រសាទទេ មិនអាចដឹងរសទាំងពួងឡើយ , ឯកាយប្រសាទគឺខ្លួន អាស្រ័យនឹងកាយប្រសាទ ។ នោះរត់សព្វសាច់ ហើយបើនៅជាស៊ិតស្រពោន កាលណាមិនរត់បានឡើយ ។

ឯវិស័យរូបមាន ៤ គឺអារម្មណ៍ ៤ មានរូបារម្មណ៍ ១ សទ្ទារម្មណ៍ ១ គន្ធារម្មណ៍ ១ រសារម្មណ៍ ១ ឯរូបារម្មណ៍ គឺយករូបជាអារម្មណ៍ បើឃើញរូបល្អជាដើមហើយ មានចិត្តត្រេកអរក្សាហាន ដូច្នេះឈ្មោះថាយករូបជាអារម្មណ៍ , ឯសទ្ទារម្មណ៍ គឺយកសំឡេងជាអារម្មណ៍ ដូចជាឮចម្រៀងតូរ្យតន្ត្រីក៏កាន់យកជាអារម្មណ៍ ដូចជាវត្ថុមានស្អុយក្រអូបជាដើមហើយ ក៏យកជាអារម្មណ៍ ។

ខ្ញុំបាននូវសំដែងក្នុងវិស័យរូប សូមស្មេះតែប៉ុណ្ណោះ ឥឡូវនេះនឹងសំដែងតទៅទៀតអំពីភាវរូប ២ នោះគឺ ឥត្ថីភាវរូប ១ បុរិសភាវរូប ១ ឯឥត្ថីភាវរូបនោះ គឺស្ត្រីត្រូវរក្សាកិរិយាជាស្ត្រី. បុរិសភាវរូប គឺបុរសឲ្យរក្សាកិរិយាជាប្រុស ។ ចំណែកខាងហទយរូប គឺសាច់ចិត្តដែលតំកល់ស៊ើមនេះឯង ប្លែកពីសាច់ទាំងពួង, ឯជីវិតរូបគឺអាការៈទាំង ៣២ ប្រៀបដូចជារនេះ មានកង់ការ ប្រែក ត្ថូ ទាំងអស់ ទើបហៅថារនេះ, ឯអាហាររូបនោះគឺ អាហារដែលគេបរិភោគជាទីតាំងរូបសព្វថ្ងៃនេះឯងហៅថាអាហាររូប ឯបរិច្ឆេទរូបនោះ លោកកំណត់ទ្វារទាំង ៣នេះ ដូចជាត្រចៀក ច្រមុះ មាត់ ហៅថាទ្វារ ត្បិតទ្វារទាំង ៣ ជាទីសម្រាប់

ខ្យល់ចេញចូល , អវិញ្ញត្តិរូបបានដល់ **វចីវិញ្ញត្តិ កាយវិញ្ញត្តិ មនោវិញ្ញត្តិ** ចំណែកឯវិការរូបមាន ៣ គឺ រូបលហុតាប្រការ ១ រូបមុទិតា ១ រូបមញ្ញតា ១ ។

ចំណែកខាងលក្ខណរូប អធិប្បាយថា បណ្ដាសត្វទាំងពួងតាំងពីមកចាប់បដិសន្ធិក្នុងផ្ទៃ មាតាតាលណា ឈ្មោះហៅថា ឧបជយរូបឯសន្តរូប នោះគឺរូបដែលកើតពីគ្នាដល់ធំ, ឯជរារូប គឺរូបជរាចាស់ទ្រាំទ្រា ឯអនិច្ចតារូបនោះគឺរូបមិនទៀង កើតឡើងហើយស្លាប់ រួចមកកើតទៀតដូច្នេះផងគ្នាត្រូវជាលក្ខណរូប ៤ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ខ្ញុំអាននូសំដែងមកក្នុងឧបាទានរូប ២៨ ចប់ស្រេចតែប៉ុណ្ណោះណាអម្ចាស់សូមទ្រង់ជ្រាប ។

ចុ. ២៦- **សាធុ សាធុ អាវុសោ** អាននូអើយ ចម្លើយអ្នកឆ្លើយមកនេះពីរោះពេកហើយ អើអាននូអើយ យើងនឹងដណ្ដឹងអ្នកតទៅទៀត ចុះមហាភូតរូបបញ្ចូលនឹងរូបក្ខន្ធនោះ តើបញ្ចូលនឹងបទឯណាហ្ន៎ៈអាននូអ្នក ចូរអាននូអធិប្បាយមកជាទីសណ្ដាប់ប្រាប់មកយើងរាល់គ្នាមើលហ្ន៎ៈអាននូអ្នក ?

**ទិ. ២៦- ភន្តេ កស្សប** បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ឯរូបខន្ធនោះ បញ្ចូលនឹងវេទនាខន្ធ ឯវេទនាខន្ធបញ្ចូលនឹងសញ្ញាខន្ធ ឯសញ្ញាខន្ធ បញ្ចូលនឹងសង្ខារខន្ធ ឯសង្ខារខន្ធបញ្ចូលនឹងវិញ្ញាណខន្ធ ដូច្នេះផងគ្នាត្រូវជារូបក្ខន្ធ ៥ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

ប. ២៧ – សាធុ សាធុ អានន្ទអើយ បើដូច្នោះហើយ ចូរអ្នកសំដែងក្នុងវេទនាខន្ធនោះតើមានប៉ុន្មាន ? សញ្ញាក្ខន្ធមានប៉ុន្មាន ? សង្ខារខន្ធមានប៉ុន្មាន វិញ្ញាណក្ខន្ធតើមានប៉ុន្មាន? ចូរអានន្ទអ្នកសំដែងកែខៃ ក្នុងសេចក្ដីនៃខន្ធទាំង ៥ នេះមកកស្សបបងនឹងស្ដាប់មើលហ៎ អានន្ទអ្នក ?

ឆ. ២៧ ភន្តេ កស្សប បពិត្រព្រះអរិយកស្សប អម្ចាស់អើយ សូមចាំស្ដាប់ខ្ញុំ អានន្ទនឹងសំដែង ក្នុងវេទនាខន្ធនោះមាន ៥ គឺសុខវេទនា ១ ទុក្ខវេទនា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ ឧបេក្ខាវេទនា ១ ផ្សំទាំងអស់ផងគ្នា ត្រូវវេទនា ៥ ឯវេទនា ៥ នេះអាស្រ័យកើតពីទ្វារទាំង ៦ គឺចក្ខុទ្វារ ១ សោតទ្វារ ១ ឃានទ្វារ ១ ជិវ្ហាទ្វារ ១ កាយទ្វារ ១ មនោទ្វារ ១ ទ្វារទាំង ៦ នេះជាទីកើតនៃវេទនាទាំង ៥ ឯសញ្ញាខន្ធ ក៏អាស្រ័យដោយទ្វារទាំង ៦ មានចក្ខុទ្វារជាដើម មានកាយទ្វារជាទីបញ្ចប់ ឯវិញ្ញាណជាទីកំណត់បានតែមិនស្រេច បើមានប្រាជ្ញាផង ទើបពិចារណាដឹងថាល្អអាក្រក់ ប្រៀបបីដូចជាក្មេងចាប់ខ្សាច់បាចលើងទៅឃើញត្បូង តែមិនស្គាល់ថាត្បូងយកទៅឲ្យម្ដាយ ឯម្ដាយស្គាល់ថាត្បូង តែមិនដឹងថាល្អអាក្រក់ ថ្លៃតិចច្រើន មានឧបមាដូចម្ដេចមិញ ឯសញ្ញានិងវិញ្ញាណ និង បញ្ញា ក៏មានឧបមាដូច្នោះ បពិត្រព្រះអរិយកស្សប ខ្ញុំអានន្ទ សំដែងក្នុងគម្ពីរព្រះធាតុកថានេះជាសង្ខេបតែប៉ុណ្ណោះឯង សូមទ្រង់ជ្រាប ។

ពុ. ២៨_ សាធុ សាធុ អាវុសោ អានន្ទអើយ ព្រះពុទ្ធអង្គទ្រង់សំដែងព្រះគម្ពីរធាតុកថាចប់ តើព្រះអង្គទ្រង់សំដែងគម្ពីរអ្វីតទៅទៀតហ្ន៎ អានន្ទអ្នក ?

ទិ. ២៨ _ ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សម្តេចព្រះជិនវង្ស ស្តេចទ្រង់សំដែងគម្ពីរព្រះធាតុកថាចប់ហើយ ព្រះអង្គទ្រង់សំដែងគម្ពីរព្រះបុគ្គលបញ្ញត្តិតទៅទៀតណាអម្ចាស់ សូមទ្រង់ជ្រាប ។

ពុ. ២៩_ អើ អានន្ទអើយអានន្ទ ព្រះមុនីនាថសាស្ដាចារ្យ ទ្រង់សំដែងព្រះគម្ពីរបុគ្គលនោះ តើទ្រង់ចែកជាធម្មក្ខន្ធមានប៉ុន្មាន ? ជាបញ្ញត្តិមានប៉ុន្មានហ្ន៎ អានន្ទអ្នក ?

ទិ. ២៩ _ ភន្តេ កស្សប បពិត្រព្រះអរិយកស្សបដ៏ប្រសើរអើយ សម្តេចព្រះពុទ្ធអង្គទ្រង់សំដែងចែកចេញជា ៥៥០០ ព្រះធម្មក្ខន្ធទ្រង់ចែកចេញបញ្ញត្តិមាន ៦ គឺខន្ធប្បញ្ញត្តិ ១ អាយតនប្បញ្ញត្តិ ១ ធាតុប្បញ្ញត្តិ ១ សច្ចប្បញ្ញត្តិ ១ ឥន្ទ្រិយប្បញ្ញត្តិ ១ បុគ្គលប្បញ្ញត្តិ ១ ផ្សំផងគ្នាត្រូវជាបញ្ញត្តិមាន ៦ ប្រការ បពិត្រព្រះអរិយកស្សបអើយ សូមទ្រង់ជ្រាប ។

ពុ. ៣០_ សាធុ សាធុ អាវុសោ ម្នាលអាវុសោ អានន្ទអើយ ចំឡើយអ្នកឆ្លើយមកនេះ ពីរោះពេកហើយ អើអានន្ទ

អើយ ក្នុងបញ្ញត្តិទាំង ៦ ប្រការយើងក៏ដឹងហើយ យើងនឹងសួរតែបញ្ញត្តិ ១ បទ ចុងឈ្មោះបុគ្គលប្បញ្ញត្តិនោះ តើសម្តេចព្រះពុទ្ធអង្គទ្រង់ប្រញាប្តនឹងបុគ្គលប៉ុន្មាន ជំពូកហ្ន៎ អានន្ទអ្នក ?

ថិ. ៣០- ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់ អើយ សម្តេចព្រះសាស្តាចារ្យទ្រង់សំដែងនឹងបុគ្គលជំពូក ១ មែនពិតដំរាប ដល់ ១០ តាំងពីសម័យវិមុត្តិជាដើមជាប្រធាន មានអរហត្តមគ្គាបរិយោសាន ហេតុដូច្នេះ បានជាសម្តេចព្រះទ្រង់ញាណ មានពុទ្ធដីកាថា កតមោ ច បុគ្គលោ សមយវិមុត្តោ ឯសម័យវិមុត្តបុគ្គលនោះ បានខាងឯសោតា សកិទាគាមី អនាគាមី ទាំង ៣ ជំពូកនេះ ឈ្មោះសមយវិមុត្តិ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

ចុ- ៣១- សាធុ សាធុ អាវុសោ អានន្ទអើយ ចម្លើយ អ្នកឆ្លើយមកក្នុងសមយវិមុត្តិថា មានបុគ្គល ៣ ជំពូកនោះដូចម្តេចហ្ន៎ ចូរអ្នកអធិប្បាយប្រែស្រាយជាសេចក្តីមកកស្សបចង់នឹងបានស្តាប់មើលហ្ន៎ អានន្ទអ្នក?

ថិ. ៣១- ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់ អើយ សូមស្តាប់ខ្ញុំអានន្ទនឹងអធិប្បាយតាមព្រះពុទ្ធដីកាទ្រង់សំដែងមកថា សមយ

វិមុត្តិបុគ្គល គឺព្រះសោតាៗ នោះមាន ៣ ជំពូក គឺ ឯកពីជីសោតា ១ កោលោហលំសោតា ១ សត្តក្ខត្តុំបរមំសោតា ១ ដូច្នេះត្រូវជា ព្រះសោតា ៣ ប្រការ ឯសោតាបុគ្គលនោះលោកលះបង់ធម៌ ៣ ប្រការ គឺ សក្កាយទិដ្ឋិប្រការ ១ វិចិកិច្ឆាប្រការ ១ សីលព្វតបរាមាសប្រការ ១ ថា បើអ្នកឯណាលះបង់នូវធម៌ ៣ ប្រការនេះបានកាលណា ក៏លោកកំណត់ហៅថា ព្រះសោតា កាលគ្រានោះ ឥឡូវនេះខ្ញុំអាននូវនឹងសំដែងអធិប្បាយក្នុងទិដ្ឋិ ទាំង ៣ ប្រការ ឯសក្កាយទិដ្ឋិនោះ គឺចិត្តរឹងរូសក្នុងកាយនៃអាត្មា បៀតបៀនចង្រៃនឹងព្រះត្រៃរត្នកែវទាំង ៣ គឺព្រះពុទ្ធព្រះធម៌ព្រះសង្ឃ, ឯសីលព្វតបរមាសៈនោះ គឺបុគ្គលកាន់សាសនអន្យតិរ្ថិយ ធ្វើកិរិយាតាមសាសនានោះៗ ដូចជាស្លៀកសំពតពាក់អាវ, ម្យ៉ាងវិញទៀត ដូចជារៀនមន្តវិជ្ជាការក្រៅពីព្រះត្រៃសរណគមន៍ទាំង ៣ នេះហៅថា សីលព្វតបរាមាស, បពិត្រព្រះអរិយកស្សបអម្ចាស់អើយ បើបុគ្គលឯណាកំចាត់បង់ធម៌ទាំង ៣ ប្រការឲ្យស្អាត គិតយកតែកែវទាំង ៣ ជាទីពឹងកាលណា ក៏ហៅថាព្រះសោតាបុគ្គលកាលគ្រានោះ ព្រះសោតានោះមាន ៣ ជំពូកគឺ ឯកពីជីសោតានោះមកកើតតែ ១ ជាតិក៏បានសម្រេចព្រះអរហត្តចូលព្រះបរិនិព្វានដ៏ជាស្ថានបរមសុខ ឯកោលាហលំសោតា មកបង្កើតក្នុងមនុស្សលោកបាន ៦ ជាតិ ហើយកើតតែនឹងត្រកូល

សេដ្ឋីមន្ត្រី សំរេចព្រះអរហត្តដល់និព្វាន , ឯសត្តត្តុំបរមសោតា ថា
បើបានព្រះសោតាហើយនឹងបានទៅកើតឯកាមាវចរសួគ៌ទាំង ១៦ ស្ថាន លុះ
ច្យុតិអំពីសួគ៌ នឹងមកកើតនៅមនុស្សលោកនេះបាន ៧ ជាតិ ទើបបានអរហត្ត
កំចាត់បង់នូវកិលេស នឹងចូលនិព្វានដ៏ជាស្ថានបរមសុខប្រសើរ នឹងរកស្ថាន
ឯណាស្មើនោះគ្មានឡើយ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ខ្ញុំអានន្ទនាំ
សេចក្តីក្នុងសមយវិមុត្តិអស់តែប៉ុណ្ណេះឯង សូមទ្រង់ជ្រាប ។

បុ. ៣២– សាធុ សាធុ អាវុសោ អានន្ទអើយ អ្នកសំដែង
មកក្នុងព្រះសោតានោះរួចហើយ នៅឯព្រះសកិទាគាមិ និងអរហត្តនោះ
មិនទាន់សំដែងទៅឡើយ អើអានន្ទអើយ ចូរអ្នកសំដែងប្រែស្រាយបរិយាយ
ប្រាប់មកសប្បុរសផងទាំងពួង នឹងបានស្តាប់រាល់គ្នាមើលហ្ន៎អានន្ទអ្នក ?

វិ. ៣២– ភន្តេ កស្សប បពិត្រព្រះអរិយកស្សប
អម្ចាស់អើយ ឯបុគ្គលបានសកិទាគាមិ កំណត់អស់អាយុអំពីមនុស្សលោកនេះ
នឹងបានទៅកើតឯសួគ៌ទេវលោកនាយ ច្យុតអំពីទេវលោកមកកើតនៅឯមនុស្ស
លោកនេះ ១ ជាតិ ក៏បានសម្រេចព្រះអរហត្តចូលនិព្វាន ឯបុគ្គលបាននូវ
អនាគាមិ ក៏តែងបានសម្រេចអរហត្ត កាត់កិលេសអស់ស្រេច ហើយ
ចូលព្រះនិព្វានទាត្រានោះឯង ។ ខ្ញុំអានន្ទសំដែងនេះ អំពីសមយវិមុត្តិបុគ្គល

ឯអសមយវិមុត្តនោះ បានខាងព្រះអរហត្តមាន ២ ប្រការ គឺ ព្រះអរហត្តសុក្ខវិបស្សក ១ អរហត្តបដិសម្ភិទាញាណប្រការ ១, ឯអរហត្តសុក្ខវិបស្សកនោះ គឺភិក្ខុចំរើនព្រះកម្មដ្ឋាន ហើយបានសំរេចព្រះអរហត្ត ស្ងួតកិលេសតែប៉ុណ្ណោះ ឯអរហត្តបដិសម្ភិទាញាណ រៀនឈ្លានក្នុងព្រះត្រៃបិដក ចេះយល់គ្មានសល់ចន្លោះឡើយ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

បុ. ៣៣- សាធុ សាធុ អាវុសោ អាននូអើយ ចម្លើយអ្នកឆ្លើយមកនេះ ពេញពៅពីរោះគ្រោះក្បាយ ផ្ទាយទូលាយត្រូវតាមព្រះពុទ្ធដីកា យើងរាល់គ្នាក៏ចូលចិត្តហើយ អើអាននូអើយ សម្ដេចព្រះបរមលោកនាថសាស្ដាចារ្យ ទ្រង់សំដែងគម្ពីរបុគ្គលប្បញ្ញត្តិចប់ហើយ តើព្រះអង្គទ្រង់សំដែងគម្ពីរអ្វីតទៅទៀតហ្ន៎: អាននូអ្នក ?

វិ. ៣៣- ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សម្ដេចព្រះជិនវង្ស ទ្រង់សំដែងគម្ពីរបុគ្គលប្បញ្ញត្តិចប់ ហើយទ្រង់សំដែងគម្ពីរកថាវត្ថុតទៅទៀតណាអម្ចាស់ សូមទ្រង់ជ្រាប ។

បុ. ៣៤_ សាធុ សាធុ អាវុសោ អាននូអើយ សម្ដេចព្រះសាស្ដាចារ្យ ទ្រង់សំដែងគម្ពីរកថាវត្ថុនោះ តើមានប៉ុន្មានព្រះធម្មក្ខន្ធ ចែកជាសូត្រមានប៉ុន្មានសូត្រ ចូលអាននូអ្នកសំដែងមកកស្សប

បងនឹងចង់ស្តាប់មើលហ៎ះ អានន្ទអ្នក ?

ថិ. ៣៤- ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សម្តេចព្រះបរមពោធិញ្ញាណ ទ្រង់មានព្រះពុទ្ធដីកាចែកជា ៧១០០ ព្រះធម្មក្ខន្ធ ចែកជាសករាទិសូត្រ ៥០០ បរិវារទិសូត្រ ៥០០ តែព្រះពុទ្ធអង្គទ្រង់មិនសំដែងឲ្យពិស្តារឡើយ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សម្តេចព្រះជិនវង្ស ទ្រង់ញាណទៅឃើញថា ម.ឆសាវ័កជាខាងក្រោយឈ្មោះមោគ្គលីបុត្តតេ្ថរ នឹងមកសំដែងឲ្យពិស្តារតទៅទៀត ហេតុដូច្នេះ បានជាស្តេចព្រះទ្រង់យល់ ទ្រង់សំដែងជាពួក ជាកងណាអម្ចាស់ សូមទ្រង់ជ្រាប ។

ប៉ុ. ៣៥- សាធុ សាធុ អានន្ទអើយ ... ចំឡើយអ្នកឆ្លើយដោះស្រាយក្នុងសករាទិទាំង ៥០០ **បរិវារទិ ៥០០** នោះថាអង្គសម្តេចព្រះសាស្តាចារ្យ ទ្រង់អនុញ្ញាតទុកឲ្យព្រះមោគ្គល្លានសំដែងជាខាងក្រោយ យើងក៏ពេញចិត្តហើយ អើអានន្ទអើយ យើងនឹងសួរអ្នកក្នុងបរមត្ថធម៌ ដែលមានបាលី

បុគ្គលោ ឧបលព្ភតិ សច្ចិកដ្ឋបរមត្ថេនាតិ បញ្ចូលមកថាមានស្រីប្រុស មាន-សត្វ មានបុគ្គល ដូចជាមានព្រះបាលីជាដូច្នេះ រិតតែចម្លែកទៅទៀតណាអានន្ទអ្នក ចូរអានន្ទចាត់ចែងសំដែងមកកស្សបបងនឹងស្តាប់មើលហ៎ះអានន្ទអ្នក ?

ថិ. ៣៥- ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់

ហើយ សម្តេចព្រះសារពេជ្ញតាញាណ ទ្រង់មានព្រះពុទ្ធដីកាសំដែងថា ប
សត្វទាំងពួងកើតមកក្នុងវដ្តសំសារនេះ ជាទីជំរំនៃខន្ធទាំង ៥ ដូចគ្នា ក៏
លោកកំណត់ថាស្រីថាប្រុស ឯសត្វនិងបុគ្គលផ្សេងៗគ្នាតាំងពីបចង្កើតបញ្
ខាទាំង ៥ មានជើងដៃក្បាលជាដើមជាប្រធាននោះ មានសណ្ឋានផ្សេងពីគ្នាថា
ស្រី-ប្រុស ឯសត្វនិងបុគ្គលផ្សេងពីគ្នា ដូចជាសំដែងមកថាសត្វនេះ និងនោះ
ថា ឆ្កែ ឆ្មា មាន់ ទាក៏ទេ ឯមនុស្សនេះបានជាលោកសំដែងហៅថាសត្វដូច្នោះ ព្រោះ
លោកថា កើតមកជាមនុស្ស មិនដឹងបុណ្យ បាប គុណ ទោស លោកដូច្នោះ
បានជាលោកសំដែងថាសត្វ ឯបុគ្គលនោះលោកសំដែងថា អ្នកឯណា ១ រមោប
ក្នុងកិលេសវដ្តសង្សារ ប្រៀបដូចជាជ្រូកស្រុកដេកក្នុងលាមកយ៉ាងណាមិញអ្នកឯ
ណាបានរៀនធម៌សំណាក់ព្រះកម្មដ្ឋានដល់បដ្ឋានក្តី តែមិនបានកាត់ក្រមែល
កិលេសពោលគឺវដ្តសង្សារ ដូច្នេះហៅថាបុគ្គល ឯបុរសអ្នកមានសេចក្តីខ្មាសបាប
ដូច្នោះបានជាមានឈ្មោះថាបុរស ដូចមានបាលីថា ហិរិឱត្តប្បសម្បន្នា
សុក្កធម្មសមាហិតោ សន្តោ សប្បុរិសាលោកេ ទេវធម្មាតិ វុច្ចរេ ឯឧបាសកនិង
ទាយកនោះមិនត្រូវគ្នា ឯឧបាសកគឺអ្នករក្សាសីលពិព្យាយាមប្រតិបត្តតាមផ្លូវនវលោ
កុត្តរធម៌ទាំង ៩ ឯទាយកជាអ្នកឲ្យទានមិនមានខ្វះ ជាទីពឹងនៃស្មូមយាចក អ្នក
កំសត់ទុរគតជនទាំងឡាយ ឯមហាឧបាសកនិងមហាឧបាសិកា ទោះបីប្រុសស្រី
ក៏ហៅថាជាព្រះសោតា បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

ប៉ុ: ៣៦- សាធុ សាធុ អាវុសោ អានន្ទអើយ ចម្លើយអ្នកឆ្លើយមកនេះពីរោះពេកហើយ អើអានន្ទអើយ យើងនឹងដណ្ដឹងសួរអ្នកតទៅទៀតថា កាលអង្គសម្តេចព្រះបរមលោកនាថសាស្តាចារ្យ ស្តេចទ្រង់សំដែងគម្ពីរកថាវត្ថុចប់ តើព្រះអង្គទ្រង់សំដែងគម្ពីរអ្វីទៀតហ្ន៎ះ អានន្ទអ្នក ?

វិ. ៣៦- ភន្តេ កស្សប បពិត្រព្រះអរិយកស្សប អម្ចាស់អើយ សម្តេចព្រះពិជិតមារទ្រង់សំដែងគម្ពីរយមកតទៅទៀតណាអម្ចាស់ សូមទ្រង់ជ្រាប ។

ប៉ុ. ៣៧- អើអាវុសោ អានន្ទអើយ ព្រះពុទ្ធអង្គទ្រង់សំដែងគម្ពីរយមកនោះ តើទ្រង់សំដែងចែកចេញជាប៉ុន្មានព្រះធម្មក្ខន្ធ ? ចូរអានន្ទអ្នកអធិប្បាយប្រែស្រាយមកមើលហ្ន៎ះអ្នក ?

វិ. ៣៧- ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សម្តេចព្រះជិនវង្សទ្រង់សំដែងគម្ពីរយមកនោះ ទ្រង់ចែកចេញជាខន្ធមាន៥០០ព្រះធម្មក្ខន្ធ ចែកចេញជាយមកមាន ១០ គឺមូលយមក ១ ខន្ធយមក ១ អាយតនយមក ១ ធាតុយមក ១ សច្ចយមក ១ សង្ខារយមក ១ អនុសយយមក ១ ចិត្តយមក ១ ធម្មយមក ១ ឥន្ទ្រិយយមក ១ ផ្សំទាំងអស់ផងគ្នាត្រូវជាយមក១០ ប្រការ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមទ្រង់ជ្រាប ។

ប៉ុ. ៣៨- សាធុ សាធុ អាវុសោ អានន្ទអើយ អ្នកសំដែង

មកក្នុងយមកៈទាំង ១០ យើងចូលចិត្តហើយ អានន្ទអើយ យើងនឹងសួរអ្នកក្នុងយមក ១ ឈ្មោះមូលយមក នោះតើដូចម្ដេច ហៈអានន្ទ ចូរអ្នកចាត់ចែងសំដែងមក កស្សបបងនឹងស្ដាប់មើល ហៈអានន្ទអ្នក ។

ទិ. ៣៨ – ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ សូមស្ដាប់ខ្ញុំអានន្ទនឹងសំដែងតាមព្រះពុទ្ធអង្គទ្រង់ទេសនាថា បណ្ដាធម៌ទាំងពួង ធម៌ឯណាជាឫសជាគល់ ធម៌នោះឯងឈ្មោះថា មូលយមកៗនេះ អធិប្បាយប្រែស្រាយថា ជាឫសជាគល់នៃធម៌ទាំងពួង ណាអម្ចាស់សូមទ្រង់ជ្រាប ។

បុ. ៣៩ – កស្សបត្ថេរោ តំ សុត្វា ព្រះមហាកស្សបត្ថេរទ្រង់ព្រះសណ្ដាប់ព្រះមហាអានន្ទសំដែងមកដូច្នោះហើយ ក៏ដំណើងសួរតទៅទៀតថា ម្នាលអាវុសោអានន្ទអើយ ខ្ញុំកស្សបនៅសង្ស័យនឹងមូលយមកដែលអ្នកសំដែងថាជាឫសគល់ធម៌ទាំងពួង អានន្ទអើយ ចូរអ្នកសំដែងមក កស្សបបងនឹងស្ដាប់មើល ហៈអានន្ទអ្នក ?

ទិ. ៣៩ – កស្សបត្ថេរោ តំ សុត្វា បពិត្រព្រះអរិយកស្សបអើយ ខ្ញុំអានន្ទនឹងសំដែងតាមព្រះពុទ្ធដីកាថា អលោភោ អទោសោ អមោហោ ៗ ធម៌ទាំង ៣ នេះ ព្រះអង្គទ្រង់សំដែងថាជាឫសគល់ធម៌ទាំងពួង បានជាព្រះពុទ្ធអង្គទ្រង់សំដែងដូច្នោះ ពីព្រោះថា អលោភោនេះ អធិប្បាយថា មិនមានលោភ ហើយមានចិត្តសទ្ធាធ្វើបុណ្យឲ្យទានគ្មានរន្ធត់មច្ឆរិយ

នោះឡើយ ឯអទោសោ គ្មានសេចក្ដីខឹងក្រេវក្រោធនឹងអ្នកឯណា បណ្ដាសត្វទាំងពួងតែមានចិត្តដូច្នោះហើយ នឹងរក្សាពិព្យាយាមបាន , អមោហោ គ្មានវង្វេងទៅដោយអកុសលឡើយ នឹងចំរើនមេត្តាភាវនា ក៏មិនដាច់ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ បានជាសម្ដេចព្រះមុនីសរពេជ្ញតាញាណទ្រង់មានព្រះពុទ្ធដីកាថាជាឫសគល់ធម៌ទាំងពួង ព្រោះធម៌ទាំង ៣ ជំពូកជាទីទំនុកបំរុងធម៌ទាំងពួងគ្រប់ប្រការ បើអ្នកឯណារក្សាធម៌ទាំង ៣ ប្រការនេះបានស្មើរបានកាន់តាមធម៌ទាំងអស់ ប្រៀបដូចជាឈើ បណ្ដាបសផងទាំងពួង ដែលដុះក្នុងទីទំនាប តែងទទួលទឹកពីទីនានា យ៉ាងណាមិញ ធម៌ទាំង ៣ នេះជួយទំនុកបំរុងធម៌ទាំងពួងដូច្នោះឯង បពិត្រព្រះអរិយកស្សបជាអម្ចាស់ សូមទានក្រាប។

ពុ. ៤០– សាធុ សាធុ អាវុសោ ម្នាលអាវុសោអានន្ទអើយ យើងនឹងសំដែងក្នុងគម្ពីរយមក ១នេះ ដោយសង្ខិតកថា តែប៉ុណ្ណោះហើយយើងនឹងសួរអ្នកតទៅទៀតថា កាលសម្ដេចព្រះជិនវង្សស្ដេចទ្រង់សំដែងគម្ពីរយមកចប់ហើយ តើព្រះអង្គទ្រង់សំដែងគម្ពីរអ្វីតទៅទៀតហ្នះអានន្ទអ្នក ?

ទិ. ៤០– ភន្តេ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ កាលព្រះពុទ្ធអង្គទ្រង់សំដែងគម្ពីរយមកចប់ ព្រះអង្គទ្រង់សំដែងគម្ពីរមហាបដ្ឋានតទៅទៀតណាអម្ចាស់ សូមទ្រង់ក្រាប ។

បុ. ៤១- អើ អាវុសោ អានន្ទអើយ ព្រះបរមសាស្តាចារ្យ
ស្តេចទ្រង់សំដែងព្រះគម្ពីរមហាបដ្ឋាននោះ តើចែកចេញជាធម្មក្ខន្ធ មានប៉ុន្មាន
ហ:អានន្ទអ្នក ?

ធិ. ៤១– ភន្តេ កស្សប បពិត្រព្រះអរិយកស្សប ដ៏ប្រសើរ
អើយ សម្តេចព្រះមុនីនាថសាស្តាចារ្យ ស្តេចទ្រង់ចែកជា ៩៨០០ ព្រះធម្ម
ក្ខន្ធ ចែកជាហេតុមាន ២២ មានហេតុបច្ច័យជាដើមជាប្រធាន សម្តេចព្រះ
ទ្រង់ញាណ ទ្រង់សំដែងជាចំណែកបរិយាយច្រើនប្រការ ល្មើស រាល់ក្មាស់
ដែងបានតិចណាស់ បពិត្រព្រះអរិយកស្សបអើយ សូមទ្រង់ជ្រាប ។

បុ. ៤២- សាធុ សាធុ អាវុសោ អានន្ទអើយ ចម្លើយ
អ្នកឆ្លើយមកនោះពេញពោរពីរោះពេកហើយ អ្នកសំដែងថាហេតុបច្ច័យមាន ២៦
យើងលើកទុកសិនចុះ យើងនឹងសួរអ្នកក្នុងហេតុទាំង ៦ នោះ តើដូចម្តេចហ:
អានន្ទអ្នក ?

ធិ. ៤២— ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអើយ ឯ
ហេតុទាំង ៦ នោះ គឺលោភោប្រការ ១ ទោសោ ១ មោហោ ១ ឯលោភោ គឺ
ចិត្តលោភចង់បានទ្រព្យសម្បត្តិទាំងពួង ឯទោសោ គឺចិត្តខឹងក្រេវក្រោធ ឯមោ
ហោ គឺចិត្តងងឹតវង្វេង មិនដឹងបុណ្យបាប , គមិទាំង ៣ នេះ ជាមូលគល់នៃ
អកុសល ឯអលោភោ អទោសោ អមោហោ ជាមូលគល់នៃកុសល ,

ឫសគល់នៃកុសលនិងអកុសលនោះជាគូគ្នា ឥឡូវនេះ ខ្ញុំអាននូវនឹងសំដែងតែ ខាងកុសលធម៌ គឺអលោភោ អទោសោ អមោហោ ទាំង ៣ ដែលតែង ជួយទំនុកបំរុងក្នុងកាមាវចរ ឯកាមាវចរកុសលនោះ គឺចិត្តឧហាតសង្ខារធ្វើ បុណ្យឲ្យទានរក្សាសីលតាមសុចរិតធម៌ ឯរូបាវចរនោះ គឺរៀនវិបស្សនាកម្មដ្ឋាន បានចូលក្នុងឈានទាំង ៥ ឈ្មោះថារូបាវចរ ។ ឯបឋមជ្ឈានមាន អង្គ ៥ គឺវិតក្ក ១ វិចារ ១ បីតិ ១ សុខ ១ ឯកគ្គតា ១ ឯទុតិយជ្ឈានមាន អង្គ ៤ គឺវិចារ ១ បីតិ ១ សុខ ១ ឯកគ្គតា ១ ឯតតិយជ្ឈានមានអង្គ ៣ គឺបីតិ ១ សុខ ១ ឯកគ្គតា ១ ចតុត្ថជ្ឈានមានអង្គ ២ គឺសុខ ១ ឯកគ្គតា ១, បញ្ចមជ្ឈានមានអង្គ ២ គឺឯកគ្គតា ១ ឧបេក្ខា ១ ។ វិតក្កនោះគឺគិតតែនឹងធម៌, វិចារៈគឺពិចារណារកធម៌ ជាបរម សុខ, បីតិមានចិត្តត្រេកអរមាន ៥ ប្រការ គឺខុទ្ទកាបីតិ ១ ខណិកាបីតិ ១ ឱក្កន្តិកាបីតិ ១ ឧព្វេង្គាបីតិ ១ ផរណាបីតិ ១ ផ្សំផងគ្នាទាំងអស់ជាបីតិមាន ៥ ប្រការ ឯ ខុទ្ទកាបីតិ គឺការបង្កើតព្រឺព្រួចក្នុងចិត្តក្នុងកាយ, ខណិកាបីតិ សេចក្តីត្រេកអរដូចផ្លេកបន្ទោរ, ឱក្កន្តិកាបីតិ សេចក្តីត្រេកអរដូចរលកទឹកបោកខ្ទប់មកត្រូវ ឧព្វេង្គាបីតិ សេចក្តីត្រេកអរខ្លាំងអាចញ៉ាំងកាយឲ្យអណ្តែតផរណាបីតិ សេចក្តីត្រេកអរទ្វាំង ធ្វើឲ្យត្រជាក់ត្រជុំផ្សាយទូទៅក្នុងកាយ, ឯសុខ បង្កើត សេចក្តីសុខក្នុងចិត្តក្នុងកាយ សប្បាយរីករាយ, ឯកគ្គតា ផានចិត្តនោះ ឲ្យតែ ១ ប្រៀបដូចជាព្រួញ គឺបុគ្គលបាញ់ទៅរយៀវនោះត្រង់ដូចឈ្មោះមិញ

ឯចិត្តឯកគ្គតា ត្រង់ទៅកាន់ផ្លូវព្រះនិព្វាន ក៏ដូច្នោះដែរ ។ បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ខ្ញុំអាននូវសំដែងក្នុងបឋមជ្ឈាននេះ សង្ខេបតែប៉ុណ្ណោះ ល្មោះថាកាយគតាសតិ ហៅថាឧគ្គហនិមិត្ត ឯបដិភាគនិមិត្ត សំដៅយកស្រីទាំង ៦ ពណ៌ មានក្រហមសជាដើម ឯកាយគតាសតិនេះ លោកសំដែងទុកជាកណ្ដាល ឯអនាបានស្សតិ សំរេចយកខ្យល់ចេញចូលនេះឯង ។

បពិត្រអើយ ឯក្នុងទុតិយជ្ឈាន មិនមានវិតក្កឡើយ បើចូលសមាធិហើយបង្កើតនូវចិត្តបីតិ និងសុខ ឯកគ្គតា ។ ឯតតិយជ្ឈានតាំងអភិរម្យ ហើយបានសេចក្ដីសុខក្នុងឈាន មានចិត្តមូលតែ ៣ ទៅរកព្រះនិព្វានឯចតុត្ថជ្ឈានមានអង្គ ៣ កាលណាចំរើនហើយបានសេចក្ដីសុខសប្បាយមូលចិត្តទៅរកបរមសុខ ឯបញ្ចមជ្ឈានមានអង្គ២ និមិត្តបង្កើតឡើងកាលណា មានចិត្តមូលតែ ១ គឺឯកគ្គតា ឯចិត្តឧបេក្ខា គឺស្រឡាញ់រាប់អានអ្នកដទៃស្មើនឹងខ្លួនឯង ។ បពិត្រអើយ ខ្ញុំអាននូវសំដែងអំពីគម្ពីរមហាបដ្ឋានជាសង្ខេបតែប៉ុណ្ណោះ សូមទ្រង់ជ្រាប ។

ប. ៤៣- កស្សបត្ថេរោ តំ សុត្វា ព្រះមហាកស្សបត្ថេរ អ្នកបានស្ដាប់ថេរវាចា ព្រះមហាអានន្ទត្ថេរ នាំសេចក្ដីអធិប្បាយប្រែស្រាយតាមព្រះពុទ្ធដីកានូវបញ្ចក្ខន្ធទាំង ៥, វត្ថុទាំង ៦, ពិស្ដារទាំង ៧ នោះ កស្សបបងបានស្ដាប់ហើយ រីករាយចូលចិត្តហើយអាននូវអើយ តែកស្សបបងសូមសួរអ្នកទៅទៀតថា គម្ពីរទាំង ៣ ថា ម.អ.ខ នោះ តើដូចម្ដេច ចូលអាចារ្យ...

ចាត់ចែងសំដែងញែកចេញទាំង ៣ បទ ឲ្យច្បាស់តាមត្រាក់ទ្បូកនេះមើលហ្ន៎ះ អានន្ទអ្នក ?

ទិ. ៤៣- តំ សុត្វា អានន្ទត្ថេរ កាលណាបើបានស្តាប់ថេរវាចា ព្រះមហាកស្សបអ្នកចោទសួរផ្លូវឆ្នោះហើយ ក៏ពិតថេរវាចាថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអម្ចាស់អើយ ឥឡូវនេះអម្ចាស់សង្ស័យនឹងគម្ពីរទាំង ៣ នោះ ថាដូចម្តេចទៅ ? បពិត្រព្រះមហាកស្សបដ៏ចំរើនអើយ ម្ម- គឺគម្ពីរព្រះវិន័យទាំង ៥ អ្ន. គឺគម្ពីរព្រះអភិធម្មទាំង ៧ ខ្ញុ. គឺគម្ពីរព្រះសូត្រទាំង៥នេះឯងសូមទ្រង់ជ្រាប។

ប៉ុ. ៤៤- តំ សុត្វា បពិត្រអើយ អរិយកស្សប ខ្ញុំស្តាប់បានហើយ អានន្ទអើយ អ្នកឆ្លើយមកដូច្នេះពីរោះពេកហើយថា ម្ម. គឺគម្ពីរព្រះវិន័យទាំង ៥ អ្ន. នោះ គឺគម្ពីរព្រះអភិធម្មទាំង ៧ គម្ពីរ ខ្ញុ. នោះគឺគម្ពីរព្រះសូត្រទាំង ៥ អើអានន្ទ អើយ កាលយើងគេរៀន ន មោ ក ខ នោះតើយើងថា ម្ម អ្ន ខ្ញុ. ដូច្នេះឯង ឬថាមានប្រការដូចម្តេចហ្ន៎ អានន្ទអ្នក ? ចូរមានថេរដីកាឲ្យច្បាស់សោះសង្ស័យហ្ន៎ះអានន្ទអ្នក ?

ទិ. ៤៤- តំ សុត្វា បពិត្រអើយព្រះនោះព្រះមហាអានន្ទអ្នក បាន ស្តាប់ថេរវាចាព្រះអរិយកស្សបផ្ដាំងសួរដូច្នោះហើយ ក៏ឆ្លើយថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបអើយ ខ្ញុំអានន្ទនឹងឆ្លើយតាមព្រះពុទ្ធដីកាថា កាលយើងគេ

រៀន ន មោ ក ខ មិនបានថា ម.អ.ឧ. ដូច្នោះទេ ណាអម្ចាស់ សូមទ្រង់ជ្រាប ។

ပု. ៤៥- តំ សុត្វា មហាកស្សបោ ព្រះមហាកស្សបត្ថេរ កាលណាបើបានស្តាប់ព្រះមហាអានន្ទហើយ អ្នកក៏សួរទៅវិញទៀតថា ម្នាលអានន្ទអ្នកមានថេរដីកាថា ម្នះ នោះ តើ មរ ដែលគេផ្ដលក់សំពត់នោះឬ ? ម្នះ អានន្ទអ្នកចាត់ចែងសំដែងវោហារក្នុងអត្ថកថា ប្រែស្រាយប្រាប់អស់ឧបាសកឧបាសិកា នឹងបានស្ដាប់រាល់គ្នា មើលហ្ន៎ះអានន្ទអ្នក ?

វិ. ៤៥- ភន្តេ មហាកស្សប បពិត្រព្រះអរិយកស្សបតើយ ខ្ញុំអានន្ទនឹងឆ្លើយថ្វាយតាមសព្វព្រះទ័យ កុំសង្ស័យតទៅទៀតឡើយ បពិត្រអើយឯត្ថអក្ខរាដែលថា ម្នះ នោះ មិនមែន មរ ជ្រលក់សំពត់ឲ្យខ្មៅនោះឡើយ ត្ថ ម្នះ នេះគឺជាត្ថនាំមកចាប់បដិសន្ធិក្នុងព្រះឧទរនៃព្រះវរមាតាណាអម្ចាស់ ឯត្ថ អ នេះមកបង្កើតជាអង្គទ្រង់បញ្ចក្ខន្ធទាំង ៥ គឺដៃ ២ ជើង ២ ក្បាល ១ ឯត្ថ ឧ នេះលុះតែដល់គ្រប់ ១០ ខែហើយ ក៏ប្រសូត្រចេញមកឮដំគ្រានោះ ខ្ញុំអានន្ទសំដែងត្ថអក្សរទាំង ៣ បទនេះចប់តែប៉ុណ្ណោះឯង សូមទ្រង់ជ្រាប ។

ပု. ៤៦- តំ សុត្វា ព្រះមហាកស្សបត្ថេរ កាលណាបើបានស្ដាប់ដូច្នោះហើយ ក៏មានថេរវាចាថា អើអានន្ទអើយ កស្សបបងនឹង[illegible]

សួរបន្តិចទៀត ឯរូបយើងសព្វថ្ងៃនេះ កាលបើលទៅវិញនោះនឹងមានហេតុប្រការដូចម្ដេចហ្ន៎ អានន្ទអ្នក ? ចូរចាត់ចែងសំដែងអធិប្បាយប្រែស្រាយរាយសេចក្ដីឲ្យអស់ញាតិញោមផងទាំងពួង ស្ដាប់រាល់គ្នាមើលហ្ន៎អានន្ទអ្នក ?

ទិ. ៤៦- តំ សុត្វា អានន្ទត្ថេរោ ព្រះមហាអានន្ទត្ថេរកាលណាបើបានស្ដាប់ព្រះអរិយកស្សប ចោទសួរដូច្នោះហើយ អ្នកក៏ឆ្លើយថា ភន្តេ កស្សប បពិត្រព្រះអរិយកស្សបម្ចាស់អើយ សូមប្រុងសោតប្រសាទទាំងសង្ឃត្រងត្រាប់ ខ្ញុំអានន្ទនឹងសំដែងថ្វាយ ។ បណ្ដាមនុស្សយើងសព្វថ្ងៃនេះ បើដល់កំណត់អាយុហើយ ក៏ប្រែធាតុក្នុងកាយឲ្យរសាប់រសល់ថមថយកម្លាំង ប្រែទាំងធាតុទឹក ធាតុដី ធាតុភ្លើង ធាតុខ្យល់នេះឡើងកើតរងារ ក្ដៅក្រហល់ក្រហាយ អន្ទះអន្ទែង ប្រះផៃ ប្រះផើងដូច្នេះឯងហើយ បានជាលោកហៅថាស្លូឈាម ព្រោះធាតុភ្លើងនេះដុតរោលរាលក្នុងកាយនៃរូបយើងរាល់គ្នា ឯធាតុប៉ុន្មានមិញ ក៏រារលត់រលាយអស់ លុះខ្យល់ចេញទៅឈប់ដើរនោះ កុសលា អកុសលា និង អព្យាកតា គម្ពីរទាំង ៣ ដែលថា ម អ.ឧ នោះ ជំនុំគ្នា ថាបើរូបរាល់គ្នាបានធ្វើបុណ្យឲ្យទាន តើបានប៉ុន្មាន ធ្វើកុសលកម្មតើបានតិចឬច្រើន ក៏ឲ្យទៅសោយសម្បត្តិប្រាកដឰដ៏ទេវលោកនាយ ថាបើធ្វើអកុសលច្រើនឲ្យទៅរងទុក្ខវេទនា នៅមហាអវីចិមហានរកនាយនោះឯងហោង ទើបគម្ពីរទាំង ៣ ជំនុំគ្នារកទៅឃើញថាបុណ្យ

ជាបាប តិចច្រើន ហើយឲ្យទៅសោយផលកុសល អកុសល តាមអំពើរបស់ខ្លួន។

បពិត្រសប្បុរសផងទាំងពួងរាល់គ្នាអើយ គួរតែខ្លាចបាបខ្មាស់បាបស្រឡាញ់សម្បត្តិលោកីយ-បរលោក បើបុរសបុគ្គលឯណាពុំជឿគុណព្រះរតនត្រ័យ ទាំង ៣ ប្រការនេះហើយ ពុំធ្វើបុណ្យឲ្យទាន ពុំដឹងគុណទោសបុណ្យបាប ហើយក៏នាំគ្នាទៅសោយទុក្ខវេទនា ប្រាកដពុំលែងឡើយ បើបុគ្គលឯណាជឿគុណព្រះរតនត្រ័យ ធ្វើបុណ្យឲ្យទានរក្សាសីល អ្នកនោះនឹងបានទៅកើតនៅសុគតិភព ហើយទាន់ព្រះទ្រង់ញាណសិអារ្យមេត្រី បានសម្រេចអរហត្តផល ដល់នូវស្ថានព្រះបរមសុខ គឺព្រះនិព្វានពុំខានឡើយ ។ បពិត្រព្រះអរិយកស្សបម្ចាស់អើយ ខ្ញុំបាននាំសំដែងមក ក៏សូមបញ្ចប់តែប៉ុណ្ណោះ សូមទ្រង់ជ្រាប ។

## ព្រះមហាកស្សបសូត្របញ្ចប់

## ព្រះធម៌ទេសនា — ជូនពរ

**អភិធម្មបិដកការសានេ មុច្ចារិសជ្ជនា សមត្តា និដ្ឋិតា**

បពិត្រអស់សប្បុរសផងទាំងពួងអើយ វិការចោទឆ្លើយមកក្នុងគម្ពីរព្រះអភិធម្ម ក៏យល់ថាវែងឆ្ងាយណាស់ហើយ ឯទាយកទាយិកា ឧបាសកឧបាសិកា ក៏បានស្តាប់បានដឹងទំនងតាមគន្លងមកហើយដែរ បើដូច្នេះអាត្មាភាពនឹងសូមបញ្ចប់ដោយសង្ខេបតែប៉ុណ្ណោះឯង ម្យ៉ាងថ្ងៃក៏ទន់ទាបហៀបនឹងអស្តង្គតបាំងភ្នំព្រះសុមេរុទៅហើយ (ជិតពេលយប់រាត្រី ក៏យន់ទន់អាប្រោតស្ទាត់ សារិកាចូលដេក សេក

ចូលសំបុក កុកចូលទ្រនំ ) ក្មេងក្មាងតូចធំគ្រប់កម្ទោះ ចាស់ព្រឹទ្ធាចារ្យខ្លះផង ក៏ដោយជុំយកុគលក់ករគៀកខ្លះៗទាំហើយ ឯអាត្មាភាពទាំងអស់អង្គ ក៏គង់នៅវត្តឆ្ងាយពីគេណ: ឃ្លាតណាស់ពីផ្ទះ ទំរាំនឹងនិមន្តសល់នៅប្រហែលពេលទន់អា-ព្រាត្របែកមាចម៉ែឪមិនមឹង រំភើងតែលំបាកកាយ ឯញាតិញោមនៅឯអាយមឹងអាលទៅផ្ទះសម្បែងតំនៅស្ថានវិញ អាត្មាភាពទាំង ៣ អង្គសំដែងតែបន្តិចៗ យកតែផលវុទ្ធិសន្សំបស្នងធ្ងងសទ្ធាបោយកទាយិកាតែប៉ុណ្ណោះ មិនបានវិត្ថារពិស្តារប៉ុន្មានទៀយ ។

ធម្មទេសនានិសង្សេន ដោយអំណាចនៃអានិសង្ស ដែលកើតមកពីព្រះធម៌ទេសនាបុច្ឆាវិសជ្ជនានូវបិដកទាំង ៣ ក្នុងពេលនេះអាត្មាភាព សូមលើកកុសលរាសីនេះ ចែកជូនដល់វិញ្ញាណក្ខន្ធនៃបុព្វបុរសរបស់អស់លោកអ្នកសប្បុរសទាំងឡាយ មានមាតាបិតា គ្រូឧបជ្ឈាយាចារ្យ តាដូនមីង មាម៉ាកុងជាដើម ដែលបានចែកស្ថាននៅហើយ សូមឲ្យបានទទួលនូវឥដ្ឋមនុញ្ញផល គឺផលជាទីគាប់ចិត្តនោះ ឲ្យបានគ្រប់ ៗ គ្នា ។ ម្យ៉ាងទៀតសូមចែកជូនថ្វាយកុសលរាសីនេះ ដល់ភុម្មទេវតា អាកាសទេវតា រុក្ខទេវតា ព្រះព្រហ្ម ព្រះឥន្ទកោសិយជាដើម សូមបានចំណែកបុណ្យនេះ ដូចសប្បុរសជនទាំងឡាយ ហើយសូមជួយរក្សាពិថាលថែទាំលោកអ្នកនាងទាំង

ប្រុសស្រីក្មេងចាស់ ក្រមុំកម្លោះគ្រប់រូប អង្គ ឲ្យបានចម្រុងចំរើន កើតកាល វាលតុម្ពត្រដាក់ត្រដុំ សុខុមរមនាមូលមិត្ត បងប្អូនញាតិសាលោហិតព្រៀង លាន តាមសមគួរ ៗ សូមសាធុផនញាតិញោមទាំងឡាយ បាន ទទួលនូវផលានិសង្សនេះ តាមសេចក្តីប្រាថ្នារៀង ៗ ខ្លួន អនាគតជាតិ បើបានកើតក្នុងទីណា ៗ ជាតិណា ៗ ក៏សូមឲ្យមានប្រាជ្ញាដូចព្រះសារីបុត្ត ចេះ ចាំធម៌យ៉ាងមុះមុត ដូចព្រះមហាអានន្ទ មានសម្បត្តិទ្រព្យធនធានរាប់ពាន់ លានកោដិ ដូចសេដ្ឋីអនាថបិណ្ឌិក ល្អរូប ល្អរាង ល្អវៅ ល្អឫក ប្រកបដោយបញ្ចពិធកល្យាណី ដូចនាងស្រីវិសាខា មានអាយុជន្មាយឺនយូរ ដូចព្រះមហាកស្សប ប្រាថ្នាជប់បានជប់ប្រាថ្នាជាព្រះពុទ្ធមាតាពុទ្ធបិតា ឬ អគ្គសាវក អគ្គសាវិកាណា ៗ ក៏សូមឲ្យបានសម្រេចដូចសេចក្តីប្រាថ្នា កើតជាតិណា ៗ សូមជួបនឹងតាជីដូនប្អូនបងជិតឆ្ងាយ ម្តាយឪពុក ជួបនឹងព្រះរតនត្រ័យគុណកែវទាំង ៣ តាមសេចក្តីបំណង, បើចង់សម្បត្តិទាំង ៣ គឺសម្បត្តិមនុស្ស សម្បត្តិទេពតា សម្បត្តិព្រះនិព្វាន ក៏សូមឲ្យបានសម្រេច យំ យំ ឥច្ឆិតំ តំ តំ សមិជ្ឈតុ លោកអ្នកនាងមានប្រាថ្នាយ៉ាងណា ក៏សូមឲ្យបានសម្រេចតាមសេចក្តីប្រាថ្នានោះ ៗ កុំបីឃ្លាតឡើយ ។

**ធម្មទេសនាវសានេ** នាកាលព្រះធម៌ទេសនាបុច្ឆាវិសជ្ជនា អំពីគម្ពីរ

ព្រះអភិធម្មចប់ហើយ  ក៏សូមអរាធនានិមន្តព្រះសង្ឃដែលគង់ហត្ថបាសដ៏មាននូវព្រះមហាថេរទាំង ៤ អង្គរៀបខ្លួនឲ្យចំណាប់ចាប់នូវផងផ្ចិតវិចិត្រដោយភ្ញក  សូត្ររលាក់រលែតបែកសម្លេងជាបទខ្មែរឲ្យព្រម ៗ  ល្បូទល្មោកទាំង ៤ ព្រះអង្គទៅហោង ។

អយំ  ធម្មទេសនា  និដ្ឋិតា  ព្រះធម៌ទេសនាដែលបានសំដែងចោទធ្វើយមកនេះ  ក៏សូមបញ្ចប់តែប៉ុណ្ណោះឯង ឯវំ ។

ចប់ព្រះអភិធម្មបិដក

បឋមសង្គាយនាត្រៃបី

ចប់តែប៉ុណ្ណោះ

# ធម៌សូត្រ – អានត្រៃ

ព្រះវិន័យ ព្រះសូត្រ ព្រះបរមត្ថសង្ខេប ដែលលោករួមទុកឲ្យព្រះសង្ឃសូត្រក្នុងកាលចប់ សង្គីតិទេសនានោះ តាមលំដាប់តទៅ

## ព្រះវិន័យ

សំរាប់សូត្រនៅពេល ចោទ – ឆ្លើយ ព្រះវិន័យចប់

យេន ភគវតា បស្សតា អរហតា សម្មា សម្ពុទ្ធេ បឋមំ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយំ បញ្ញត្តន្តិ ។ កំ អារព្ភាតិ ។ សុទិន្នំ កលន្ទបុត្តំ អារព្ភាតិ ។ កិស្មឹ វត្ថុស្មិន្តិ ។ សុទិន្នោ កលន្ទបុត្តោ បុរាណទុតិយិកាយ មេថុនំ ធម្មំ បដិសេវី តស្មឹ វត្ថុស្មិន្តិ ។

តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ វិហរតិ នឡេរុបុចិមន្ទមូលេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ អស្សោសិ ខោ វេរញ្ជោ ព្រាហ្មណោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ វេរញ្ជាយំ វិហរតិ នឡេរុបុចិមន្ទមូលេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ តំ ខោ បន ភវន្តំ

គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

## ព្រះសូត្រ

សំរាប់សូត្រនៅពេលចោទ – ឆ្លើយ ព្រះសូត្រចប់

ឯវម្មេ សុតំ ឯកំ សមយំ ភគវា អន្តរា ច រាជគហំ អន្តរា ច នាលន្ទំ អទ្ធានមគ្គប្បដិបន្នោ ហោតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ សុប្បិយោបិ ខោ បរិព្វាជកោ អន្តរា ច រាជគហំ អន្តរា ច នាលន្ទំ

អទ្ធានមគ្គប្បដិបន្នោ ហោតិ សទ្ធឹ អន្តេវាសិនា ព្រហ្មទត្តេន·មាណវេន ។ តត្រ សុទំ សុប្បយោ បរិព្វាជកោ អនេកបរិយាយេន ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ។ សុប្បិយស្ស បន បរិព្វាជកស្ស អន្តេវាសិ ព្រហ្មទត្តោ មាណវោ អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ ។ ឥតិហ តេ ឧភោ អាចរិយន្តេវាសី អញ្ញមញ្ញស្ស ឧជុវិបច្ចនីកវាទា ភគវន្ត បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា ហោន្តិ ភិក្ខុសង្ឃញ្ច ។

## ព្រះអភិធម្ម

សំរាប់សូត្រនៅពេលចោទ – ឆ្លើយព្រះអភិធម្មចប់

### ធម្មសង្គណី

កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ។ កតមេ ធម្មា កុសលា ។ យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ញាណសម្បយុត្តំ

រូបារម្មណំ វា សទ្ទារម្មណំ វា គន្ធារម្មណំ វា រសារម្មណំ វា ផោដ្ឋព្វារម្មណំ វា ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មិំ សមយេ ផស្សោ ហោតិ អវិក្ខេបោ ហោតិ ។ យេ វា បន តស្មឹ សមយេ អញ្ញេបិ អត្ថិ បដិច្ចសមុប្បន្នា អរូបិនោ ធម្មា ឥមេ ធម្មា កុសលា ។

ចប់

បានតម្កល់ទុកតាមច្បាប់លេខ ១១៤
ទះថ្ងៃទី ២៩ - ៣ - ៦៩ ចំនួន ៣០០០ក្បាល

មានលក់ដុំនិងរាយនៅ

Librairie et Imprimerie
PHNOM-PENH
59, VITHEI PASTEUR, 59
PHNOM-PENH